# ថ្ងៃទី០១ ខែ សីហា ឆ្នាំ២០២៣

## អាស៊ាន ពង្រឹងកិច្ចសហប្រតិបត្តិការ លើការគាំពារពលករចំណាកស្រុកក្នុងតំបន់អាស៊ាន

https://www.postkhmer.com/national/2023-07-30-1856-252903.html *រី សុចាន់* | Publication date 30 July 2023 | 18:56 ICT

***ភ្នំពេញ:*** *ប្រតិភូជាង ៩០ នាក់ ដែលជាជនបង្គោល នៃគណៈកម្មាធិការអាស៊ាន ស្ដីពីការអនុវត្តសេចក្ដីថ្លែងការណ៍អាស៊ាន ស្ដីពីការគាំពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍* (ACMW)*នៃរដ្ឋសមាជិកអាស៊ានទាំង ១០ ប្រទេស និងលេខាធិការដ្ឋានអាស៊ានបានចូលរួមកិច្ចប្រជុំលើកទី១៦ នៃ* ACMW *កាលពីថ្ងៃទី២៦-២៧ ខែកក្កដា តាមរយៈប្រព័ន្ធវីដេអូនៅប្រទេសឥណ្ឌូនេស៊ី។ អ្នកចូលរួមដែលជាជនបង្គោលរបស់ទីម័រខាងកើត ក៏បានចូលរួមជាអ្នកសង្កេតការណ៍ជាលើកដំបូងផងដែរនៅក្នុងកិច្ចប្រជុំនេះ។*

*សេចក្ដីប្រកាសព័ត៌មានលេខាធិការដ្ឋានអាស៊ាន បញ្ជាក់កាលពីថ្ងៃទី២៧ ខែកក្កដាថា កិច្ចប្រជុំនេះបានពិនិត្យមើលពីវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៨-២០២៥ នៃកិច្ចព្រមព្រៀងអាស៊ានស្ដីពីការគាំពារ និងលើកកម្ពស់សិទ្ធិពលករចំណាកស្រុក។ លទ្ធផលសំខាន់ៗ និងបញ្ហាប្រឈមនៃគំនិតផ្ដួចផ្ដើមដែលបានបិទបញ្ចប់ ក៏ដូចជាការអនុវត្តគម្រោងដែលកំពុងបន្ត និងផែនការនៃគម្រោងត្រូវបានពិភាក្សាផងដែរ។*

*សេចក្ដីប្រកាសព័ត៌មានបញ្ជាក់ថា៖ «កិច្ចប្រជុំក៏បានពិនិត្យមើលលទ្ធផលនៃស្វ័យវាយតម្លៃលើកទី២ របស់រដ្ឋសមាជិកអាស៊ាន ស្ដីពីការអនុវត្តការកិច្ចព្រមព្រៀងនេះផងដែរ។ វឌ្ឍនភាពប្រកបដោយស្ថិរភាព និងការបង្កើនកិច្ចខិតខំប្រឹងប្រែងត្រូវបានសង្កេតឃើញថា ធ្វើឡើងដើម្បីសម្រេចបានការប្ដេជ្ញាចិត្តនៃកិច្ចព្រមព្រៀងនេះ»។*

*កិច្ចប្រជុំនេះក៏បានពិភាក្សាលើសេចក្ដីថ្លែងការណ៍អាស៊ាន ដែលបានអនុម័តនាពេលថ្មីៗនេះទាក់ទងនឹងការគាំពារពលករចំណាកស្រុក រួមមានសេចក្ដីថ្លែងការណ៍អាស៊ាន ស្ដីពីចល័តភាពនៃអត្ថប្រយោជន៍របបសន្តិសុខសង្គម សម្រាប់ពលករទេសន្តរប្រវេសន៍ក្នុងតំបន់អាស៊ាន, សេចក្ដីថ្លែងការណ៍អាស៊ានស្ដីពីការគាំពារពលករចំណាកស្រុក និងសមាជិកគ្រួសារស្ថិតក្នុងស្ថានភាពវិបត្តិ, និងសេចក្ដីថ្លែងការណ៍អាស៊ានស្ដីពីការបញ្ជូន និងគាំពារអ្នកនេសាទចំណាកស្រុក ក៏ដូចជាការអភិវឌ្ឍបន្តនៃគោលការណ៍ណែនាំដើម្បីប្រែក្លាយការប្ដេជ្ញាចិត្តទៅជាសកម្មភាពជាក់ស្ដែង។*

*តំណាងអង្គការអន្តរជាតិទេសន្តរប្រវេសន៍* (IOM) *និងអង្គការអន្តរជាតិខាងការងារ* (ILO) *ក៏បានចូលរួមក្នុងកិច្ចពិភាក្សាបើកចំហក្នុងកិច្ចប្រជុំនេះរួមទាំងដៃគូម្ចាស់ជំនួយនីមួយៗ ពីប្រទេសអូ*

ស្ត្រាលី កាណាដា និងសហភាពអឺរ៉ុប (EU)។ កិច្ចពិភាក្សាបើកចំហនេះបានបិទបញ្ចប់ដោយតំណាង របស់ ILO និង IOM ដោយបានព្រមព្រៀងពិនិត្យ និងធ្វើបច្ចុប្បន្នភាពភាពជាដៃគូដែលកំពុងដំណើរ ការ និងស្វែងរកវិស័យអាទិភាពផ្សេងទៀតសម្រាប់កិច្ចសហការនាពេលអនាគត រួមមានការពង្រឹងកិច្ចខិតខំប្រឹងប្រែង និងគំនិតផ្តួចផ្តើមក្នុងការទប់ស្កាត់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្មរបស់ពលករចំណាកស្រុក ក៏ដូចជាការលើកកម្ពស់ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងយុត្តិធម៌នៅក្នុងតំបន់។

ក្រៅពីនេះ កិច្ចប្រជុំបានរំឭកឡើងវិញពីការដាក់ឱ្យប្រើប្រាស់ថ្មីៗនូវការណែនាំជាវីដេអូ(AVP) នៃយុទ្ធនាការសាធារណៈស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងយុត្តិធម៌ក្នុងតំបន់អាស៊ាន ដែលរៀបចំដោយប្រទេសហ្វីលីពីនកាលពីថ្ងៃទី៤ ខែកក្កដា នៅទីក្រុងបូរ៉ាកៃ (Boracay) ប្រទេសហ្វីលីពីន។ យុទ្ធនាការនេះត្រូវបានគាំទ្រដោយ EU តាមរយៈឧបករណ៍លើកកម្ពស់កិច្ចសន្ទនា EU-អាស៊ាន ក្នុងតំបន់ និងអង្គការ ILO។

AVP ត្រូវបានផលិតឡើងជាសម្ភារអប់រំ និងលើកកម្ពស់ការយល់ដឹង ដើម្បីផ្តល់ឱ្យពលករចំណាកស្រុកបច្ចុប្បន្ន និងអនាគត នូវព័ត៌មានគ្រប់ជ្រុងជ្រោយ និងអាចទុកចិត្តបាននៅមុនពេលធ្វើដំណើរនិងក្រោយពេលមកដល់ដើម្បីរៀបចំពួកគេឱ្យកាន់តែប្រសើរឡើងសម្រាប់ការធ្វើចំណាកស្រុក និងការពារពួកគេពីការកេងប្រវ័ញ្ចរាល់គ្រប់ទម្រង់។AVPដែលរៀបចំជាភាសាអង់គ្លេសក៏ត្រូវបានបកប្រែជាភាសាជាតិរបស់រដ្ឋសមាជិកអាស៊ានដែលមានភាសាខ្មែរផងដែរ ដើម្បីបង្កើនការយល់ដឹង៕

## កិច្ចប្រជុំតាមដានត្រួតពិនិត្យប្រចាំខែកក្កដា របស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប

https://www.information.gov.kh/articles/110262 ចេញផ្សាយ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០២៣

នៅសាលាខេត្តសៀមរាប នៅព្រឹកថ្ងៃ ទី៣១ ខែកក្កដា ឆ្នាំ២០២៣ លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត (គ.ខ.ប.ជ.សរ) បើកកិច្ចប្រជុំប្រចាំខែកក្កដា ឆ្នាំ ២០២៣ ក្រោមកិច្ចដឹកនាំរបស់លោកស្រី យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តសៀមរាប ព្រមទាំងមានការអញ្ជើញចូលរួមពីលោក លោកស្រី សមាជិក សមាជិកា លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរ អង្គភាពពាក់ព័ន្ធ រដ្ឋបាលក្រុង ស្រុក មន្ត្រីនគរបាលយុត្តិធម៌ តំណាងព្រះរាជអាជ្ញាអមសាលាដំបូងខេត្ត ព្រមទាំងតំណាងអង្គការ ដៃគូពាក់ព័ន្ធ សរុប ៦០នាក់ ស្រី ២៩នាក់។

កិច្ចប្រជុំបានប្រព្រឹត្តទៅតាមកម្មវិធីរួមមានៈ ១.ពិនិត្យទៅលើសេចក្តីព្រាងរបាយការណ៍ប្រចាំខែកក្កដា ឆ្នាំ២០២៣ ២. ពិនិត្យ និងពិភាក្សាលើបញ្ហាប្រឈមមួយចំនួន ដែលក្រុមការងារបានអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមគ្រប់រូបភាព ដោយមានការចូលរួមសហការពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ នៅតាមមូលដ្ឋានភូមិ ឃុំ ដូចជា ធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ការជួញដូរមនុស្សឆ្លងដែន កិច្ចការពារជនរងគ្រោះដោយការរត់ពន្ធមនុស្ស និងការជួញដូរមនុស្សឆ្លងដែន ខុសច្បាប់ជាដើមៗលៗ

នៅក្នុងសេចក្តីព្រាងរបាយការណ៍ប្រចាំខែកក្កដា ឆ្នាំ២០២៣ របស់លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត បានបង្ហាញពីចំណុចខ្លាំងដោយបានអនុវត្តយ៉ាងយកចិត្តទុកដាក់នូវទិសដៅភារកិច្ចរបស់ខ្លួនតាមការគ្រោងទុក ព្រមទាំងមានការចូលរួមកាន់តែសកម្មពីមន្ត្រីអនុវត្តតាម បណ្តាមន្ទីរ អង្គភាពពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារសហប្រជាជាតិផងដែរ។

លើសពីនេះកិច្ចប្រជុំក៏បានលើកយកបញ្ហាជាច្រើនមកពិភាក្សា ដើម្បីស្វែងរកដំណោះស្រាយរួមគ្នា សម្រាប់ការការពារជនរងគ្រោះ និងងាយរងគ្រោះ ដោយសារការរត់ពន្ធឆ្លងដែនជាដើម។ អង្គប្រជុំបានពិភាក្សាលើករណីប្រជាពលរដ្ឋដែលបានស្នើឱ្យអាជ្ញាធរធ្វើការបញ្ជាក់អំពីទំនាក់ទំនងរវាងពលរដ្ឋខ្មែរចំនួន ១នាក់ ថាជាកូនចិញ្ចឹមរបស់គ្រួសារជនជាតិជប៉ុន ដើម្បីបានទៅធ្វើការនៅប្រទេសជប៉ុនដោយមិនចាំបាច់ចំណាយលើការបង់ពន្ធ ប៉ុន្តែពុំត្រូវបានអាជ្ញាធរធ្វើការបញ្ជាក់ជូនឡើយដោយពុំមានលិខិតបទដ្ឋានគតិយុត្តិណាមួយ ត្រឹមត្រូវតាមច្បាប់សម្រាប់ធ្វើការបញ្ជាក់បាននោះទេ។

ពាក់ព័ន្ធនឹងករណីនេះដែរ លោកស្រីព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្ត និងជាអនុប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានផ្តល់ជាអនុសាសន៍ថា ករណីខាងលើនេះអាជ្ញាធរមូលដ្ឋានមិនមានសមត្ថកិច្ចបញ្ជាក់អះអាងថាជាកូនចិញ្ចឹមឬជាកូនសុំបានទេ(សុំកូន) គប្បីប្រើនីតិវិធីស្នើសុំទៅតុលាការ ដើម្បីបំពេញបែបបទពាក់ព័ន្ធទៅតាមលក្ខ័ណ្ឌលើការស្នើសុំ របស់ភាគីអ្នកស្នើសុំ និងកូនសុំ។

បន្ថែមពីនោះអង្គប្រជុំក៏បានធ្វើការពិភាក្សាលើទៅបញ្ហាពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយបានស្នើដល់មន្ត្រីមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធ ជាពិសេសមន្ត្រីនៅមូលដ្ឋានផ្ទាល់តែម្តង នៅពេលដែលទទួលបានករណីដែលសង្ស័យថាមានជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឬ អំពើរំលោភបំពាននានា សូមឱ្យធ្វើការកំណត់អត្តសញ្ញាណឱ្យបានច្បាស់លាស់ទៅតាមទម្រង់ ដែលក្រុមការងារបានធ្វើការបណ្តុះបណ្តាលកន្លងមក ជៀសវាងការកំណត់មិនបានត្រឹមត្រូវធ្វើឱ្យសមត្ថកិច្ចជំនាញពិបាកក្នុងការបង្ក្រាប ក៏ដូចការផ្តល់សេវាមិនបានសមស្រប។

ទន្ទឹមនឹងការផ្តល់សេវាឱ្យសមស្រប លោកស្រី យូ សុភា អភិបាលរងខេត្ត និងប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានជំរុញឱ្យមន្ទីរសង្គមកិច្ច ពង្រឹងទៅលើការធ្វើអធិការកិច្ចនៅតាមមណ្ឌលថែទាំជំនួសនៅក្នុងខេត្តឱ្យបានគ្រប់មណ្ឌល និងត្រូវមានវិធានការឱ្យម៉ឺងម៉ាត់ចំពោះមណ្ឌលថែទាំណាមិនអនុវត្ត ឬគោរពទៅតាមគោលការណ៍ និងបទដ្ឋានអប្បបរិមាដែលក្រសួងបានកំណត់។ ស្របតាមបរិបទឌីជីថល ការប្រើប្រាស់ប្រព័ន្ធបណ្តាញសង្គមរបស់ប្រជាពលរដ្ឋបាននឹងកំពុងមានសន្ទុះយ៉ាងខ្លាំងនោះ នៅក្នុងខេត្តរបស់យើងសមត្ថកិច្ចក៏បានធ្វើការស្រាវជ្រាវ និងបង្ក្រាបបាននូវករណីរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញបានមួយចំនួនផងដែរ។

ដើម្បីឆ្លើយតបទៅបញ្ហានេះ សូមឱ្យសមត្ថកិច្ចពាក់ព័ន្ធ អាជ្ញាធរគ្រប់ថ្នាក់ និងអង្គការដៃគូទាំងអស់ បង្កើនកិច្ចខិតខំប្រឹងប្រែងសហការទប់ស្កាត់តាមរយៈការងារអប់រំផ្សព្វផ្សាយតាមគ្រប់រូបភាព និងប្រើប្រាស់គ្រប់លទ្ធភាព និងធនធាន ពិសេសនៅតាមគ្រឹះស្ថានសិក្សា ដើម្បីលើកកម្ពស់ការយល់ដឹងជាសាកលអំពីការជួញដូរ ការធ្វើអាជីវកម្មផ្លូវភេទ កិច្ចការពារកុមារពីការរំលោភបំពានផ្សេងៗ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តប្រវេសន៍ និងអំពើជួញដូរមនុស្ស ព្រមទាំងបទល្មើសពាក់ព័ន្ធដទៃទៀតឱ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវ័យក្នុង និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។ លោកយូ វង្ស កែសម្រួលដោយ លីវ សុខុន

# ថ្ងៃទី០២ ខែ សីហា ឆ្នាំ២០២៣

## នគរបាលការពារព្រំដែន ចេញល្បាតទប់ស្កាត់បទល្មើសឆ្លងដែន

https://kohsantepheapdaily.com.kh/article/1779203.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram បន្ទាយមានជ័យ០១ ខែ សីហា ឆ្នាំ ២០២៣ ម៉ោង ០៩:២៩

ខេត្តបន្ទាយមានជ័យ ៖ កម្លាំងនគរបាលការពារព្រំដែនគោកលេខ៨៩១ តែងចេញល្បាតពង្រឹងវិធានការទប់ស្កាត់បទល្មើសឆ្លងដែន និងពលករចំណាកស្រុកដោយខុសច្បាប់ នៅខាងត្បូងច្រកទ្វារអន្តរជាតិប៉ោយប៉ែត ក្រុងប៉ោយប៉ែត ។

លោកវរសេនីយ៍ត្រី សែម សាមឿន នាយប៉ុស្តិ៍នគរបាលការពារព្រំដែនគោកលេខ៨៩១ ថ្លែងថា តាមការណែនាំរបស់លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្ត ដើម្បីទប់ស្កាត់បទល្មើសឆ្លងដែន និងពលករចំណាកស្រុកខុសច្បាប់ ព្រមទាំងទំនិញគេចពន្ធ កងកម្លាំងតែងចេញល្បាតតាមបន្ទាត់ព្រំដែន ពីចំណុចក្បាលស្ពានខាងត្បូងច្រកទ្វារអន្តរជាតិប៉ោយប៉ែត រហូតដល់ព្រំប្រទល់ស្រុកម៉ាឡៃ ។

លោកបញ្ជាក់ថា នៅតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ខាងត្បូងច្រកទ្វារអន្តរជាតិប៉ោយប៉ែត ស្ថិតភូមិសាស្ត្រក្រុងប៉ោយប៉ែត ជាអូរព្រំដែនដែលមានទឹកជ្រៅ អាចរារាំងរាល់បទល្មើសបាន ។ ប៉ុន្តែនៅអូរព្រំដែនស្រុកម៉ាឡៃ ត្រូវតែពង្រឹងនិងការពារទប់ស្កាត់រាល់ថ្ងៃយប់ ព្រោះជាចំណុចទឹករាក់ ដើម្បីទបស្កាត់បទល្មើសឆ្លងដែននិងពលករលួចឆ្លង ដែលត្រូវទប់ស្កាត់ឱ្យបាន ។

លោកវរសេនីយ៍ត្រី សែម សាមឿន ថ្លែងទៀតថា កម្លាំងនគរបាលការពារព្រំដែនគោកលេខ ៨៩១ ដែលកំពុងឈរជើងតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ គឺដើម្បីការពារបូរណៈភាពទឹកដីការពារសន្តិសុខជូនប្រជាពលរដ្ឋ និងទប់ស្កាត់បទល្មើសលួចឆ្លងដែន និងពលករចំណាកស្រុក ៕

# ថ្ងៃទី០៣ ខែ សីហា ឆ្នាំ២០២៣

## ប៉ូលិសថៃ ចាប់ខ្លួនពលករខ្មែរ១១នាក់ និងទាហានថៃម្នាក់ ខណៈកំពុងបម្រុងរត់ចូលឆ្លងដែន ចូលទៅប្រទេសថៃ ដោយខុសច្បាប់

https://cen.com.kh/archives/682158.html Posted ByPen Srey NeatAugust 2, 2023

ខេត្តស្រះកែវ ៖ មន្ត្រីកងទ័ពប៉ូលិស រកឃើញពលករចំណាកស្រុកខ្មែរ រត់ឆ្លងដែនចូលក្នុងទឹកដីថៃដោយខុសច្បាប់ ក្នុងនោះមនុស្ស ១១ នាក់ រួមជាមួយមេខ្យល់នាំជនជាតិថៃ ១ នាក់ នៅព្រំដែនស្រុកខក់ស៊ុង ខេត្តស្រះកែវ នាំចូលតំបន់នេះដើម្បីត្រៀមទៅទីក្រុងបាងកក ខេត្តខនកែន ខេត្តឈុនបុរី ខេត្តរ៉ាយ៉ង ត្រូវបានបញ្ជូនទៅកាត់ទោសតាមច្បាប់។

កាលពីថ្ងៃទី១ ខែសីហា ឆ្នាំ២០២៣ ឧត្តមសេនីយទោ ថេប តាក់និមិត មេបញ្ជាការកងទ័ពប៉ូរ៉ាផា បញ្ជាឲ្យផ្ទាំព្រំដែន ខេត្តស្រះកែវរឹតបន្តឹងការរត់ពន្ធ ទំនិញខុសច្បាប់ និងនាំពលករបរទេសឆ្លងកាត់ព្រំដែន កម្ពុជា-ថៃ រហូតដល់ពាក់កណ្ដាលយប់ វរសេនីយ៍ឯក គី យ៉ាណែត ផាតសាសារ៉ាតវង្ស អគ្គបញ្ជាការនៃកងវរសេនាធំបញ្ជាការយោធភូមិភាគទី១២ (ឆ.គ.ធ.ធ.១២) បានបញ្ជាឲ្យលោកវរសេនីយ៍ទោអង្គភាពបញ្ជាការដ្ឋានកងអនុសេនាធំលេខ១២ សហការជាមួយកម្លាំងពិសេស ១១២ រៀបចំកម្លាំងចុះល្បាត និងត្រួតពិនិត្យនៅតំបន់ទទួលខុសត្រូវ ឃាត់ខ្លួនជនសង្ស័យចំនួន១២នាក់ ខណៈកំពុងធ្វើដំណើរតាមបណ្ដោយផ្លូវព្រៃធម្មជាតិ (ចូល) ចម្ងាយប្រហែល១០០ម៉ែត្រ ពីផ្លូវស៊ីផេន ចន្លោះបង្គោលគីឡូម៉ែត្រលេខ ៣៩-៤០ ភូអរដោះ TA 520237, Ban Nong Chan, T. Non Mak Mun, ស្រុកខុកស៊ុង ខេត្តស្រះកែវ ទើបធ្វើការស្រាវជ្រាវជាបឋម ទើបដឹងថា ពួកគេជាពលករខ្មែរចំនួន១១នាក់ ប្រុស៧នាក់ ស្រី៤នាក់ រួមនឹងមេខ្លោងនាំជនជាតិថៃ១នាក់ មកឃាត់ខ្លួនយកមកសាកសួរនៅប៉ុស្តិ៍លេខ១២០៦។

បន្ទាប់ពីមន្ត្រីបានវាស់សីតុណ្ហភាពរាងកាយដំបូងរបស់មនុស្សគ្រប់គ្នា សីតុណ្ហភាពរបស់មនុស្សគ្រប់រូបមិនលើសពី 37.5 អង្សាសេទេ។ រកមិនឃើញឯកសារលិខិតឆ្លងដែន ឬឯកសារចុះឈ្មោះសម្រាប់ពលករចំណាកស្រុកចំនួន ១១នាក់ ដែលមាន ៣សញ្ជាតិ និងពីការសម្ភាសន៍ពលករខ្មែរ ដឹងជាបឋម បានមកជួបមេដឹកនាំជាជនជាតិថៃ ដើម្បីទៅកាន់ចំណុចប្រជុំនៅភូមិណងចាន់ ឃុំណនម៉ាក់មុន ដើម្បីធ្វើដំណើរទៅធ្វើការក្នុងតំបន់ បាងកក ខនកែន ឈុនបុរី រ៉ាយ៉ុង។

ទោះជាយ៉ាងណា តាមការស៊ើបអង្កេតមេខ្យល់ជនជាតិថៃ បានឲ្យដឹងជាបឋម គឺនាំពលករខ្មែរទាំងអស់ទៅចំណុចប្រជុំ នៅភូមិណងចាន់ ឃុំណន ម៉ាក់មុនចាំឡានមកធ្វើការនៅខាងក្នុងប្រទេសថៃ ពួកគេនឹងទទួលបានថ្លៃដឹកជញ្ជូន ៣០០ បាត ក្នុងម្នាក់ពេលទៅដល់គោលដៅរហូតដល់ត្រូវបាន ចាប់ខ្លួនដំបូង ដោយមន្ត្រីអនុរក្សនិងមន្ត្រីប៉ូលិស រ.១១២ ហើយចាប់ខ្លួន។ នៅពេលចាប់ខ្លួនមានមេដឹកនាំម្នាក់ ដែលក្រោយមកបានស៊ើបអង្កេត និង កត់ត្រាការចាប់ខ្លួន។ ជនជាប់ចោទទាំងអស់ត្រូវបាននាំយកមក បញ្ជូនទៅកាន់អធិការដ្ឋាននគរបាលខណ្ឌគោកឃ្វាង ដើម្បីចាត់ការបន្តតាមផ្លូវច្បាប់ ៕ រក្សាសិទ្ធដោយ ៖ សួង សាម

# ថ្ងៃទី០៤ ខែ សីហា ឆ្នាំ២០២៣

## កម្ពុជា-ថៃ ប្តេជ្ញាបន្តពង្រឹងកិច្ចសហប្រតិបត្តិការ លើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីប្រយោជន៍សេដ្ឋកិច្ចទៅវិញទៅមក

https://freshnewsasia.com/index.php/en/localnews/302804-2023-08-03-08-22-05.html 2023-08-03 03:22pm

**(ភ្នំពេញ)៖** ភាគីកម្ពុជា និងថៃ បានប្តេជ្ញាក្នុងការបន្តពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យកាន់តែល្អប្រសើរបន្ថែមទៀត សំដៅជានាដល់ប្រយោជន៍សេដ្ឋកិច្ចទៅវិញទៅមក។ ការបញ្ជាក់បែបនេះ បានធ្វើឡើងក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងាររវាងលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយលោក ឆឺតគៀត អាត់ថ:កន (Cherdkiat ATTHAKOR) ឯកអគ្គរាជទូតថៃប្រចាំកម្ពុជា នាព្រឹកថ្ងៃទី៣ ខែសីហា ឆ្នាំ២០២៣ នៅទីស្តីការក្រសួងការងារ។

នាឱកាសនោះ លោក អ៊ិត សំហេង បានវាយតម្លៃខ្ពស់ ចំពោះកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យរវាងភាគីកម្ពុជា និងភាគីថៃ ជាពិសេសភាគីទាំងពីរ បានខិតខំអនុវត្តបានយ៉ាងល្អ នូវអនុស្សរណៈយោគយល់គ្នាចំនួន៣ ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារ ការផ្លាស់ប្តូរកម្លាំងពលកម្ម និងការរួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលផ្អែកលើក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការនេះ

ជាអំណោយផលល្អដល់ការជំរុញកំណើនសេដ្ឋកិច្ច សង្គម វប្បធម៌ វិស័យអប់រំជាដើម គឺមានការផ្លាស់ប្ដូរបទពិសោធន៍គ្នាទៅវិញទៅមក បានយ៉ាងល្អប្រសើរ។ ការបើកឱកាសការងារជូនប្រជាពលរដ្ឋកម្ពុជាទៅធ្វើការនៅប្រទេសថៃ ពិតជាបានរួមចំណែកធ្វើឱ្យសេដ្ឋកិច្ចប្រទេសទាំងពីរទទួលបាននូវវឌ្ឍភាពជាច្រើន ហើយពលករកម្ពុជាក៏ទទួលបាននូវប្រាក់ចំណូល និងបទពិសោធន៍ការងាររួមទាំងជំនាញ ចំណេះដឹងផ្សេងៗផងដែរ។

លោករដ្ឋមន្ត្រីបានអំណរគុណចំពោះភាគីថៃ ដែលបានយកចិត្តទុកដាក់ដល់ការការពារសិទ្ធិ និងអត្ថប្រយោជន៍ស្របច្បាប់ជូនដល់ពលករកម្ពុជា ព្រមទាំងបានបង្កលក្ខណៈងាយស្រួលដល់ពួកគេក្នុងការស្នាក់នៅ និងបំពេញការងារនៅប្រទេសថៃ ដែលចាត់ទុកថាជានយោបាយឈ្នះ-ឈ្នះមួយរបស់ភាគីទាំង២ ក្នុងនោះពលករកម្ពុជាជាកម្លាំងបំពេញឱ្យតម្រូវការទីផ្សារការងាររបស់ថៃ ហើយពលករកម្ពុជាទទួលបានប្រាក់ចំណូលខ្ពស់ ទទួលបានជំនាញបន្ថែម និងជំរុញរំហូរហិរញ្ញវត្ថុចាក់បញ្ចូលក្នុងសេដ្ឋកិច្ចជាតិកម្ពុជាផងដែរ។ លោករដ្ឋមន្ត្រីបន្ថែមថា នៅក្នុងប្រទេសកម្ពុជាមិនខ្វះទេការងារដែលមានចំណូលសមរម្យដូចនៅប្រទេសថៃ ប៉ុន្តែដោយសារតែប្រជាពលរដ្ឋចង់ទៅធ្វើការនៅក្រៅប្រទេស ដូច្នេះរាជរដ្ឋាភិបាលកម្ពុជាក៏ផ្ដល់ជម្រើស និងជួយសម្របសម្រួលឱ្យពួកគេបានទៅធ្វើការនៅក្រៅប្រទេសដោយស្របច្បាប់។

ភាគីទាំងពីរ ក៏បានឯកភាពគ្នាផងដែរនឹងពិនិត្យមើលការលើកទឹកចិត្តឱ្យពលករកម្ពុជាប្រើប្រាស់ប្រព័ន្ធធនាគាក្នុងការផ្ញើប្រាក់ជូនក្រុមគ្រួសារនៅស្រុក ដើម្បីជួយកាត់បន្ថយនូវហានិភ័យនានា និងងាយស្រួលដល់ការគ្រប់គ្រងផងដែរ។ ចំពោះវិស័យបណ្ដុះបណ្ដាលវិជ្ជាជីវៈវិញ លោករដ្ឋមន្ត្រី អ៊ិត សំហេង បានថ្លែងអំណរគុណចំពោះភាគីថៃដែលជួយផ្ដល់អាហារូបករណ៍ទទួលនិស្សិតកម្ពុជាទៅសិក្សានៅប្រទេសថៃ ពិសេសគឺបានបង្កើតឱ្យមានវិទ្យាស្ថានមិត្តភាពអភិវឌ្ឍន៍ជំនាញកម្ពុជា-ថៃពូនភ្នំ សម្រាប់ផ្ដល់ការបណ្ដុះបណ្ដាលជំនាញដល់សិក្ខាកាមកម្ពុជាឱ្យមានចំណេះជំនាញក្នុងការប្រកបវិជ្ជាជីវៈ។

ភាគីកម្ពុជា បានដាក់សំណើររួចហើយទៅភាគីថៃ ស្នើសុំផ្ដល់នូវការបណ្ដុះបណ្ដាលលើមុខជំនាញចំនួន៦ រួមមាន៖ ១-ជំនាញវិស្វកម្មអេឡិចត្រូនិក ២-សំណង់ស៊ីវិល ៣-គ្រឿងយន្ត (Automotive) ៤-បរិក្ខារត្រជាក់ ៥-ព័ត៌មានវិទ្យា និង៦-វគ្គបណ្ដុះបណ្ដាលសម្រាប់បុគ្គលិកការិយាល័យ។ ភាគីកម្ពុជាសង្ឃឹមថា បន្ទាប់ពីទទួលបានសំណើនេះ ភាគីថៃនិងផ្ដល់ជូនវិទ្យាស្ថានមិត្តភាពអភិវឌ្ឍន៍ជំនាញកម្ពុជា-ថៃពូនភ្នំ តាមសំណើនេះនឹងបន្តទទួលបានកិច្ចសហប្រតិបត្តិការពីភាគីថៃលើការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈបន្តទៀត ហើយនឹងបង្កើតឱ្យមានកម្មវិធីរួមគ្នាជាច្រើនទៀតដូចការរៀបចំវេទិកាការងាររវាងកម្ពុជា-ថៃជាដើម៕

# ថ្ងៃទី០៧ ខែ សីហា ឆ្នាំ២០២៣

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ០២ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ០៧នាក់

https://freshnewsasia.com/index.php/en/localnews/303123-2023-08-04-10-41-07.html 2023-08-04 05:41pm

***(ភ្នំពេញ)៖*** *គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី០២ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០២ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ០៧នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន* Fresh News។ ***បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ រួមមាន៖***

***១៖*** *សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ១០២០ករណី មានមនុស្ស ២,៦២៣នាក់*

***២៖*** *បានស្រាវជ្រាវស៊ើបអង្កេតបឋម ៩៨២សំណើ និងបិទសំណុំរឿង ៣៣៨សំណើ (រកឃើញមនុស្ស ១,៥៣២នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣៧នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)*

***៣៖*** *កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣៨ករណី។*

## ពលរដ្ឋខ្មែរចំនួន៦នាក់ ក្នុងចំណោមជនអន្តោប្រវេសន៍ខុសច្បាប់ចំនួន៤២៥នាក់ ដែលស្នាក់នៅជុំគ្នាក្នុងអាផាតមិនក្នុងទីក្រុងគូឡាឡាំពួ

https://www.khmertimeskh.com/501337710//?p=1337710 August 6, 2023

*មន្ត្រីអន្តោប្រវេសន៍កាលពីថ្ងៃសៅរ៍បានប្រមូលផ្តុំជនអន្តោប្រវេសន៍ខុសច្បាប់ចំនួន ៤២៥នាក់ ដែលស្នាក់នៅជុំគ្នានៅក្នុងបន្ទប់ជាច្រើននៃប្លុកអាផាតមិនក្នុងក្រុង* Cheras *ដោយអ្នកខ្លះលាក់ខ្លួនក្នុងទូរ និងក្នុងធុងសំរាម។ ប្រធាននាយកដ្ឋានអន្តោប្រវេសន៍ទីក្រុងគូឡាឡាំពួ លោក* Syamsul Badrin Mohshin *បាននិយាយថា ការឆ្មក់ចូលក្នុងអគារ* Cheria Heights Apartments *ត្រូវបានអនុវត្តបន្ទាប់ពីការស៊ើបអង្កេត និងការឃ្លាំមើលអស់រយៈពេលពីរសប្តាហ៍ បន្ទាប់ពីមានបណ្តឹងពីសាធារណជនដែលបាននិយាយថា ជនបរទេសនៅក្នុងតំបន់នេះមានចំនួនច្រើនលើសលុប និងបង្កបញ្ហាសង្គមផ្សេងៗ។*

«ក្នុងប្រតិបត្តិការដែលធ្វើឡើងដោយមន្ត្រីអន្តោប្រវេសន៍ និងកម្លាំងចំនួន ៦០នាក់ ចាប់ផ្តើមពីម៉ោង ១ ទៀបភ្លឺ និងបញ្ចប់នៅម៉ោង ៤ ព្រឹកនេះ ដោយជនអន្តោប្រវេសន៍ខុសច្បាប់សរុបចំនួន ៤២៥ នាក់ត្រូវបានចាប់ខ្លួន ដោយសារមិនមានឯកសារអត្តសញ្ញាណត្រឹមត្រូវ ស្នាក់នៅ ឬប័ណ្ណការងារបណ្តោះអាសន្ន លើសកាលកំណត់ ព្រមទាំងមានអ្នកកាន់ប័ណ្ណដែលគ្មានការទទួលស្គាល់។

គាត់បាននិយាយនៅក្នុងសន្និសីទសារព័ត៌មានបន្ទាប់ពីប្រតិបត្តិការថា «អ្នកដែលត្រូវបានចាប់ខ្លួននោះ មានជនជាតិខ្មែរ (៦នាក់) បង់ក្លាដែស (២៥២នាក់) មីយ៉ាន់ម៉ា (១០៨នាក់) ហ្វីលីពីន (២នាក់) ឥណ្ឌូនេស៊ី (៣០នាក់) នេប៉ាល់ (២០) និងប៉ាគីស្ថាន (៧នាក់) ដែលពួកគេទាំងអស់មានអាយុចន្លោះពី ៨ ទៅ ៥២ឆ្នាំ មានបុរស ៣៧២នាក់ និងស្ត្រី៥៣នាក់"។ គាត់បានឱ្យដឹងថា ការស៊ើបអង្កេតបានរកឃើញថា ជនបរទេសដែលត្រូវបានចាប់ខ្លួននោះ ធ្វើការក្នុងវិស័យផ្សេងៗ រួមមានផ្នែកសំណង់ និងផ្នែកសម្អាត។

លោកបន្តថា ក្នុងប្រតិបត្តិការនោះ ជនបរទេសមួយចំនួនក៏បានធ្វើសកម្មភាពហឹង្សាដោយគប់វត្ថុផ្សេងៗ ដូចជាដបទឹក ដើម្បីគេចពីការចាប់ខ្លួន ប៉ុន្តែមិនមានអ្នករងរបួសនោះទេ។ លោក Syamsul Badrin បាននិយាយថា ក្រៅពីអ្នកដែលត្រូវបានចាប់ខ្លួន ក៏មានជនបរទេសដែលបានតាំងលំនៅក្នុងតំបន់នោះផងដែរ ក្នុងចំណោមពួកគេជនភៀសខ្លួនរ៉ូហ៊ីងយ៉ា ដែលកាន់ប័ណ្ណរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិសម្រាប់ជនភៀសខ្លួន (UNHCR) និងអ្នកដែលមានប័ណ្ណការងារត្រឹមត្រូវ។

"សម្រាប់ពលរដ្ឋមីយ៉ាន់ម៉ា ពួកគេមានប័ណ្ណដែលចេញដោយសមាគម ឬជនជាតិដើមភាគតិចរបស់ពួកគេ ប៉ុន្តែប័ណ្ណទាំងនោះមិនមានសុពលភាពសម្រាប់ការប្រើប្រាស់ និងមិនត្រូវបានទទួលស្គាល់ (នៅក្នុងប្រទេស)។ លោកបានបន្តថា៖ «ចំពោះអ្នកដែលមានតែប័ណ្ណទាំងនេះជាអត្តសញ្ញាណ ខាងអន្តោប្រវេសន៍នឹងឃាត់ខ្លួនពួកគេ»។ លោកបានបន្តថា អ្នកដែលត្រូវបានឃុំខ្លួនទាំងអស់ត្រូវបាននាំទៅកាន់ប៉ុស្តិ៍អន្តោប្រវេសន៍ Bukit Jalil ដើម្បីចាត់ការបន្ត ហើយករណីនេះកំពុងត្រូវបានស៊ើបអង្កេតតាមមាត្រា ១៥(១)(គ) និងផ្នែក ៦(១)(គ) នៃច្បាប់អន្តោប្រវេសន៍ឆ្នាំ ១៩៥៩/៦៣។

Bernama

# យល់ដឹងផ្នែកច្បាប់៖ បទល្មើសពាក់ព័ន្ធរូបភាព និងសម្ភារៈអាសអាភាស

https://plus.freshnewsasia.com/index.php/en/freshnewsplus/303381-2023-08-06-07-11-08.html

2023-08-06 02:11pm

**(ភ្នំពេញ)៖** *សកលលោកកាន់តែមានភាពរីកចម្រើន ប្រព័ន្ធបច្ចេកវិទ្យាក៏កាន់តែទំនើប ដែលបង្កលក្ខណៈងាយស្រួលដល់អ្នកប្រើប្រាស់នៅទូទាំងសកលលោក ដែលអាចដឹងអំពីព័ត៌មានទាំងអស់ដែលកើតមានប្រចាំថ្ងៃ មិនថានៅក្នុងប្រទេស ឬនៅទឹកដីក្រៅណានោះទេ គឺបច្ចេកវិទ្យាអាចបង្ហាញឱ្យដឹងតាមរយៈការចែករំលែកនូវសកម្មភាព រូបភាព ក៏ដូចជាបង្ហាញពីអារម្មណ៍នៅលើប្រព័ន្ធទំនាក់ទំនងសង្គមជាដើម។*

*មិនត្រឹមតែប៉ុណ្ណោះ យើងសង្កេតឃើញថា មានអ្នកប្រើប្រាស់មួយចំនួនធំបានទាញយកភាពជឿនលឿននៃប្រព័ន្ធបច្ចេកវិទ្យានេះ ទៅប្រើប្រាស់ក្នុងគោលបំណងវិជ្ជមាន ដើម្បីអាចបំពេញតម្រូវការរបស់អ្នកប្រើប្រាស់ដទៃទៀត ក៏ដូចជាចែករំលែកចំណេះដឹង និងបទពិសោធន៍ល្អៗ ទៅកាន់សកលលោកតាមរយៈភាពទំនើបនៃបច្ចេកវិទ្យានេះ។*

*ប៉ុន្តែមានមួយភាគតូច ដែលមានគំនិតអវិជ្ជមាន បានឆ្លៀតយកទំនើបកម្មនៃបច្ចេកវិទ្យានេះ ទៅប្រើប្រាស់ក្នុងផ្លូវមិនល្អ រហូតដល់មានការប្រកបអាជីវកម្ម ចែកចាយ និងឈានទៅរកការប្រព្រឹត្តបទល្មើសផ្សេងៗផងដែរ។ ជាងនេះទៅទៀត ក៏មានអ្នកប្រើប្រាស់ខ្លះទៀតមិនបានដឹងថា សកម្មភាពរបស់ខ្លួនដែលបង្ហាញតាមរយៈប្រព័ន្ធទំនាក់ទំនងសង្គមអាចបង្កទៅជាបទល្មើស ឬការចែករំលែកនូវសកម្មភាព រូបភាព សម្ភារៈដែលហាមឃាត់ផ្សេងៗ ដោយមិនដឹងថាអំពើទាំងនោះជាបទល្មើសនោះទេ។*

***ដើម្បីអាចយល់កាន់តែច្បាស់ ថាតើសកម្មភាពណាខ្លះដែលត្រូវបានហាមឃាត់ និងអាចឈានទៅមានបទល្មើសនោះ?***

*សប្តាហ៍នេះ កម្មវិធីយល់ដឹងផ្នែកច្បាប់របស់អង្គភាពសារព័ត៌មាន* Fresh News *សហការជាមួយ ក្រុមហ៊ុនមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ សូមលើកយកប្រធានបទស្តីពី* ***«បទល្មើសពាក់ព័ន្ធរូបភាព និងសម្ភារៈអាសអាភាស»*** *មកធ្វើការបង្ហាញជូនបងប្អូនប្រជាពលរដ្ឋ សិស្ស និស្សិតឱ្យបានជ្រាបកាន់តែច្បាស់។*

*នៅក្នុងប្រទេសដែលប្រកាន់យកនយោបាយប្រជាធិបតេយ្យ គឺផ្តល់នូវសិទ្ធិសេរីភាពពេញលេញដល់ប្រជាជនរបស់គេ មិនខុសគ្នានឹងប្រទេសកម្ពុជានោះទេ គឺប្រជាពលរដ្ឋមានសិទ្ធិសេរីភាព ប៉ុន្តែសិទ្ធិសេរីភាពទាំងនោះមិនត្រូវធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ កេរ្តិ៍ឈ្មោះ កិត្តិយស សកម្មភាពរបស់អ្នកដទៃនោះទេ ។ ជាងនេះទៅទៀត កម្ពុជាក៏មិនបានហាមឃាត់ក្នុងការប្រើប្រាស់ប្រព័ន្ធទំនាក់ទំនង*

សង្គមផ្សេងៗនោះដែរ ពោលគឺប្រជាជនមានសិទ្ធិសេរីភាពក្នុងការបង្ហាញ បញ្ចេញមតិ ផ្សព្វផ្សាយ ចែករំលែក នូវសកម្មភាពផ្សេងៗដែលកើតមាននៅក្នុងសង្គមជាក់ស្តែង។

ប៉ុន្តែយើងសង្កេតឃើញថាមានប្រជាជនមួយភាគតូច ដែលមានចេតនាក្នុងការប្រើប្រាស់ប្រព័ន្ធទំនាក់ទំនងសង្គម ក៏ដូចជាប្រព័ន្ធផ្សេងៗទៅប្រព្រឹត្តអំពើដែលច្បាប់ហាមឃាត់ដូចជា៖ ការចែកចាយរូបភាពអាសអាភាស ការលក់ផលិតផលសម្ភារៈអាសអាភាស (លិង្គសិប្បនិម្មិត ប្រដាប់រួមភេទសិប្បនិម្មិត ឧបករណ៍ជំនួយដល់ការរួមភេទ...) ការបង្កើតក្រុមដើម្បីចែករំលែករូបភាព ឬវីដេអូអាសអាភាស ការផ្សព្វផ្សាយលក់វីដេអូ និងរូបភាពអាសអាភាស ការបន្តផ្ទាល់ (Live) ក្នុងគោលបំណងអាជីវកម្មផ្លូវភេទ ការថតសកម្មភាព ឬវីដេអូដែលធ្វើឱ្យរំជួលដល់ចំណង់ផ្លូវភេទ បង្ហោះតាមប្រព័ន្ធទំនាក់ទំនងសង្គម ជាដើម ។ល។ មាត្រា ៣៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានឱ្យនិយមន័យ នៃរូបភាព និងសម្ភារៈអាសអាភាស ថា៖ រូបភាព និងសម្ភារៈអាសអាភាស គឺជាសម្ភារៈដែលអាចមើលឃើញនឹងភ្នែកដូចជា រូបថត ខ្សែវីដេអូ រួមទាំងសម្ភារៈអេឡិចត្រូនិច ដែលពិពណ៌នាអំពីកេរភេទ ឬភាពអាសអាភាស ប្រហាក់ប្រហែលផ្សេងទៀតដែលធ្វើឱ្យរំភើប ឬរំជួលដល់ចំណង់ផ្លូវភេទ។

ដូចនេះ ចំពោះជនណាដែលចែកចាយ កាន់កាប់ លក់ ជួល ដឹកជញ្ជូន នាំចូល នាំចេញ ដាក់តាំង បញ្ចាំង ឬបង្ហាញនៅទីសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ថ្ងៃ ដល់ ១ (មួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ដល់ ២០០.០០០ (ពីរសែន) រៀល (ស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ)។

មិនត្រឹមតែប៉ុណ្ណោះ រាល់សកម្មភាព សម្ភារៈអាសអាភាស ឬបទល្មើសពាក់ព័ន្ធនឹងកុមារ គឺត្រូវបានហាមឃាត់ជាដាច់ខាត និងមានការដាក់ទណ្ឌកម្មធ្ងន់ធ្ងរជាង ពោលគឺ ជនណាដែលចែកចាយ កាន់កាប់ លក់ ជួល ដឹកជញ្ជូន នាំចូល នាំចេញ ដាក់តាំង បញ្ចាំង ឬបង្ហាញនៅទីសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល ។

ជនណាផលិតរូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ បន្ថែមពីនេះប្រសិនបើមានករណីយករូបភាព និងសម្ភារៈអាសអាភាសទាំងនោះក្នុងគោលដៅយកទៅប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើសណាមួយ គឺត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ (មាត្រា ៤១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ)។ ដោយសង្កេតឃើញថា អ្នកប្រើប្រាស់បណ្តាញសង្គមនៅកម្ពុជាមួយចំនួនតូចមានចេតនាក្នុងការផលិត ចែកចាយបន្ត ដាក់បង្ហាញ និងធ្វើអាជីវកម្ម លើរូបថត ខ្សែវីដេអូ

ក៏ដូចជាសម្ភារៈអាសអាភាស ជាសាធារណៈនៅតាមប្រព័ន្ធបណ្តាញសង្គមផ្សេងៗជាហេតុនាំឱ្យការប្រព្រឹត្តបទល្មើសមានចំនួនកើនឡើង។

សរុបជារួមមក កម្ពុជាមិនបានហាមប្រាមសិទ្ធិក្នុងការផ្សព្វផ្សាយ ការចែកចាយ ការបង្ហាញ ការប្រកបអាជីវកម្មនោះទេ តែរាល់សកម្មភាពទាំងនោះត្រូវតែស្របតាមច្បាប់កំណត់ ទោះបីជាសកម្មភាពមួយចំនួនជាសិទ្ធិសេរីភាពរបស់អ្នកប្រើប្រាស់ក៏ពិតមែន ប៉ុន្តែត្រូវប្រាកដថា សកម្មភាពទាំងនោះមិនត្រូវបានហាមឃាត់ដោយច្បាប់ផ្សេងៗ ឬសកម្មភាពខ្លះអាចជំរុញឱ្យមានបទល្មើសក៏ថាបាន។ ដើម្បីចៀសវាងចំពោះសកម្មភាពល្មើសណាមួយកើតឡើង គប្បីឈ្វេងយល់ឱ្យបានច្បាស់លាស់ មុននឹងធ្វើការផ្សព្វផ្សាយជាសាធារណៈ ចែករំលែក ឬផ្សព្វផ្សាយបន្ត ទោះជាយើងបានឃើញអំពើទាំងនោះពីអ្នកដទៃក៏ដោយ គួរណាកុំចែកចាយ ឬណែនាំទៅអ្នកផ្សេង ឬផ្សព្វផ្សាយបន្តជាសាធារណៈជាដាច់ខាត។

រៀបរៀងដោយ៖ លោកស្រីមេធាវី នូ ពិសី និងលោក ហេង សុគន្ធ ជាសមាជិកក្រុមការងាររៀបចំ និងផ្សព្វផ្សាយអត្ថបទច្បាប់នៃក្រុមហ៊ុនមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ មានអាសយដ្ឋាននៅអគារស៊ីអាយស៊ី (CIC) លេខ ១២៦៩ ផ្លូវលំ ស្ថិតក្នុងភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរស័ព្ទទំនាក់ទំនងលេខ ០២៣ ៩៨៦ ២៤៩ អ៊ីម៉ែល៖ president@ciclf.com, គេហទំព័រ៖ www.ciclf.com, ហ្វេសបុកផេក៖ Cambodia International Cooperation Law Firm៕

# ថ្ងៃទី០៩ ខែ សីហា ឆ្នាំ២០២៣

## ជនជាតិឥណ្ឌូណេស៊ី ០៩ នាក់ មិនពេញចិត្តនឹងការងារ ប្រឌិតរឿងត្រូវគេបង្ខាំង និងបង្ខំឲ្យធ្វើការ

https://www.kampucheathmey.com/security/554609 ថ្ងៃចន្ទ ៧ សីហា ២០២៣ដោយ Inn Pisey

ជនជាតិឥណ្ឌូណេស៊ី ០៩ នាក់ មិនបានរងគ្រោះដោយអំពើបង្ខាំង និងបង្ខំឲ្យធ្វើការនៅទីតាំងក្រុមហ៊ុនមួយកន្លែង ភូមិសាស្ត្រខេត្តស្វាយរៀងនោះទេ ហើយមូលហេតុពួកគេផ្តល់ព័ត៌មានទៅស្ថានទូតឥណ្ឌូណេស៊ី ដោយសារមិនពេញចិត្តការងារ ទើបប្រឌិតរឿង ផ្តល់ព័ត៌មានមិនពិត។ នេះបើយោងតាមសេចក្តីប្រកាសព័ត៌មានរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

សេចក្តីប្រកាសព័ត៌មាន របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានឲ្យដឹងថា ក្រុមប្រតិបត្តិការស៊ើបអង្កេតស្រាវជ្រាវបណ្តាញនាំមនុស្សឆ្លងដែនខុសច្បាប់ នៃអគ្គស្នងការដ្ឋាន នគរបាលជាតិ សូមជម្រាបជូនដល់សាធារណជនអំពីលទ្ធផលប្រតិបត្តិការស្វែងរកជន

បរទេស ដែលបានស្នើសុំអន្តរាគមន៍តាមរយៈទំព័រហ្វេសប៊ុក សម្ដេចក្រឡាហោម (ករណីលេខ ៩៥៣)។

សេចក្ដីប្រកាសព័ត៌មាន បានបន្តថា នៅថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០២៣ ក្រុមប្រតិបត្តិការទទួលបានកំណត់ទូតពីស្ថានទូតឥណ្ឌូណេស៊ី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ស្នើសុំអន្តរាគមន៍ជួយសង្គ្រោះប្រជាពលរដ្ឋរបស់ខ្លួនចំនួន ០៩ នាក់ លើករណីបង្ខាំងមនុស្ស និងបង្ខំឲ្យធ្វើការ នៅទីតាំងក្រុមហ៊ុនមួយកន្លែង ស្ថិតក្នុងភូមិសាស្ត្រខេត្តស្វាយរៀង។ ក្រោយពីទទួលបានសំណើសុំអន្តរាគមន៍ នៅថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០២៣ សមត្ថកិច្ចជំនាញ នៃស្នងការដ្ឋាន នគរបាលខេត្តស្វាយរៀង បានរកឃើញជនជាតិឥណ្ឌូណេស៊ីទាំង ០៩ នាក់ កំពុងស្នាក់នៅ និងធ្វើការនៅក្នុងក្រុមហ៊ុនមួយកន្លែង ស្ថិតនៅភូមិបាវិតកណ្ដាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង និងបានអញ្ជើញមកធ្វើការសាកសួរនៅស្នងការដ្ឋាននគរបាលខេត្ត។

ជាមួយគ្នានេះ ផ្អែកតាមការបំភ្លឺរបស់ជនជាតិឥណ្ឌូណេស៊ីទាំង ០៩ នាក់ ខាងលើ និងពិនិត្យលើស្ថានភាពទីតាំងជាក់ស្ដែងឃើញថា ពួកគេទាំង ០៩ នាក់ មិនត្រូវបានរងគ្រោះដោយអំពើបង្ខាំងនៅក្នុងទីតាំង និងបង្ខំឲ្យធ្វើការនោះទេ។ ផ្ទុយទៅវិញ មូលហេតុដែលពួកគេផ្ដល់ព័ត៌មានទៅស្ថានទូត ដើម្បីប្ដឹងសុំអន្តរាគមន៍ ព្រោះពួកគេមិនពេញចិត្តនឹងការងារ ហើយមិនអាចសុំក្រុមហ៊ុនឈប់បាន ដោយសារជាប់កិច្ចសន្យាការងារ រយៈពេល ០៨ ខែ ហេតុដូច្នេះទើបប្រឌិតរឿង និងផ្ដល់ព័ត៌មានមិនពិតទៅស្ថានទូតឥណ្ឌូណេស៊ីថា ពួកគេត្រូវបានរងគ្រោះដោយអំពើបង្ខាំង និងបង្ខំឲ្យធ្វើការ។

បច្ចុប្បន្ន សមត្ថកិច្ច បានបញ្ជូនជនជាតិឥណ្ឌូណេស៊ីទាំង ០៩ នាក់ ខាងលើ ទៅកាន់មណ្ឌលត្រៀមបណ្ដេញចេញ នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីអនុវត្តនីតិវិធីធ្វើមាតុភូមិនិវត្តន៍៕ ពិសី

## នគរបាលជាតិ
## ជំរុញភ្នាក់ងារសន្តិសុខឯកជនអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព

https://www.khmertimeskh.com/501339358// ហង្ស ពណ្ណរាយ / Khmer Times August 9, 2023

អគ្គស្នងការដ្ឋាននគរបាលជាតិ ជំរុញដល់ភ្នាក់ងារសន្តិសុខវិស័យឯកជន ចូលរួមអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ដើម្បីទប់ស្កាត់ បង្ការ និងបង្ក្រាបបទល្មើស នៅតាមមូលដ្ឋាននានាទូទាំងប្រទេស។

ក្នុងពិធីបើកវគ្គបំប៉នជំនាញភ្នាក់ងារសន្តិសុខឯកជន លើកទី៥១ លោក លឹម សុខាស្មី ប្រធាននាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ កាលពីម្សិលមិញ បានថ្លែងថា ការចូលរួមអនុវត្តគោលនយោបាយ ភូមិ-ឃុំសង្កាត់ មានសុវត្ថិភាព គឺមានសារៈសំខាន់

សម្រាប់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ដែលផ្តល់សុវត្ថិភាព ជាពិសេសជានាគ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន និងល្បែងស៊ីសងខុសច្បាប់។ លោកបន្ថែមថា៖ «ការចូលរួមអនុវត្តគោលនយោបាយ ភូមិ-ឃុំសង្កាត់ មានសុវត្ថិភាព គឺផ្តើមចេញពីគ្រប់វិស័យ ជាពិសេសភ្នាក់ងារសន្តិសុខឯកជន ដែលជាកម្លាំងជំនួយដល់កងកម្លាំងមានសមត្ថកិច្ច ដែលនៅឈរជើងជាប់ជាប្រចាំតាមបណ្តាគោលដៅនានា ក្នុង២៤ម៉ោង លើ២៤ម៉ោង»។

លោកបានបន្តអំពាវនាវដល់កម្លាំងភ្នាក់ងារសន្តិសុខឯកជនទាំងអស់ ត្រូវអនុវត្តគោលនយោបាយ ភូមិ-ឃុំសង្កាត់ មានសុវត្ថិភាព នៅទូទាំងប្រទេសឱ្យមានប្រសិទ្ធភាពខ្ពស់។ ប្រធាននាយកដ្ឋានបញ្ជាក់ថា សម្រាប់វគ្គបំប៉នជំនាញខាងលើនេះ ភ្នាក់ងារសន្តិសុខវិស័យឯកជន គឺទទួលបានចំណេះដឹងពាក់ព័ន្ធនឹងបញ្ហាប្រឈមជាប្រចាំថ្ងៃក្នុងការអនុវត្តការងារ។ ក្នុងនោះមានដូចជា តួនាទី និងការទទួលខុសត្រូវរបស់ភ្នាក់ងារសន្តិសុខឯកជន និងវិធីសាស្ត្រការពារគោលដៅ។ លោកបន្ថែមថា ភ្នាក់ងារសន្តិសុខ ក៏ទទួលបានការបណ្តុះបណ្តាលស្តីពី ច្បាប់ចរាចរណ៍ផ្លូវគោក របៀបផ្តល់ជំនួយ និងសហការជាមួយសមត្ថកិច្ច ការស្វែងយល់អំពីក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ វិធានការបង្ការពន្លត់អគ្គីភ័យ និងការជម្លៀសខ្លួនចេញពីអគ្គីភ័យ ព្រមទាំងកិច្ចសហការការពារកន្លែងកើតហេតុ ជាដើម។

លោក តុង កក្តិ ប្រធានផ្នែកសុវត្ថិភាពសាលា និងសាធារណៈ នៃក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ប្រាប់កាសែតខ្មែរថាមស៍ កាលពីម្សិលមិញថា បច្ចុប្បន្ន វិស័យសន្តិសុខឯកជន បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សាសុវត្ថិភាពជូនសារធាណជននៅតាមទីសាធារណៈ មានដូចជា សាលារៀន ផ្សារទំនើប ភោជនីយដ្ឋាន និងហាងលក់ទំនេញ ជាដើម។ លោកបញ្ជាក់ថា៖ «ពួកគាត់ជាឆ្មាំ ដែលនៅប្រចាំការផ្ទាល់នៅហ្នឹងកន្លែង ហើយជាអ្នកដោះស្រាយបញ្ហាសុវត្ថិភាពភ្លាមៗ មុនពេលសមត្ថកិច្ចមកដល់។ អាជីកម្មមួយដែលមានសន្តិសុខ ធ្វើឱ្យអាជីកម្មនោះ កាន់តែមានទំនុកចិត្តពីអតិថិជន»។

លោក តុង កក្តិ បន្តថា សម្រាប់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន គឺមានសន្តិសុខ ដែលមានជំនាញច្បាស់លាស់ មានវិន័យ និងក្រមសីលធម៌ ដោយពួកគេយកចិត្តទុកដាក់ខ្ពស់លើសុវត្ថិភាពសិស្សានុសិស្ស អាណាព្យាបាលសិស្ស លោកគ្រូ អ្នកគ្រូ និងបុគ្គលិក ដោយប្រកាន់ខ្ជាប់នូវគុណភាព វិន័យ និងសេវាកម្ម។ លោកថា លើសពីការងារសុវត្ថិភាពសម្រាប់វិស័យសាធារណៈ និងវិស័យឯកជន សន្តិសុខ ក៏ជាអ្នកផ្តល់សេវាកម្មជួរមុខ ដែលផ្តល់ភាពកក់ក្តៅ និងទទួលរាក់ទាក់អតិថិជន ដែលមកទទួលសេវាកម្មផងដែរ។

កាលពីខែកក្កដា ឧត្តមសេនីយ៍ឯក អ៊ី សុខឃី អគ្គស្នងការរងនគរបាលជាតិ បានណែនាំក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន សហគ្រាស និងគ្រឹះស្ថាន ឱ្យបញ្ជូនភ្នាក់ងាររបស់ខ្លួនចូលរួមវគ្គបណ្តុះបណ្តាលពីនាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជន ដើម្បីអភិវឌ្ឍសមត្ថភាព ចំណេះ និងជំនាញពាក់ព័ន្ធ កាន់តែច្បាស់លាស់ និងទទួលបានការគាំទ្រពីអបិតិជន។ លោកបន្ថែមថា ក្រុមហ៊ុនសន្តិសុខវិស័យឯកជន ត្រូវពង្រឹងអាកប្បកិរិយា ក្របសីលធម៌ សម្លៀកបំពាក់ និងត្រូវគោរពឱ្យបាននូវលិខិតបទដ្ឋាន គតិយុត្តដែលមានចែងជាធរមាន។ លើសពីនេះ មិនត្រូវរាំងរាំងដល់កិច្ចប្រតិបត្តិការរបស់កម្លាំងអាជ្ញាធរមានសមត្ថកិច្ច ពិសេសស្ថាប័នតុលាការជាដើម ផ្ទុយទៅវិញត្រូវផ្តល់កិច្ចសហការឲ្យបានល្អ។

# ថ្ងៃទី១០ ខែ សីហា ឆ្នាំ២០២៣

## នគរបាលឥណ្ឌូណេស៊ីស្វែងរកព័ត៌មានបន្ថែមពីនគរបាលអន្តរជាតិស្តីពីជនសង្ស័យម្នាក់ ដែលជាប់ពាក់ព័ន្ធនៅនឹងការជួញដូរក្រលៀនខុសច្បាប់

https://www.khmertimeskh.com/501340458// Khmer Times August 10, 2023

នគរបាលឥណ្ឌូណេស៊ីបានស្វែងរកព័ត៌មានបន្ថែមពីនគរបាលអន្តរជាតិស្តីពីជនសង្ស័យម្នាក់ដែលជាប់ពាក់ព័ន្ធទៅនឹងការជួញដូរក្រលៀនខុសច្បាប់ ដែលត្រូវបានគេជឿថា ជាសមាជិកនៃក្រុមជួញដូរខុសច្បាប់។

លោក Hengki Haryadi ស្នងការជាន់ខ្ពស់នៃទីក្រុង Jakarta Metro បាននិយាយថា "យើងកំពុងស្វែងរកស្វែងរកព័ត៌មានបន្ថែមពីនគរបាលអន្តរជាតិ ស្តីពីជនសង្ស័យម្នាក់ ដែលត្រូវបានគេស្គាល់ថា Huang" ។ បើតាមលោក Haryadi ជនសង្ស័យមានតួនាទីសំខាន់ ក្នុងការរៀបចំការប្តូរក្រលៀននៅកម្ពុជា។ នគរបាលឥណ្ឌូណេស៊ីកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរកម្ពុជា ដើម្បីតាមចាប់ Huang ។ លោកបានបន្តថា៖ «យើងកំពុងសម្របសម្រួលយ៉ាងសកម្មជាមួយនគរបាលឥណ្ឌូនេស៊ី និងអនុព័ន្ធការពារជាតិកម្ពុជា។

នគរបាលក្រុង Jakarta Metro បានស្រាវជ្រាវនិងដឹងពីតួនាទីរបស់ជនសង្ស័យចំនួន១២ នាក់នៅក្នុងក្រុមជួញដូរក្រលៀន ដែលបានធ្វើសកម្មភាពពីសង្កាត់ Tarumajaya ស្រុក Bekasi ភាគខាងលិច Java ។ ជនសង្ស័យ ដែលត្រូវបានគេជឿថា ជាសមាជិក នៃក្រុមជួញដូរសរីរាង្គខុសច្បាប់បានបោកបញ្ឆោតជនជាតិឥណ្ឌូនេស៊ីយ៉ាងហោចណាស់១២២នាក់ឱ្យលក់ក្រលៀនរបស់ពួកគេទៅអោយក្រុមជួញដូរខុសច្បាប់នៅកម្ពុជា។

លោក Karyoto អធិការនគរបាលក្រុង Jakarta បាននិយាយថា៖ «ក្នុងករណីនេះ មានមនុស្ស ១២ នាក់ត្រូវបានជាប់ចោទជាជនសង្ស័យ។ ទន្ទឹមនឹងនេះដែរ លោក Haryadi បាននិយាយថា ជនសង្ស័យចំនួន១០ នាក់ជាសមាជិករបស់ក្រុមជួញដូរខុសច្បាប់អន្តរជាតិ ហើយ៩នាក់ក្នុងចំណោមពួកគេ គឺជាអតីតអ្នកផ្តល់ក្រលៀន ដោយក្រោយមកបានពួកគេក្លាយជាអ្នកជ្រើសរើសមនុស្សផ្សេងទៀត។ លោកបានបន្ថែមថា៖ «សម្រាប់មនុស្សពីរនាក់ដែលមិនមែនជាសមាជិកនៃក្រុមជួញដូរនោះ គឺជានគរបាល និងមន្ត្រីអន្តោប្រវេសន៍»។

លោកបានអោយដឹងទៀតថា ជនរងគ្រោះបានយល់ព្រមលក់ក្រលៀនរបស់ពួកគេ ដោយសារតែជីវភាពក្រីក្របន្ទាប់ពីជំងឺរាតត្បាត COVID-19។ លោកបានបន្តថា៖ «ជនរងគ្រោះមានអាជីពដូចជា គ្រូបង្រៀន កម្មករ និងសន្តិសុខ អ្នកខ្លះក៏មានសញ្ញាបត្រអនុបណ្ឌិត ផងដែរ»។ ទន្ទឹមនឹងនេះ សភាប្រឹក្សាប្រជាជន (MPR) បានជំរុញឱ្យរដ្ឋាភិបាល និងនគរបាលការពារជនរងគ្រោះដែលពាក់ព័ន្ធក្នុងការជួញដូរក្រលៀនខុសច្បាប់អោយបានល្អបំផុត។

លោក Bambang Soesatyo ប្រធាន MPR បាននិយាយនៅក្នុងសេចក្តីប្រកាសព័ត៌មានមួយកាលពីខែកក្កដាថា "រដ្ឋាភិបាល និងនគរបាលត្រូវតែការពារជនរងគ្រោះដែលពាក់ព័ន្ធក្នុងការជួញដូរក្រលៀនខុសច្បាប់អោយបានល្អបំផុតរហូតដល់ជនរងគ្រោះជាសះស្បើយពេញលេញ" ។ *Antara News*

# ថ្ងៃទី១១ ខែ សីហា ឆ្នាំ២០២៣

## សមត្ថកិច្ចកម្ពុជា បន្តទទួលបានបណ្តឹង ០៤ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ០៨នាក់

https://freshnewsasia.com/index.php/en/localnews/304494-2023-08-10-03-17-50.html ***2023-08-10 10:17am***

(ភ្នំពេញ)៖ គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី០៨ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០២ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ០៨នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៣ រួមមាន៖

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ១,០៣៦ករណី មានមនុស្ស ២,៦៤៩នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៩៨៩សំណើ និងបិទសំណុំរឿង ៣៣៨សំណើ (រកឃើញមនុស្ស ១,៥៤១នាក់, ឃាត់ខ្លួនជនសង្ស័យ ១៣៧នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៤៧ករណី។

# ថ្ងៃទី១៤ ខែ សីហា ឆ្នាំ២០២៣

## ស្ថានទូតឥណ្ឌូនេស៊ី នៅទីក្រុងភ្នំពេញ ធ្វើមាតុភូមិនិវត្តន៍ ជនជាតិឥណ្ឌូនេស៊ី ៤១នាក់ ពីក្រុមហ៊ុនបោកប្រាស់ តាមប្រព័ន្ធអនឡាញ នៅកម្ពុជា

https://www.khmertimeskh.com/501339426/indonesian-embassy-in-phnom-penh-repatriates-41-indonesians-from-online-scam-company-in-cambodia/ ខ្មែរថាមស៍ថ្ងៃទី 9 ខែសីហា ឆ្នាំ 2023

ស្ថានទូតឥណ្ឌូនេស៊ី រាជធានីភ្នំពេញ ស្ថានទូតឥណ្ឌូនេស៊ី (KBRI) បានធ្វើមាតុភូមិនិវត្តន៍ដោយជោគជ័យនូវជនជាតិឥណ្ឌូនេស៊ីចំនួន 41 នាក់ ដែលជាជនរងគ្រោះនៃក្រុមហ៊ុនបោកប្រាស់តាមអ៊ីនធឺណិតនៅក្នុងទីក្រុងជាច្រើនក្នុងប្រទេសកម្ពុជា (5/8) រួមទាំង Steven និងមិត្តភក្តិដែលបានទាក់ទងទៅកាន់ប្រធានាធិបតី Joko Widodo តាមរយៈការអំពាវនាវជាវីដេអូ។ ជនជាតិឥណ្ឌូណេស៊ីទាំង 41 នាក់ត្រូវបានត្រឡប់ទៅប្រទេសកំណើតរបស់ពួកគេវិញនៅក្នុងក្រុមចំនួន 4 ដាច់ដោយឡែកពីគ្នាចាប់ពីថ្ងៃទី 22 ខែកក្កដាដល់ថ្ងៃទី 5 ខែសីហា ឆ្នាំ 2023។ ដំណើរការនេះមានលក្ខណៈបន្តិចម្តងៗ ដោយសារតែដំណើរការអនុញ្ញាត និងការដោះស្រាយករណីផ្សេងៗគ្នាសម្រាប់មនុស្សគ្រប់រូប។ ដំណើរការនេះស្ថិតនៅក្រោមក្រសួងមហាផ្ទៃកម្ពុជា។

ចាប់ពីថ្ងៃទី 5 ខែមិថុនា ដល់ថ្ងៃទី 14 ខែមិថុនា ឆ្នាំ 2023 នគរបាលជាតិកម្ពុជា (CNP) បានជួយសង្គ្រោះជនរងគ្រោះចំនួន 41 នាក់ ពីក្រុមហ៊ុនឆបោកតាមប្រព័ន្ធអ៊ីនធឺណេត មកពីខេត្តនានារួមមានខេត្តបន្ទាយមានជ័យ (ព្រំដែនកម្ពុជា-ថៃ) ស្វាយរៀង (ព្រំដែនកម្ពុជា-វៀតណាម) និងរាជធានីភ្នំពេញ។ ប្រតិបត្តិការ ជួយ សង្គ្រោះ នេះ ត្រូវ បាន ធ្វើ ឡើង ដោយ ផ្អែក លើ ព័ត៌មាន ពី ស្ថានទូត ឥណ្ឌូនេស៊ី ប្រចាំ រាជធានី ភ្នំពេញ។ ស្ថានទូត បាន បញ្ជូន ព័ត៌មាន នេះ ទៅ ភាគី ពាក់ព័ន្ធ ក្នុងប្រទេស កម្ពុជា តាមរយៈ បណ្តាញ ការទូត ផ្លូវការ និង មធ្យោបាយ ក្រៅផ្លូវការ។ បន្ទាប់ មក ជនជាតិ ឥណ្ឌូនេស៊ី ទាំង ៤១ នាក់ បានឆ្លងកាត់ដំណើរការ នៃការផ្តល់សុពលភាព របាយការណ៍ និងការសម្ភាសន៍ អន្តោប្រវេសន៍ ពីភាគីពាក់ព័ន្ធក្នុងប្រទេស កម្ពុជា CNP និង អគ្គនាយកដ្ឋាន អន្តោប្រវេសន៍ កម្ពុជា (GDI) មាន សិទ្ធិ អំណាច ពេញលេញ លើ ដំណើរការ នៅ កម្ពុជា។ ក្នុងដំណើរការ

នេះ CNP និង GDI Cambodia នៅតែផ្តល់ឱកាសដល់ស្ថានទូតឥណ្ឌូនេស៊ីប្រចាំនៅទីក្រុងភ្នំពេញ ដើម្បីជួប និងពិគ្រោះជាមួយពលរដ្ឋឥណ្ឌូនេស៊ី ដើម្បីធានាបាននូវសុខភាព និងសន្តិសុខរហូតដល់ពួកគេត្រលប់មកវិញ។

អ្នកជ្រើសរើសបុគ្គលិកនៅក្នុងប្រទេសឥណ្ឌូនេស៊ីបានសន្យា ជាមួយប្រជាជនឥណ្ឌូនេស៊ីជាច្រើនថា ពួកគេនឹងត្រូវបានជួលជាបុគ្គលិកផ្នែកសេវាកម្ម Call Center នៅបរទេស និងទទួលបានប្រាក់ខែដ៏សប្បុរស។ ទោះជាយ៉ាងណាក៏ដោយ ជំនួសឱ្យការបំពេញការសន្យាទាំងនេះ ពួកគេត្រូវបានគេប្រើប្រាស់ជាអ្នកបោកប្រាស់ ដើម្បីប្រព្រឹត្តិគម្រោងការក្លែងបន្លំផ្សេងៗប្រឆាំងនឹងប្រជាជននៅក្នុងប្រទេសឥណ្ឌូនេស៊ី។ ប្រាក់ខែរបស់ពួកគេច្រើនតែមានចាប់ពី 500 ដុល្លារក្នុងមួយខែ។

## កម្ពុជា និងឥណ្ឌូណេស៊ី
## បានពិភាក្សាគ្នាអំពីកិច្ចសហប្រតិបត្តិការ ដើម្បីលុបបំបាត់ការជួញដូរមនុស្ស

https://www.khmertimeskh.com/1341550// August 12, 2023

កម្ពុជា និងប្រទេសឥណ្ឌូនេស៊ី បានប្តេជ្ញាសហការលុបបំបាត់ការជួញដូរមនុស្សនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់អគ្គនាយកអន្តោប្រវេសន៍ និងប្រធានកុងស៊ុលអាស៊ានលើកទី២៦(DGICM)ដែលបានប្រព្រឹត្តិទៅចាប់ពីថ្ងៃទី៨-១១ ខែសីហា នៅទីក្រុងភូកេត ប្រទេសថៃ។ នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំខាងលើ លោក Silmy Karim អគ្គនាយកអន្តោប្រវេសន៍នៃក្រសួងច្បាប់ និងសិទ្ធិមនុស្សរបស់ប្រទេសឥណ្ឌូនេស៊ី បានជួបពិភាក្សាការងារជាមួយឯកឧត្តម នាយឧត្តមសេនីយ៍ គៀត ច័ន្ទថារិទ្ធ អគ្គនាយកអន្តោប្រវេសន៍កម្ពុជា។

លោក Silmy Karim បាននិយាយនៅក្នុងសេចក្តីប្រកាសព័ត៌មួយនៅថ្ងៃសុក្រថា "ក្នុងអំឡុងពេលនៃជំនួបពិភាក្សាខ្ញុំបានលើកឡើងថាមានប្រជាជនឥណ្ឌូនេស៊ីជាច្រើនបានក្លាយជាជនរងគ្រោះនៃល្បែងអនឡាញ ការក្លែងបន្លំតាមអ៊ីនធឺណិត និងការជួញដូរគ្រឿងញៀន"។

គណៈប្រតិភូកម្ពុជាបានជម្រាបជូនលោក Silmy Karim ថា អាជីវកម្មល្បែងអនឡាញធ្លាប់ប្រព្រឹត្តិទៅដោយស្របច្បាប់នៅកម្ពុជា។ ប៉ុន្តែចាប់តាំងពីខែមិថុនា ឆ្នាំ២០១៩ មក អាជ្ញាប័ណ្ណសម្រាប់ប្រតិបត្តិការល្បែងស៊ីសង និងល្បែងអនឡាញត្រូវបានប្រកាសថាខុសច្បាប់។

លោក Silmy Karim បានបន្តថា "នៅឆ្នាំ២០២២ អាជ្ញាធរមូលដ្ឋានបានចុះបង្ក្រាបនៅទីតាំងមួយក្នុងខេត្តព្រះសីហនុ ដែលត្រូវបានគេសង្ស័យថាជាកន្លែងល្បែងស៊ីសង។មានមនុស្សជាង២០០នាក់ត្រូវបានចាប់ខ្លួន ហើយពួកគេភាគច្រើនមកពីប្រទេសឥណ្ឌូនេស៊ី"។ លោកបានអោយដឹងទៀតថា បន្ទាប់ពីការបង្ក្រាបនេះ ជនជាតិឥណ្ឌូនេស៊ីដែលជាជនរងគ្រោះត្រូវបានការពារដោយស្ថានទូតឥណ្ឌូនេស៊ីនៅទីក្រុងភ្នំពេញ។ លោកបានបន្តថា៖ «ជនរងគ្រោះត្រូវបានអោយស្នាក់នៅបណ្តោះ

អាសន្ននៅទីតាំងដែលផ្តល់ជូន ចំណែកអ្នកដែលមិនមែនជាជនរងគ្រោះត្រូវបានដាក់ក្នុងបន្ទប់ឃុំឃាំងអន្តោប្រវេសន៍កម្ពុជា។ លោកបាននិយាយទៀតថាករណីជួញដូរក្រលៀនជាព័ត៌មានថ្មីដែលរដ្ឋាភិបាលកម្ពុជាទើបនឹងទទួលបាន។ ទន្ទឹមនឹងនេះ សម្រាប់រដ្ឋាភិបាលឥណ្ឌូនេស៊ី ការិយាល័យរបស់លោកបានអំពាវនាវដល់មន្ត្រីអន្តោប្រវេសន៍ ចាត់វិធានការពារ ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។

លោកបានសង្កត់ធ្ងន់ថាអន្តោប្រវេសន៍ដើរតួនាទីយ៉ាងសំខាន់ក្នុងការចេញលិខិតឆ្លងដែន និងត្រួតពិនិត្យនៅច្រកអន្តោប្រវេសន៍។ នៅក្នុងពាក្យសុំលិខិតឆ្លងដែន មន្ត្រីអន្តោប្រវេសន៍ត្រូវតែកំណត់អត្តសញ្ញាណអោយបានច្បាស់លាស់ ឬស៊ើបអង្កេតលើជនណាដែលបានផ្តល់ព័ត៌មានមិនត្រឹមត្រូវ។ លោកបានបន្តថា សម្រាប់ជនទាំងនោះការដាក់ពាក្យសុំធ្វើលិខិតឆ្លងដែនអាចត្រូវបានផ្អាករហូតដល់ទៅពីរឆ្នាំ។ លោកបានបញ្ជាក់ថា ដើម្បីចាត់វិធានការអោយមានប្រសិទ្ធភាពអគ្គនាយកដ្ឋានអន្តោប្រវេសន៍នឹងដាក់ចំណាត់ការដាក់លាក់ដើម្បីពន្យារពេលសុំធ្វើលិខិតឆ្លងដែនរហូតដល់៣ឆ្នាំ។

ការត្រួតពិនិត្យនៅច្រកអន្តោប្រវេសន៍ក៏ជាវិធានការបន្ទាប់ក្នុងការទប់ស្កាត់ការជួញដូរមនុស្សផងដែរ។ លោកបាននិយាយទៀតថារាល់ការធ្វើដំណើរអាចពន្យាពេល ប្រសិនបើមានបញ្ហាមិនប្រក្រតីណាមួយត្រូវបានរកឃើញលើអ្នកដំណើរដែលជាពលករចំណាកស្រុក។ លោកបានបន្តថា "ទាក់ទងនឹងការជួញដូរមនុស្ស ប្រទេសឥណ្ឌូនេស៊ី នឹងផ្តួចផ្តើមកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយកម្ពុជា ដើម្បីតាមដានលើបញ្ហានេះ។ យើងសង្ឃឹមថា កិច្ចការនេះនឹងបញ្ចប់ក្នុងពេលដ៏ខ្លីខាងមុខ"។ Antara News Agency

# ថ្ងៃទី១៥ ខែ សីហា ឆ្នាំ២០២៣

## ចាប់ខ្លួនប្រុសស្រី៤នាក់ និងរំដោះនារីរងគ្រោះ១២នាក់ចេញពីហាងការ៉ាអូខេ៥កន្លែងជាប់ៗគ្នា

https://kohsantepheapdaily.com.kh/article/1786400.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ភ្នំពេញ ១៥ ខែ សីហា ឆ្នាំ ២០២៣ ម៉ោង ០៩:០៣

រាជធានីភ្នំពេញ ៖ បើតាមសេចក្តីរាយការណ៍បានឱ្យដឹងថា កម្លាំងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការនគរបាលជាតិ បានចុះបង្ក្រាបទីតាំងហាងការ៉ាអូខេចំនួន៥កន្លែងជាប់ៗគ្នា ដែលលួចបង្កប់នូវសេវាកម្មផ្លូវភេទ ដោយធ្វើការឃាត់ខ្លួនប្រុសស្រីចំនួន៤នាក់ ដែលជាម្ចាស់ទីតាំង និងរំដោះនារីរងគ្រោះចំនួន១២នាក់ បង្កឱ្យមានការភ្ញាក់ផ្អើលកាលពីវេលាម៉ោង៨និង៤០នាទីយប់ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣ នៅចំណុចត្រឡោកបែក តាមបណ្តោយផ្លូវ៥៩៨

ស្ថិតក្នុងសង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក។ សេចក្តីរាយការណ៍បន្តថា សមត្ថកិច្ចបានឃាត់ខ្លួនមនុស្សប្រុសស្រីចំនួន១៦នាក់ ក្នុងនោះមានម្ចាស់ទីតាំងចំនួន៤នាក់ (ស្រី៣នាក់) និង១២នាក់ទៀតគឺជានារីរងគ្រោះ រួមទាំងវត្ថុតាងមានដូចជា ៖ ស្រោមអនាម័យប្រើប្រាស់រួចមួយចំនួន និងមិនទាន់ប្រើប្រាស់មួយចំនួនទៀត។

បើតាមសមត្ថកិច្ច បានប្រាប់ឱ្យដឹងថា «មុននឹងកម្លាំងសមត្ថកិច្ចធ្វើការចុះបង្ក្រាបទីតាំងខាងលើនេះ គឺមានការរាយការណ៍ពីបងប្អូនប្រជាពលរដ្ឋមកថា ហាងកាហ្វេទាំង៥ទីតាំងនេះ គឺបើកលក់ទាំងយប់ទាំងថ្ងៃ និងមានលួចបង្កប់សេវាកម្សាន្ត (ផ្លូ .វភេ.ទ)»។ សមត្ថកិច្ចប្រាប់បន្តទៀតថា «បន្ទាប់មកកម្លាំងជំនាញក៏បានធ្វើការស៊ើបអង្កេត រហូតនៅយប់ថ្ងៃកើតហេតុ កម្លាំងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការនគរបាលជាតិ សហការជាមួយនឹងអាជ្ញាធរ ព្រមទាំងសមត្ថកិច្ចមូលដ្ឋាន ធ្វើការចុះបង្ក្រាប និងឆែកឆេររកឃើញវត្ថុតាងរួមមាន ៖ ស្រោមអនាម័យប្រើប្រាស់រួចមួយចំនួន និងមិនទាន់ប្រើប្រាស់មួយចំនួន ព្រមទាំងបានរំដោះនារីរងគ្រោះចំនួន១២នាក់ ហើយធ្វើការឃាត់ខ្លួនម្ចាស់ទីតាំងចំនួន៤នាក់ ក្នុងនោះមានស្ត្រីចំនួន៣នាក់ផងដែរ»។

ក្រោយពេលកើតហេតុ នារីរងគ្រោះទាំង១២នាក់ ត្រូវបានបញ្ជូនទៅមន្ទីរសង្គមកិច្ច ចំណែកឯម្ចាស់ទីតាំងចំនួន៤នាក់ រួមទាំងវត្ថុតាងវិញ ត្រូវសមត្ថកិច្ចបញ្ជូនទៅកាន់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការនគរបាលជាតិ ដើម្បីចាត់ការបន្តតាមនីតិវិធីច្បាប់ រីឯហាងកាហ្វេទាំង៥ទីតាំងខាងលើនេះ គឺត្រូវបានឃុំបេបិទជាបណ្តោះអាសន្នសិន។

## ឃាត់ខ្លួននារីបម្រើលើយន្តហោះម្នាក់ នាំមិត្តរួមការងារ ដេកជាមួយភ្ញៀវ ១យប់ ៣ពាន់ដុល្លារអាមេរិក

https://kohsantepheapdaily.com.kh/article/1785153.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ១១ ខែ សីហា ឆ្នាំ ២០២៣ ម៉ោង ១៩:៣១

ទីក្រុងហូជីមិញ ៖ អតីតនារីអ្នកបម្រើការលើយន្តហោះម្នាក់ ត្រូវបានប៉ូលិសវៀតណាម ចាប់ឃាត់ខ្លួនកាលពីថ្ងៃព្រហស្បតិ៍ ទី១០ ខែសីហា ឆ្នាំ២០២៣ ពីបទជួញដូរសេវាផ្លូវភេ.ទ ដែលផ្តល់ដោយសហការីរបស់នាង(នារីបម្រើការលើយន្តហោះដូចគ្នា) ក្នុងតម្លៃ ១,០០០ដុល្លារអាមេរិក ក្នុងមួយដង និង៣,០០០ដុល្លារអាមេរិក ក្នុងមួយរាត្រី ។

នាង វ៉ូធី ម៉ាយហាន់ (Vo Thi My Hanh) អាយុ ២៦ឆ្នាំ ជាអតីតអ្នកបម្រើការលើយន្តហោះមានទំនាក់ទំនងជិតស្និទ្ធ(មិត្តភក្តិ)ជាមួយអ្នកបម្រើការ ដែលកំពុងនៅតែធ្វើការនោះ ហើយណែនាំ

ពួកគេផ្តល់សេវាកម្មផ្លូវភេទដល់អតិថិជន "លំដាប់ខ្ពស់" ។ នាងហាន់ ត្រូវបានចាប់ខ្លួន បន្ទាប់ពីប៉ូលិសបានឆ្មក់ចូលសណ្ឋាគារមួយ ក្នុងទីប្រជុំជននៅផ្លូវ Le Thi Rieng ក្នុងខណ្ឌ១ ទីក្រុងហូជីមិញ កាលពីយប់ថ្ងៃពុធ និងបានចាប់ខ្លួននារី ចំនួន០៤នាក់ ដែលកំពុងផ្តល់សេវាផ្លូវភេទ ។ នារី ០៣នាក់ជាអ្នកបម្រើលើយន្តហោះ និងម្នាក់ទៀតជាតារាបង្ហាញម៉ូតរបស់វៀតណាម ។

ស្ត្រីទាំងនោះ បាននិយាយដូចៗគ្នាថា នាងហាន់ បានសុំពួកគេឲ្យចូលរួមអាជីវកម្មនេះ។ ហើយពួកនាង បានគិតប្រាក់ ១,០០០ដុល្លារ ក្នុងមួយដង ហើយតម្លៃ ៣,០០០ដុល្លារអាមេរិក ប្រសិនបើអតិថិជនចង់បានរយៈពេលមួយយប់ ។ នាងហាន់ បានដកយក ៧លានដុង ប្រមាណ(ជិត ៣០០ដុល្លារអាមេរិក) ក្នុងមួយដង ជាថ្លៃឈ្នួញកណ្តាល។ ប៉ូលិសបាននិយាយថា នាងហាន់ រកបានជាង ១ពាន់លានដុង (ជាង ៤២,០០០ដុល្លារអាមេរិក) ពីអាជីវកម្មនេះ ។

អ្នកស៊ើបអង្កេត បានរកឃើញថា នាងហាន់ បានផ្សព្វផ្សាយខ្លួនឯងនៅលើបណ្តាញសង្គមថា ជាស្ត្រីជោគជ័យ ដោយបង្ហោះរូបថតរបស់នាង ទិញរបស់ប្រណិតៗ និងធ្វើដំណើរទៅកាន់កន្លែងល្បីៗ ជាដើម ។ នាងបានចាត់ទុកខ្លួនឯងថា ជាមនុស្សគំរូ ។ ហើយនៅលើបណ្តាញទំនាក់ទំនងសង្គមរបស់នាងមានអ្នកតាមដានជាង ៣០០,០០០នាក់ ។ នាងបានលាឈប់ពីការងារជាអ្នកបម្រើលើយន្តហោះ កាលពីប៉ុន្មានខែមុន មុនពេលនាងនឹងចាប់ផ្តើមអាជីវកម្មផ្លូវភេទ ។ នៅពេលចាប់ខ្លួន នាងហាន់ កំពុងគ្រប់គ្រងស្ត្រីបម្រើផ្លូវភេទ ប្រហែល៣០នាក់ ដែលភាគច្រើន ជាអ្នកបម្រើលើយន្តហោះ និងតារាម៉ូដែល ។

ភ្ញៀវភាគច្រើន មកពីទីក្រុងហាណូយ ទីក្រុងហូជីមិញ និងខេត្តដែលមានព្រំប្រទល់ជាប់ទីក្រុងហូជីមិញ ។ បុរសទាំងនោះ បានទាក់ទង នាង ហាន់ តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម ហើយនាងនឹងរៀបចំសេវាកម្ម ដែលត្រូវផ្តល់ជូននៅតាមសណ្ឋាគារ និងរមណីយដ្ឋាននានា។ នាងមានរថយន្តទំនើប សម្រាប់ដឹកស្ត្រីទាំងនោះ ទៅនិងមកពីកន្លែងរកស៊ីផ្លូវភេទ ។ នាង ហាន់ ក៏បានផ្តល់សេវាកម្មដោយខ្លួនឯង ពោលគឺ រកស៊ីដោយខ្លួនឯងផង និងជាឈ្នួញកណ្តាលផង ។ ពេស្យាចារ ត្រូវបានគេចាត់ទុកថា ជាអំពើអាក្រក់ក្នុងសង្គម ហើយការជួញដូរផ្លូវភេទ ជាបទល្មើសព្រហ្មទណ្ឌ ក្នុងប្រទេសវៀតណាម ៕

# ថ្ងៃទី១៦ ខែ សីហា ឆ្នាំ២០២៣

## ជនឆបោកជនជាតិជប៉ុនពីរនាក់នៅកម្ពុជាប្រឈមនឹងការបញ្ជូនត្រឡប់ទៅប្រទេសវិញ

https://www.khmertimeskh.com/501343124// Khmer Times August 15, 2023

*ជនឆបោកជនជាតិជប៉ុនពីរនាក់នៅកម្ពុជាអាចនឹងត្រូវប្រឈមនឹងកាត់ទោសក្នុងប្រទេសខ្លួននាពេលឆាប់ៗខាងមុខ។ ប្រភពនានាបាននិយាយថា អាជ្ញាធរគ្រោងនឹងបញ្ជូនពួកគេទៅប្រទេសជប៉ុនវិញដោយត្រូវប្រឈមនឹងបទចោទប្រកាន់ពីបទឆបោក។ បុរសទាំងនោះត្រូវបានចោទប្រកាន់ពីបទរៀបចំរគម្រោងវិនិយោគក្លែងក្លាយពីសណ្ឋាគារមួយនៅភាគខាងជើងប្រទេសកម្ពុជា។ នៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ តំបន់នេះ ត្រូវបានគេស្គាល់ថាមានសណ្ឋាគារ និងកាស៊ីណូជាច្រើន។*

*ប្រភពបានឲ្យដឹងថា មន្ត្រីស៊ើបអង្កេតកម្ពុជាបានឃុំខ្លួនបុរសជនជាតិជប៉ុនចំនួន ៧ នាក់ បន្ទាប់ពីទទួលបានព័ត៌មានក្នុងអំឡុងខែឧសភា។ ពួកគេមានអាយុពី ៣០ ទៅ ៥០ឆ្នាំ។ ពួកគេបីនាក់គ្មានលិខិតឆ្លងដែន។ ប្រភពបាននិយាយថា ពួកគេប្រហែលជាធ្វើការឱ្យអ្នកផ្សេង ដោយឯកសារធ្វើដំណើររបស់ពួកគេត្រូវអ្នកទាំងនោះរក្សាទុក។ ជនសង្ស័យពីរនាក់ត្រូវបានចោទប្រកាន់ពីបទបញ្ឆុះបញ្ឆូលបុរសម្នាក់នៅខេត្ត សាហ្គា* (Saga) *ភាគនិរតីនៃប្រទេសជប៉ុន ឱ្យវិនិយោគលើកិច្ចព្រមព្រៀងប្រឌិតមួយ។ នគរបាលជប៉ុនគ្រោងនឹងមកកាន់ប្រទេសកម្ពុជា និងបញ្ជូនពួកគេត្រឡប់ទៅប្រទេសវិញ។*

*ករណីស្រដៀងគ្នានេះបានកើតឡើងកាលពីខែមេសា នៅពេលដែលអាជ្ញាធរកម្ពុជាបានចាប់ខ្លួនជនជាតិជប៉ុន ១៩ នាក់។ ពួកគេត្រូវបានចោទប្រកាន់ពីបទរត់ការគម្រោងក្លែងបន្លំសម្រាប់រមណីយដ្ឋានមួយ។ អាជ្ញាធរកម្ពុជាបានបញ្ជូនជនសង្ស័យជនជាតិជប៉ុនទាំង ១៩ នាក់ត្រឡប់ទៅប្រទេសកំណើតវិញនៅថ្ងៃទី ១១ ខែមេសា ជុំវិញការជាប់ពាក់ព័ន្ធនឹងការឆបោកតាមទូរស័ព្ទ ខណៈនគរបាលជប៉ុនបន្តបង្ក្រាបក្រុមឆបោកដែលមានមូលដ្ឋាននៅតាមបណ្តាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍។ បុរសទាំងនោះដែលបានធ្វើសកម្មភាពពីសណ្ឋាគារមួយកន្លែងនៅភាគខាងត្បូងប្រទេសកម្ពុជាត្រូវបានចាប់ខ្លួនតាមជើងហោះហើរពិសេស* (chartered flight) *ទៅប្រទេសជប៉ុននេះបើយោងតាមនគរបាលក្រុងតូក្យូ។ យន្តហោះបានមកដល់អាកាសយានដ្ឋាន* Haneda *នៅថ្ងៃបន្ទាប់។*

*បុរសទាំងនោះត្រូវបានគេសង្ស័យថាបានឆបោកស្ត្រីអាយុ ៦២ ឆ្នាំម្នាក់ដែលរស់នៅក្នុងទីក្រុងតូក្យូ នៃប្រាក់អេឡិចត្រូនិក* BitCash *តម្លៃ ២៥០,០០០ យ៉េនក្នុងខែមករា។ ប្រភពពីនគរបាលស៊ើបអង្កេតបាននិយាយថា ពួកគេមានអាយុចន្លោះពី២៥ ទៅ ៥៥ឆ្នាំ ដោយជនសង្ស័យម្នាក់ត្រូវបានគេគិតថាជាសមាជិកនៃក្រុមឆបោក។* NHK/KYODO

# កម្ពុជាបញ្ជូនជនឆបោកតាមអ៊ីនធឺណិតជនជាតិជប៉ុន ២នាក់ទៅប្រទេសជប៉ុនវិញ

https://www.khmertimeskh.com/501343696//?p=1343696 Khmer Times August 16, 2023

ប្រភពស៊ើបអង្កេតបានអោយដឹងថា អាជ្ញាធរកម្ពុជាបានបញ្ជូនជនសង្ស័យជនជាតិជប៉ុនពីរនាក់ទៅ ប្រទេសជប៉ុនកាលពីថ្ងៃអង្គារជុំវិញការពាក់ព័ន្ធនឹងការឆបោកតាមអ៊ីនធឺណិត។ ជនទាំងពីរត្រូវបាននគរបាលជប៉ុនធ្វើដំណើរជាមួយ តាមជើងហោះហើរ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។

ជនសង្ស័យទាំងពីរនេះស្ថិតក្នុងចំណោមជនជាតិជប៉ុន៧ នាក់ ដែលត្រូវបានឃុំខ្លួននៅភាគខាងជើងប្រទេសកម្ពុជា ក្បែរព្រំដែនថៃកាលពីខែឧសភា បន្ទាប់ពីមានអ្នកជូនដំណឹងដល់អាជ្ញាធរអំពីសកម្មភាពឆបោករបស់ពួកគេ។

ជនជាប់ចោទផ្សេងទៀតត្រូវបានបញ្ជូនមកប្រទេសជប៉ុនវិញ ហើយត្រូវបាននគរបាលជប៉ុនកំពុងសាកសួរ។ នគរបាលកម្ពុជាបានរឹបអូសកុំព្យូទ័រ និងទូរស័ព្ទដៃដែលជនទាំងនោះបានប្រើប្រាស់។ ការបញ្ជូនត្រឡប់ទៅវិញនេះត្រូវបានធ្វើឡើងបន្ទាប់ពីជនឆបោកតាមអ៊ីនធឺណិតជនជាតិជប៉ុនចំនួន ១៩ នាក់ផ្សេងទៀតត្រូវបានឃាត់ខ្លួនកាលពីខែមេសា៕ The mainichi

# ថ្ងៃទី១៨ ខែ សីហា ឆ្នាំ២០២៣

## កម្ពុជា-វៀតណាម
## ធ្វើបច្ចុប្បន្នភាពលើកិច្ចព្រមព្រៀងសហប្រតិបត្តិការ ពីនីតិវិធីប្រតិបត្តិបទដ្ឋានក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស

https://freshnewsasia.com/index.php/en/localnews/305259-2023-08-16-07-08-23.html 2023-08-16 02:08pm

**(ភ្នំពេញ)៖** ក្រសួងជំនាញរបស់កម្ពុជា និងវៀតណាម នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣នេះ បានធ្វើបច្ចុប្បន្នភាពលើកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងរដ្ឋាភិបាលទាំងពីរ ពីនីតិវិធីប្រតិបត្តិបទដ្ឋានក្នុងការកំណត់អត្តសញ្ញាណនិងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

ពិធីនេះបានធ្វើឡើងក្រោមវត្តមានលោក ញឹក វណ្ណារ៉ា រដ្ឋលេខាធិការ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, លោកស្រី គ្រីស្ទីន ផាកូ (Kistin Parco) នាយិកាប្រចាំប្រទេស អង្គការទេសន្តរប្រវេសន៍ អន្តរជាតិ ប្រចាំនៅកម្ពុជា អន្តរជាតិ ប្រចាំនៅកម្ពុជា, គង់ សុភណារ៉ា ទីប្រឹក្សាក្រសួង ស.អ.យ, លោក ឡៅ វ៉េង អគ្គនាយករងសេវាសង្គមកិច្ច នៃក្រសួងសង្គមកិច្ច, លោក ជ័យ រដ្ឋា អគ្គនាយករងអគ្គនាយករងកុងសុល នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ,

ឧត្តមសេនីយទោ សេក ស៊ីវ៉េត ប្រធាននាយកដ្ឋានការពារជនរងគ្រោះ នៃអគ្គនាយកដ្ឋាន គជបជ , លោក យូ សុភក្រ្ត ប្រធាននាយកដ្ឋានគាំពារជនរងគ្រោះ នៃក្រសួងសង្គមកិច្ច, លោក យូ សុភ័ក្រ ប្រធាននាយកដ្ឋានគាំពារជនរងគ្រោះ, លោក គ្រីសស្ទិន ផាកូ (Kistin Parco) នាយិកាប្រចាំប្រទេស អង្គការទេសន្តរប្រវេសន៍ អន្តរជាតិ ប្រចាំនៅកម្ពុជា អន្តរជាតិ ប្រចាំនៅកម្ពុជា និងលោក លោកស្រី ប្រធានអង្គភាព ស្ថាប័ន ប្រធានអង្គការ ឬតំណាងអង្គការ ស្ថាប័នដៃគូអភិវឌ្ឍន៍ និងអង្គការពាក់ព័ន្ធ។

ឆ្លៀតក្នុងឱកាសនេះ លោក ញ៉ឹក វណ្ណារ៉ា សូមថ្លែងនូវអំណរគុណចំពោះអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (អាយ អូ អឹម) ដែលតែងតែសហការយ៉ាងជិតស្និទជាមួយក្រសួង ស.អ.យ លើវិស័យសង្គមកិច្ចកន្លងមក ដែលមាននាយកដ្ឋានគាំពារជនរងគ្រោះជាសេនាធិការ ជាពិសេសថ្ងៃនេះបានសហការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការធ្វើបច្ចុប្បន្នភាពលើកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលនៃកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម អំពីនីតិវិធីប្រតិបត្តិបទដ្ឋាន ក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ ជនរងគ្រោះដោយអំពើជួញដូរមនុស្សនេះ។

លោកបានបញ្ជាក់ថា ឯកសារមួយនេះ (នីតិវិធីប្រតិបត្តិបទដ្ឋាន ក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស) បានកើតឡើងតាំងពីឆ្នាំ២០០៩ រហូតមកដល់ពេលនេះ មាន រយៈពេលជាង១៣ឆ្នាំកន្លងផុតទៅហើយ ដែលជាហេតុតម្រូវឱ្យភាគីនៃប្រទេសទាំងពីរត្រូវតែធ្វើបច្ចុប្បន្នភាពឡើងវិញនូវ SOP មួយនេះ។ លោក ញ៉ឹក វណ្ណារ៉ា អំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មលើមនុស្សបានកើតឡើង និងកំពុងរីកសាយភាយគ្រប់ទីកន្លែង គ្រប់រូបភាព ភាគច្រើន ជាឧក្រិដ្ឋកម្មឆ្លងដែន ដែលមានអង្គការចាត់តាំងហើយឧក្រិដ្ឋកម្ម នេះបានធ្វើឱ្យប៉ះពាល់ទាំងថ្នាក់ជាតិតំបន់ និងលើពិភពលោក។

បន្ថែមពីនេះ លោក ញ៉ឹក វណ្ណារ៉ា បានបញ្ជាក់ថា បញ្ហានេះប្រទេសកម្ពុជាបាននឹងកំពុងបង្កើតរៀបចំចង់ក្រងផ្សព្វផ្សាយ អនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងយន្តការនានាសំដៅប្រយុទ្ធប្រឆាំង និងចូលរួមកាត់បន្ថយឱ្យបានជាអតិបរិមានូវអំពើជួញដូរមនុស្សទាំងក្នុងក្របខ័ណ្ឌជាតិ តំបន់ និងលើពិភពលោក ពិសេសជាងនោះទៅទៀត ការសម្របសម្រួល ក្នុងកំណត់អត្តសញ្ញាណបឋម ការផ្តល់សេវា ការរៀបចំធ្វើមាតុភូមិនិវត្តន៍ ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស គឺជាចំណុចដ៏សំខាន់ដែល ប្រទេ ស ជាម្ចាស់ហត្ថលេខីទាំងអស់នៃសន្ធិសញ្ញាស្តីពីការលុបបំបាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស ត្រូវតែអនុវត្តឱ្យបានពេញ

លេញ និងផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយមិនប្រកាន់និន្នាការជាតិពន្ធុនោះឡើយ។

មន្ត្រីជាន់ខ្ពស់រូបនេះ បានគូសបញ្ជាក់ថា៖ **«ព្រោះតែហេតុយ៉ាង ដូច្នេះហើយទើបយើងជួបជុំគ្នាដើម្បីធ្វើសិក្ខាសាលាពិគ្រោះយោបល់ពីការធ្វើបច្ចុប្បន្នភាព លើកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល នៃព្រះ រាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម អំពីនីតិវិធីប្រតិបត្តិបទដ្ឋាន ក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ ជនរងគ្រោះដោយអំពើជួញដូរមនុស្សនាថ្ងៃនេះ»**។

ក្នុងនាមក្រសួង ស.អ.យ លោកសូមសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់នាយកដ្ឋានគាំពារជនរងគ្រោះដែលបានខិតខំប្រឹងប្រែងសហការយ៉ាងសកម្មជាមួយអង្គការដៃគូលើការកសាងឯកសារមួយនេះ និងសូមថ្លែងអំណរគុណចំពោះ អង្គការដៃគូអភិវឌ្ឍន៍ទាំងអស់ជានិច្ចជាកាល តែងតែសហការជាមួយក្រសួង ស.អ.យ លើវិស័យការងារសង្គមកិច្ចជាពិសេសអង្គការទេសន្តរ ប្រវេសន៍អន្តរជាតិ (អាយ អូ អឹម) បានជួយគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសក្នុងដំណើរការកសាងឯកសារនេះឡើង។ ទន្ទឹមនឹងនេះដែរ លោកក៏សូមអំពាវនាវដល់អង្គការដៃគូអភិវឌ្ឍន៍ទាំងអស់ មេត្តាជួយគាំទ្រ និងមានកិច្ចសហការបន្តជាមួយក្រសួង ស.អ.យ ឱ្យបានច្រើនជាងនេះដើម្បីរួមគ្នាការពារ និងទប់ស្កាត់ជនរងគ្រោះអំពើជួញដូរមនុស្សនាពេលអនាគត៕

## ប៉ូលិសចាប់ខ្លួននិស្សិត ថៃ វ័យ ១៩ឆ្នាំម្នាក់ ពីបទលក់រូបអាសអាភាសកុមារ

https://www.kampucheathmey.com/global-news/560099 ថ្ងៃពុធ ១៦ សីហា ២០២៣ ដោយ Blue Sky

មន្ត្រីនាយកដ្ឋានស៊ើបអង្កេតពិសេស (DSI) កាលពីម្សិលមិញបានចាប់ខ្លួននិស្សិតសកលវិទ្យាល័យថៃអាយុ១៩ ឆ្នាំម្នាក់ ពីបទលក់រូបភាពអាសអាភាសកុមារតាមអ៊ីនធឺណិតនៅខុនដូក្នុងខេត្ត Pathum Thani ជិតទីក្រុងបាងកក។

នាយកផ្នែកវិវាទបច្ចេកវិទ្យា និងព័ត៌មានរបស់ DSI លោក Khemmachart Prakuyhongmanee បានរាយការណ៍ពីប្រតិបត្តិការដ៏ជោគជ័យដល់ប្រព័ន្ធផ្សព្វផ្សាយនៅថ្ងៃនេះ ដោយបញ្ជាក់ថា មន្ត្រីបានទទួលព័ត៌មានអំពីការលក់រូបភាពអាសអាភាសកុមារតាមអ៊ីនធឺណែតពីខុនដូ ហើយបានធ្វើការធ្នាក់ចាប់នៅនឹងកន្លែងកាលពីម្សិលមិញជាមួយនឹងឆ្កែញីមួយក្បាលឈ្មោះ Hidu ដែលត្រូវបានបណ្តុះបណ្តាលនៅសហរដ្ឋអាមេរិកដើម្បីចាប់ឧបករណ៍អេឡិចត្រូនិក។

ក្តៃនេះបានដឹកនាំអាជ្ញាធរ DSI ទៅកាន់បន្ទប់របស់ជនសង្ស័យអាយុ ១៩ ឆ្នាំម្នាក់ដែលលក់រូបភាពអាសអាភាសរបស់កុមារតាមរយៈកម្មវិធីជជែកជាក្រុម LINE ។ មន្ត្រីបានរកឃើញឯកសារអាសអាភាសកុមារជាង ៩,០០០ ហើយបានរកឃើញថាមានជនរងគ្រោះកុមារជាង ២០០ នាក់ដែលពាក់ព័ន្ធនឹងការបង្កើតខ្លឹមសារនេះ។

នាយកផ្នែកវិវាទបច្ចេកវិទ្យាបានរាយការណ៍បន្ថែមទៀតថា ជនសង្ស័យធ្វើការជាមួយស្ត្រីម្នាក់ទៀត។ ស្ត្រីរូបនោះបានបង្កើតប្រវត្តិរូបតាមអ៊ីនធឺណិតដោយប្រើរូបភាពដ៏ស្រស់ស្អាត និងនិយាយទៅកាន់ជនរងគ្រោះ ដែលភាគច្រើនជាក្មេងប្រុសអាយុក្រោម១៨ឆ្នាំ។ បន្ទាប់មក ស្ត្រីរូបនេះបានល្បួងជនរងគ្រោះឲ្យផ្ញើរូបភាព និងវីដេអូស្រាតរបស់នាង ដើម្បីលក់ឲ្យពួកគេក្នុងក្រុម LINE ។ សមាជិកម្នាក់ៗនៃក្រុមត្រូវចំណាយសម្រាប់កញ្ចប់មួយដើម្បីមើលរឿងអាសអាភាស ដែលមានតម្លៃចន្លោះពី ១៥០បាតទៅ៥០០ បាត។ លើសពីនេះទៀតលោកក៏ជឿថា មានសមាជិកច្រើនទៀតពាក់ព័ន្ធនឹងសង្កៀនពេស្យាចារ ជាងក្មេងប្រុសស្រីទៅទៀត។ខណៈលោកបានបន្ថែមថា ការស៊ើបអង្កេតនឹងត្រូវធ្វើឡើងដើម្បីរកឃើញក្រុមក្មេងទំនើងដែលនៅសល់។

យ៉ាងណាមិញ ដំបូងឡើយជនសង្ស័យត្រូវបានចោទប្រកាន់ពីបទកែច្នៃរូបភាពអាសអាភាសកុមារ ដើម្បីជាប្រយោជន៍ផ្លូវភេទដល់ខ្លួន ឬអ្នកដទៃ ដែលនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់ ៥ ឆ្នាំ ពិន័យជាប្រាក់រហូតដល់ ១០ ម៉ឺនបាត ឬទាំងសងខាង យោងតាមមាត្រា ២៨៧ នៃក្រមព្រហ្មទណ្ឌ។ ក្មេងជំទង់រូបនេះក៏ប្រឈមនឹងការចោទប្រកាន់ពីបទបង្ហោះរូបអាសអាភាសរបស់កុមារតាមអ៊ីនធឺណិត ដែលសាធារណជនអាចចូលមើលបាន។ ការផាកពិន័យនេះនឹងត្រូវជាប់ពន្ធនាគាររហូតដល់ប្រាំឆ្នាំ ពិន័យជាប្រាក់រហូតដល់ ១០០,០០០បាត ៕

## នគរបាលជប៉ុនចាប់ខ្លួនជនសង្ស័យឆបោក ២នាក់និងបាននិរទេសចេញពីកម្ពុជា

https://www.khmertimeskh.com/501344424// Khmer Times August 17, 2023

នគរបាលបានចាប់ខ្លួនបុរសជនជាតិជប៉ុនពីរនាក់ កាលពីថ្ងៃពុធជុំវិញការចោទប្រកាន់ថាពួកគេជាប់ពាក់ព័ន្ធនឹងក្រុមឆបោកនៅក្នុងប្រទេសកម្ពុជាបន្ទាប់ពីការនិរទេសចេញពីកម្ពុជា។ ជសង្ស័យឈ្មោះ Shigeru Sato អាយុ៥៥ ឆ្នាំ និង Hiroki Ito អាយុ៤៨ឆ្នាំ ត្រូវបានចាប់ខ្លួនពីបទឆបោកខណៈជិះយន្តហោះឆ្ពោះទៅអាកាសយានដ្ឋាន Haneda ទីក្រុងតូក្យូ ដែលបានចុះចតនៅម៉ោងប្រហែល ៦ ព្រឹក។

ប្រភពស៊ើបអង្កេត និងអ្នកដែលដឹងពីរឿងនេះបាននិយាយថា អ្នកទាំងពីរគឺជាមនុស្សចុងក្រោយក្នុងចំណោមក្រុមជនជាតិជប៉ុន៧នាក់ដែលត្រូវបានឃុំខ្លួន ពាក់ព័ន្ធនឹងក្រុមឆបោក។ ក្រៅពីនោះ ត្រូវបានបញ្ជូនខ្លួនដល់ប្រទេសជប៉ុនរួចហើយ និងត្រូវបាននគរបាលជប៉ុនធ្វើការសាកសួរ។

ប្រភពស៊ើបអង្កេតបាននិយាយថា  អ្នកទាំងពីរត្រូវបានគេសង្ស័យថាបានឆបោកអ្នកស្រុកនៅខេត្ត Saga ។ ការចាប់ខ្លួនអ្នកទាំងពីរនេះ ធ្វើឡើងចំពេលមានករណីជាច្រើនកើតឡើងលើជនជាតិជប៉ុន ដែលប្រើប្រាស់មូលដ្ឋាននៅក្រៅប្រទេស  ដើម្បីប្រព្រឹត្តបទឧក្រិដ្ឋនៅក្នុងប្រទេសកំណើតរបស់ពួកគេ។

ក្នុងចំណោមនោះ មានសំណុំរឿងឧក្រិដ្ឋកម្ម "Luffy" ដ៏ល្បីមួយ ដែលជនជាតិជប៉ុន ៤នាក់ ត្រូវបាននិរទេសចេញពីប្រទេសហ្វីលីពីន កាលពីខែកុម្ភៈ ពាក់ព័ន្ធនឹងករណីប្លន់មួយចំនួន ដែលរៀបចំនៅទូទាំងប្រទេសជប៉ុន។ ជនសង្ស័យបានហៅខ្លួនឯងថា Luffy ដូចតួអង្គគំនូរជីវចលដ៏ពេញនិយមមួយ៕ *Kyodo*

# ថ្ងៃទី២១ ខែ សីហា ឆ្នាំ២០២៣

## ស្ថានទូតៈ កម្មសិក្សាការី និងពលករជំនាញខ្មែរ ដែលកំពុងធ្វើការក្នុងប្រទេសជប៉ុនដោយស្របច្បាប់ ពុំជួបវិបត្តិអត់ការងារធ្វើដូចដែល Cambodia Daily បានចុះផ្សាយនោះទេ

https://freshnewsasia.com/index.php/en/localnews/305679-2023-08-19-12-01-19.html 2023-08-19 07:01pm

**(ភ្នំពេញ)៖** ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសជប៉ុន បានអះអាងថា កម្មសិក្សាការី និងពលករជំនាញខ្មែរ ដែលកំពុងធ្វើការក្នុងប្រទេសជប៉ុនដោយស្របច្បាប់ ពុំជួបវិបត្តិអត់ការងារធ្វើដូចដែល Cambodia Daily បានចុះផ្សាយនោះទេ។ ការបញ្ជាក់របស់ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសជប៉ុន ជាការឆ្លើយតបនឹងការចុះផ្សាយរបស់កាសែត Cambodia Daily ក្រោមចំណងជើងថា ពលករខ្មែរប្រព្រឹត្តអំពើចោរកម្ម ដោយសារគ្មានការជួយដោះស្រាយពីស្ថានទូតខ្មែរ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ ២០២៣។

បើកតាមស្ថានទូតកម្ពុជា, បច្ចុប្បន្ននេះមានកម្មសិក្សាការី និងពលករជំនាញខ្មែរកំពុងធ្វើការក្នុងប្រទេសជប៉ុនតាមរយៈក្រុមហ៊ុនបញ្ជូន សរុបចំនួន ២០,៥៦១ នាក់ (ស្រី ៩,៥៨៧ នាក់) និងពុំជួបវិបត្តិអត់ការងារធ្វើដូចដែល Cambodia Daily បានចុះផ្សាយនោះទេ លើកលែងតែបុគ្គលមកធ្វើការខុសច្បាប់តាមទិដ្ឋាការទេសចរណ៍ប៉ុណ្ណោះ។ ប៉ុន្តែក៏ មានកម្មសិក្សាការីខ្មែរមួយចំនួនតូចបានរត់ចេញពីកន្លែងការងារទៅធ្វើការខុសច្បាប់ ក្រោមការអូសទាញរបស់ មេខ្យល់។ ការរត់ចេញពីកន្លែងធ្វើការពុំមែនមានតែកម្មសិក្សាការីខ្មែរនោះទេ  កន្លងមក  ស្ថានទូតបានជួបជាមួយក្រសួង-ស្ថាប័នជប៉ុន  ហើយបានស្នើសុំឱ្យមានវិធានការផ្លូវច្បាប់ចំពោះមេខ្យល់អូស  ទាញកម្មសិក្សាការីទៅធ្វើការ

ខុសច្បាប់ និងនិយោជកជប៉ុនដែលបានទទួលកម្មសិក្សាការីខុសច្បាប់ទៅធ្វើ ការនៅតាមរោងចក្រ-សហគ្រាសរបស់ខ្លួន។

ចំពោះការទប់ស្កាត់ការរត់ចេញពីកន្លែងធ្វើការរបស់កម្មសិក្សាការី ស្ថានទូតតែងសហការជាមួយ សមាគមគ្រប់គ្រង និងក្រុមហ៊ុនជប៉ុន និងក្រុមហ៊ុនបញ្ជូនខ្មែររៀបចំកម្មវិធីចុះប្រឹក្សាយោបល់ និងណែនាំ ដល់កម្មសិក្សាការីឱ្យបានជ្រួតជ្រាបពីផលវិបាកនៃការរត់ចេញពីកន្លែងធ្វើការ និងយន្តការផ្តល់សេវាគាំពារ និងទ្រទ្រង់ដល់កម្មសិក្សាការី និងពលករជំនាញខ្មែរ តាមរយៈកិច្ចសហការជាមួយភាគីពាក់ព័ន្ធ រួមមានក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមហ៊ុនបញ្ជូនខ្មែរ សមាគមគ្រប់គ្រង និងក្រុមហ៊ុនជប៉ុន ក្រសួងសុខាភិបាល ការងារ និងសុខមាលភាពជប៉ុន ក្រសួងយុត្តិធម៌ជប៉ុន និងអង្គការគ្រប់គ្រងកម្មសិក្សាការី បច្ចេកទេស (OIIT) ដើម្បីដោះស្រាយបញ្ហាការងារ និងការរស់នៅឱ្យបានឆាប់រហ័ស និងទទួលបានជោគជ័យ។

ចំពោះអំពើចោរកម្មលួចកាត់ខ្សែភ្លើងដែលកើតមានកន្លងមកនោះ គឺការលួចកាត់ខ្សែភ្លើង Solar (ពុំមែនខ្សែភ្លើងធ្វើឱ្យស្ថានីយ៍រថភ្លើងលែងដំណើរការនោះទេ) ដែលការលួចកាត់នេះមានការរៀបចំជាប្រព័ន្ធ ពុំមែនគ្រាន់តែដោយសារជួបវិបត្តិអត់ការងារធ្វើនោះទេ និងក៏ពុំមែនមានតែអតីតកម្មសិក្សាការីខ្មែរនោះដែរ។ ស្ថានទូតកម្ពុជាបានអះអាងទៀតថា សហជីពដែលបានផ្តល់ព័ត៌មានដល់កាសែត The Cambodia Daily ពុំមែនជាសហជីពទទួលបន្ទុកការពារសិទ្ធិពលករខ្មែរដូចដែលបានអះអាងនោះទេ ក៏ប៉ុន្តែជាប្រភេទសហជីពលើកទឹកចិត្តឱ្យកម្ម សិក្សាការីបរទេសប្តឹងនឹងក្រុមហ៊ុនរបស់ខ្លួន ដោយពុំពិភាក្សា ឬផ្សះផ្សាជាមុន ជាពិសេសពុំដែលទំនាក់ ទំនងមកស្ថានទូតទេ (សហជីពមានបុគ្គលិកខ្មែរដែលមាននិន្នាការគាំទ្រអតីតគណបក្សសង្គ្រោះជាតិ)។

ដោយឡែកករណីធ្វើអត្តឃាតរបស់កម្មសិក្សាការីក្នុងឆ្នាំ ២០២២ មិនមែនដោយសារការរងសម្ពាធ ការងារ ទើបបានគេរត់ចេញនោះទេ គឺជាការចាញ់បោករត់តាមមេខ្យល់ទៅធ្វើការខុសច្បាប់។ មុនពេលធ្វើ អត្តឃាតជនរងគ្រោះបានប្រឹក្សាយោបល់ជាមួយបុគ្គលិកមជ្ឈមណ្ឌលផ្តល់ប្រឹក្សាយោបល់ដល់កម្មសិក្សាការី បរទេសរបស់អង្គការ OTIT និងទំនាក់ទំនងក្រុមហ៊ុនដែលធ្លាប់ធ្វើការ ដើម្បីស្នើសុំអនុញ្ញាតចូលធ្វើការវិញ បន្ទាប់ពីបានរត់តាមមេខ្យល់ប្រមាណមួយសប្តាហ៍។ តំណាងក្រុមហ៊ុនបានទទួលពាក្យស្នើសុំទៅពិភាក្សា ជាមួយថ្នាក់ដឹកនាំក្រុមហ៊ុន និងគ្រោងឯកភាពទទួលចូលធ្វើការវិញ ក៏ប៉ុន្តែជាអកុសលជនរងគ្រោះបានធ្វើ អត្តឃាតបាត់ទៅហើយ។

ក្រុមការងារស្ថានទូត ក៏បានចូលរួមកម្មវិធីបូជាសព និងយកថវិកាចូលបុណ្យសព ក៏ដូចជាសម្របសម្រួលជាមួយតំណាងក្រុមហ៊ុនជប៉ុនចាត់ចែងបុណ្យសព និងបញ្ជូនធាតុទៅប្រទេសខ្មែរ តាមសំណូមពររបស់គ្រួសារសពផងដែរ៕

## ពលរដ្ឋជាង៣០នាក់
## ចាញ់បោកមេខ្យល់អស់រាប់ពាន់ដុល្លារ ផ្អើលព្រលានយន្តហោះអន្តរជាតិភ្នំពេញ

https://kohsantepheapdaily.com.kh/article/1789266.html?fbclid=IwAR16MsICuKS1hfjP ភ្នំពេញ ២០ ខែ សីហា ឆ្នាំ ២០២៣ ម៉ោង ០៨:៥៥

រាជធានីភ្នំពេញ ៖ បើតាមសេចក្តីរាយការណ៍បានឱ្យដឹងថា មនុស្សប្រុសស្រីជាង៣០នាក់ បានចាញ់បោកមេខ្យល់ដោយប្រាប់ថា នាំទៅធ្វើការនៅប្រទេសជប៉ុន តែមិនបានដូចបំណងនោះទេ ព្រោះមិនបានឡើងយន្តហោះ បង្កអោយមានការភ្ញាក់ផ្អើលកាលពីវេលាម៉ោង៩និង៣០នាទីយប់ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣ នៅចំណុចព្រលានយន្តហោះអន្តរជាតិភ្នំពេញ ស្ថិតក្នុងសង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

បើតាមស្ត្រីម្នាក់មានឈ្មោះ ជា ធារិន អាយុ៣៧ឆ្នាំ មុខរបរនៅផ្ទះ រស់នៅស្រុកខាងប្តី គឺស្រុកព្រៃឈរ ខេត្តកំពង់ចាម នឹងមានស្រុកកំណើតនៅភូមិព័ន្ធរាយ ឃុំចាងដាង ស្រុកបារាយណ៍ ខេត្តកំពង់ធំ បានអះអាងថា «ខ្លួនគាត់មិនមែនជាមេខ្យល់នោះទេ គឺគាត់គ្រាន់តែជាមេក្រុមតែប៉ុណ្ណោះ ហើយគាត់ក៏ចាញ់បោកគេដែរ រួមទាំងបងប្អូន២ទៅ៣នាក់ទៀតផង។ ហើយគាត់បានយកលុយពីបងប្អូនពិតប្រាកដមែន តែយកលុយអោយមេខ្យល់ទាំងអស់ សូម្បីតែមេខ្យល់ដែលគាត់យកលុយអោយនោះ គឺមិនបានស្គាល់ផ្ទះពិតប្រាកដទេ គ្រាន់តែដឹងថា គាត់ធ្វើការនៅក្រសួង ខាងធ្វើប៉ាស្ព័រ និងធ្វើការនៅម្តុំផ្សារស៊ិនជូវីថ្នាស្សា»។

តាមប្រភពព័ត៌មានពីប្រជាពលរដ្ឋដែលចាញ់បោកមេខ្យល់ ក៏បានឱ្យដឹងដែរថា «បន្ទាប់ពីស្ត្រីម្នាក់ឈ្មោះ ជា ធារិន បានបញ្ចុះបញ្ចូលពួកគាត់ដោយប្រាប់ថា ទៅធ្វើការនៅប្រទេសជប៉ុនបានប្រាក់ខែចាប់ពី២ពាន់ដុល្លារទៅ២៥០០ដុល្លារ ដោយធ្វើជាកម្មករគ្រឿងខ្មៅខ្ចង។ ក្នុងនោះពួកគាត់ គឺត្រូវចំណាយថវិកាចំនួន៤៥០០ដុល្លារក្នុងម្នាក់ៗ តែយកលុយមុនចំនួន២៥០០ដុល្លារ ចាំបានការងារធ្វើការនឹងកាត់តាមក្រោយទៀត។ ហើយក៏មានបងប្អូនខ្លះមានតែ១ពាន់ដុល្លារក៏បានដែរ ដោយស្ត្រីខាងលើរូបនេះ សុំអោយ ចាំធ្វើការហើយកាត់តាមក្រោយ»។

ប្រភពព័ត៌មានដដែលបានបន្តទៀតថា «លុយកាក់ដែលយកមកប្រគល់ឲ្យស្ត្រីម្នាក់ខាងលើនោះ គឺបានមកពីលក់គោ-ក្របី លក់ដី និងមួយចំនួនទៀតទៅខ្ចីលុយធនាគារ។ ហើយមុនដំបូង ស្ត្រីម្នាក់ខាងលើនេះ បានបញ្ចុះបញ្ចូលពួកគាត់អោយទុកចិត្ត និងបញ្ជាក់ប្រាប់ពួកគាត់ថា គាត់ធ្លាប់ទៅធ្វើការនៅប្រទេសជប៉ុនអស់រយៈពេល៣ឆ្នាំ៦ខែ តែទៅធ្វើការម្តងក្រោយនេះ គឺរយៈពេល៥ឆ្នាំ»។ ប្រភពដដែលបន្តទៀតថា «មុននឹងទៅធ្វើការនៅប្រទេសជប៉ុន មេខ្យល់អោយប្រជាពលរដ្ឋយកឯកសារមកធ្វើប៉ាស្ព័រនៅម្តុំវត្តនិរោធ ខណ្ឌច្បារអំពៅ ដោយស្ត្រីខាងលើជាអ្នកនាំទៅធ្វើប៉ាស្ព័រគ្រប់ៗគ្នា។

សូម្បីតែពិនិត្យសុខភាព ក៏មិនចាំបាច់ដែរ ចំណែកភាសាវិញចាំផ្ទៀតរៀនថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ។ ក៏ប៉ុន្តែលុះនៅវេលាម៉ោងកើតហេតុ ស្ត្រីខាងលើបានប្រាប់ប្រជាពលរដ្ឋថា មិនឃើញមេខ្យល់មកជូនដំណើរនៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ ទើបម្នាក់ៗដឹងខ្លួនថា សង្ស័យចាញ់បោកគេ»។

ក្រោយពេលកើតហេតុ បន្ទាប់ពីភ្ញាក់ផ្អើលនៅក្នុងព្រលានយន្តហោះអន្តរជាតិភ្នំពេញភ្លាម បងប្អូនប្រជាពលរដ្ឋបានទៅប្តឹងនគរបាលប៉ុស្តិ៍ តែនគរបាលប៉ុស្តិ៍ពន្យល់ណែនាំប្រជាពលរដ្ឋជាជនរងគ្រោះ និងស្ត្រីខាងលើនៅមុខព្រលានយន្តហោះអន្តរជាតិភ្នំពេញថា «ដំណាក់កាលទី១ ចង់អោយកម្លាំងសមត្ថកិច្ចចាត់ការតាមផ្លូវច្បាប់ ឬនាំគ្នាទៅដោះស្រាយនៅស្រុក ព្រោះមួយចំនួនធំ គឺជាអ្នកស្រុករស់នៅភូមិជិតៗគ្នា»។ បន្ទាប់មក ប្រជាពលរដ្ឋក៏បាននាំស្ត្រីជាមេក្រុមទៅស្រុក ដើម្បីរកដំណោះស្រាយសិន បើមិនរកដំណោះស្រាយជូនពួកគាត់ទេ នឹងប្តឹងអោយសមត្ថកិច្ចចាត់ការតាមផ្លូវច្បាប់តែម្តង។

## ថៃ ចាប់ខ្លួនគូស្នេហ៍ ដែលបើកបណ្តាញផ្លូវភេទ ទាក់ទងនារីឲ្យធ្មៀវបរទេស

https://www.kampucheathmey.com/global-news/562137 ថ្ងៃសៅរ៍ ១៩ សីហា ២០២៣ដោយ Sok Sovann

ប៉ូលិសថៃ បានចាប់ខ្លួនជនជាតិអាមេរិកម្នាក់ និងមិត្តស្រីរបស់គាត់ជាជនជាតិថៃ ដោយសារអ្នកទាំងពីរ បើកគេហទំព័រដែលផ្តល់សេវាពេស្យាចារនៅក្នុងទីក្រុងទេសចរណ៍ជាច្រើន។ ជនជាតិអាមេរិកអាយុ៤៨ឆ្នាំ ត្រូវបានគេចាប់ខ្លួននៅផ្ទះរបស់គាត់ ក្នុងទីក្រុងរមណីយដ្ឋាន Hua Hin នៃខេត្ត Prachuap Khiri Khan ខណៈមិត្តស្រីជនជាតិថៃអាយុ ៣៤ ឆ្នាំឈ្មោះ Kanya ត្រូវបានចាប់ខ្លួននៅអាកាសយានដ្ឋានសុវណ្ណភូមិ ក្នុងទីក្រុងបាងកក។ ប៉ូលិស បានទទួលពាក្យបណ្តឹងពីអ្នកទេសចរបរទេសថា នារីបម្រើសេវាកម្មដែលពួកគេទាក់ទងតាមគេហទំព័រ Absolute Angels Bangkok មានប្រើប្រាស់គ្រឿងញៀន និងលួចទ្រព្យសម្បត្តិរបស់ពួកគេ។ ក្រោយមក ការស៊ើបអង្កេតក៏រកឃើញថា គេហទំព័រ ដែលផ្សាយពាណិជ្ជកម្មខ្លួនឯងថា សេវាផ្តល់ស្ត្រីកំដរក្នុងរាជធានីបាងកក និងទីក្រុងទេសចរណ៍ផ្សេងទៀត គឺបានផ្តល់សេវាកម្មពេស្យាចារដោយបើកចំហដល់ភ្ញៀវទេសចរបរទេស។

លោកឧត្តមសេនីយ៍ឯក Phakphumphiphat Sujjapan មេបញ្ជាការការិយាល័យអន្តោប្រវេសន៍ បានប្រាប់សន្និសីទសារព័ត៌មានកាលពីថ្ងៃសុក្រថា គេហទំព័រនេះ បានទាក់ទាញការចូលទស្សនាដល់ទៅ ៤២៩ ៥០០ដងក្នុងខែកក្កដា ហើយមានបញ្ជីឈ្មោះស្ត្រីកំដរប្រហែល៨០នាក់នៅតាមកន្លែងជាច្រើន រួមមានទីក្រុងបាងកក ប៉ាតាយ៉ា ភូកេត ឈៀងម៉ៃ និងហួហ៊ីន។ តាមការរកឃើញរបស់ប៉ូលិស, Kanya គឺជាអ្នកគ្រប់គ្រងគេហទំព័រ ដែលទទួលខុសត្រូវទទួលយកការកក់ និងរៀបចំការណាត់ជួបរវាងក្មេងស្រីនិងអតិថិជន ខណៈបុរសជនជាតិអាមេរិក ជាអ្នកទទួលខុសត្រូវចំពោះ

បញ្ហាបច្ចេកទេសពាក់ព័ន្ធនឹងគេហទំព័រ។ ពួកគេទាំងពីរទទួលបាន ៤០% នៃថ្លៃសេវាដែលអតិថិជនបង់។ លើសពីនេះ ប៉ូលិសបានរឹបអូសកុំព្យូទ័រចំនួន៤គ្រឿង ឯកសារពាក់ព័ន្ធ និងវិឡាតម្លៃ១៥លានបាត។ ប៉ូលិសក៏រឹបអូសរថយន្ត Mercedes-Benz មួយគ្រឿងតម្លៃ៣.៥លានបាត រថយន្តហុងដាតម្លៃ១.៨លានបាតមួយគ្រឿង សៀវភៅគណនីធនាគារ១៤ក្បាលដែលមានប្រាក់ប្រហែល៩លានបាត និងភាគហ៊ុនថៃមានតម្លៃ២០លានបាតផងដែរ។ **ប្រែសម្រួល៖** Vann Vann **ប្រភព៖** Nation

## កិច្ចខិតខំប្រឹងប្រែង
## និងសុទិដ្ឋិនិយមក្នុងការលុបបំបាត់ការជួញដូរមនុស្សនៅក្នុងតំបន់អាស៊ាន

https://www.khmertimeskh.com/501345815//?p=1345815 Khmer Times August 20, 2023

នៅចុងខែកក្កដាឆ្នាំ ២០២៣ ក្រុមបង្ក្រាបមកពីនគរបាលក្រុងហ្សាកាតា និងទីស្នាក់ការនគរបាលជាតិបានរកឃើញករណីជួញដូរក្រលៀនសម្រាប់លក់នៅទីផ្សារបរទេសនៅ Bekasi ភាគខាងលិច Java ។ ជាលទ្ធផល នគរបាលបានកំណត់មុខសញ្ញាជនសង្ស័យចំនួន ១៥ នាក់ ដោយក្នុងនោះមាន ៤នាក់បម្រើការនៅការិយាល័យអន្តោប្រវេសន៍នៅកោះបាលី ចំណែកម្នាក់ទៀតជាមន្ត្រីនគរបាលជាតិ។ ក្នុងករណីជួញដូរមនុស្សនេះ នគរបាលបានអោយដឹងថា ក្រុមជួញដូរក្រលៀនមានបណ្ដាញនៅកម្ពុជា និងមានជនរងគ្រោះចំនួន ១២២ នាក់។

ក្នុងចំណោមមនុស្ស ១៥នាក់ តួនាទីរបស់ជនសង្ស័យម្នាក់ៗត្រូវបានគេបង្ហាញថា មនុស្ស ១០ នាក់ជាសមាជិកនៃក្រុមជួញដូរ និងមានសមាជិកម្នាក់ជានគរបាល។ ជាមួយគ្នានេះ មន្ត្រីអន្តោប្រវេសន៍បួននាក់បានជួយជនសង្ស័យឱ្យគេចពីសមត្ថកិច្ចតាមច្រកទ្វារចេញចូលព្រលានយន្តហោះជាថ្នូរនឹងប្រាក់មួយចំនួន។ ការចាប់ខ្លួនបណ្ដាញក្រុមជួញដូរនេះបន្ថែមលើករណីជួញដូរមនុស្សមួយផ្សេងទៀតដែលត្រូវបានអនុវត្តន៍ដោយច្បាប់។

ចាប់តាំងពីលោកប្រធានាធិបតី Joko Widodo បានតែងតាំងឧត្តមសេនីយ៍ Listyo Sigit Prabowo ជាអគ្គស្នងការនគរបាលជាតិឥណ្ឌូនេស៊ី និងជាប្រធានក្រុមការងារប្រឆាំងការជួញដូរមនុស្សកាលពីថ្ងៃទី៥ ខែមិថុនា ជនរងគ្រោះសរុបចំនួន ២,១៩៥ នាក់ត្រូវបានជួយសង្គ្រោះគិតត្រឹមថ្ងៃទី២៧ ខែកក្កដា។ ដោយផ្អែកលើច្បាប់លេខ២១ ឆ្នាំ២០០៧ ការជួញដូរមនុស្សរួមមានសកម្មភាពជ្រើសរើស ដឹកជញ្ជូន បញ្ជូន ឬបង្ខំមនុស្សម្នាក់ដោយកម្លាំង ការចាប់ពង្រត់ ការបង្ខាំងមនុស្ស ក្លែងបន្លំ ការរំលោភបំពានប្រើអំណាច ចំណងបំណុល និងផ្សេងទៀត ដូច្នេះជនល្មើសអាចរំលោភសេរីភាពរបស់ជនរងគ្រោះ ហើយបន្ទាប់មកកេងប្រវ័ញ្ចលើពួកគេ។ ទម្រង់នៃការកេងប្រវ័ញ្ចនៅក្នុងករណីជួញដូរមនុស្សមានចាប់ពីការរួមភេទដោយបង្ខំ ទាសភាព ឬពលកម្មដោយបង្ខំ ការជួញដូរសរីរាង្គ ឬបង្ខំជនរងគ្រោះអោយធ្វើអ្វីមួយដោយគ្មានការយល់ព្រមពីពួកគេ។

យោងតាមទិន្នន័យពីនគរបាលឥណ្ឌូណេស៊ី ប្រភេទនៃឧក្រិដ្ឋកម្មទាក់ទងនឹងការជួញដូរមនុស្សមានភាពខុសៗប្លែកគ្នា ដូចជាការបោកប្រាស់តាមអ៊ីនធឺណិត ឬការក្លែងបន្លំតាមអ៊ីនធឺណិត ល្បែងស៊ីសង ពេស្យាចារ និងការរត់ពន្ធពលករធ្វើការលើនាវា និងពលករធ្វើការតាមផ្ទះ។ ទាក់ទងនឹងការឆបោកតាមអ៊ីនធឺណិត ក្រសួងការបរទេសបានចាត់ថ្នាក់ការជួញដូរ និងឆបោកមនុស្សតាមអ៊ីនធឺណិតជាបញ្ហាក្នុងតំបន់។ ក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ ក្រសួងការបរទេសបានដោះស្រាយករណីក្លែងបន្លំតាមអ៊ីនធឺណិតចំនួន ១,៨២១ ករណី ដែលមានជនរងគ្រោះជាពលរដ្ឋឥណ្ឌូនេស៊ីនៅក្នុងប្រទេសមីយ៉ាន់ម៉ា កម្ពុជា ថៃ វៀតណាម ឡាវ និងហ្វីលីពីន។ ផ្អែកលើទិន្នន័យរបស់អគ្គស្នងការនគរបាលជាតិ ការជួញដូរមនុស្សជារឿយៗគឺសន្យាជួយជនរងគ្រោះទៅធ្វើការនៅបរទេសដោយគ្មាននីតិវិធីច្បាប់ និងមានការចូលរួមពីដៃគូរពាក់ព័ន្ធ ដោយបានបញ្ជូនជនរងគ្រោះទៅប្រទេសដែលបានកំណត់ជាមួយទិដ្ឋាការទេសចរណ៍ និងផ្តល់សំបុត្រយន្តហោះធ្វើដំណើរទៅមក និងរត់ពន្ធជនរងគ្រោះទៅប្រទេសផ្សេងៗទៀត។

លើសពីនេះ ជនរងគ្រោះភាគច្រើនត្រូវបានចងភ្ជាប់ដោយកិច្ចសន្យាការងារដែលបង្ខំពួកគេឱ្យធ្វើការនៅកន្លែងដែលត្រូវបានការពារយ៉ាងតឹងរឹងដោយក្រុមប្រដាប់អាវុធ។ ជនរងគ្រោះក៏ត្រូវបានបង្ខំឱ្យធ្វើការពី ១៦-១៨ ម៉ោងជារៀងរាល់ថ្ងៃ ដោយគ្មានប្រាក់ឈ្នួលសមរម្យ ចំណែកជនដៃដល់មិនស្ទាក់ស្ទើរក្នុងការប្រព្រឹត្តិអំពើហឹង្សាលើរាងកាយជនរងគ្រោះ ប្រសិនជនរងគ្រោះមិនអាចបំពេញការងារដែលបានដាក់អោយ។ ក្រៅពីក្រុមងាយរងគ្រោះ ដូចជាស្ត្រី និងកុមារ ក៏ដូចជាមនុស្សដែលមានការអប់រំទាប ជនល្មើសក៏បានកំណត់គោលដៅលើមនុស្សដែលមានកម្រិតសិក្សាខ្ពស់តាមរយៈកម្មវិធីផ្តល់កម្មសិក្សាក្លែងក្លាយដល់និស្សិតនៅបរទេសផងដែរ។

នៅក្នុងតំបន់អាស៊ាន របាយការណ៍សកលស្តីពីការជួញដូរមនុស្សក្នុងឆ្នាំ២០២២ ដែលដាក់ចេញដោយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) បានបញ្ជាក់ថា សមាមាត្រនៃចំនួនជនរងគ្រោះពីការជួញដូរមនុស្សនៅក្នុងតំបន់អាស៊ីបូព៌ា រួមទាំងប្រទេសឥណ្ឌូនេស៊ី បានឈានដល់ ០.៣៤ នាក់ក្នុងង ១០០ ពាន់នាក់ក្នុងឆ្នាំ២០២២។ ទិន្នន័យរបស់ UNODC សំដៅទៅលើចំនួនជនរងគ្រោះដែលបានរកឃើញ និងកត់ត្រាជាផ្លូវការដោយអាជ្ញាធរ ដូច្នេះតួលេខជាក់ស្តែងអាចខ្ពស់ជាងនេះ។ យោងតាម UNODC បណ្តាប្រទេសនៅអាស៊ីបូព៌ារួមមាន ឥណ្ឌូនេស៊ី ប្រ៊ុយណេ កម្ពុជា ម៉ាឡេស៊ី មីយ៉ាន់ម៉ា សិង្ហបុរី ហ្វីលីពីន ថៃ ម៉ុងហ្គោលី ជប៉ុន និងចិន។ ទន្ទឹមនឹងនេះ ប្រទេសប៉ាស៊ីហ្វិក រួមមាន ហ្វីជី ប៉ាឡៅ តុងហ្គា វ៉ានូអាទូ កោះសូឡូម៉ុន មីក្រូនេស៊ី អូស្ត្រាលី និងនូវែលសេឡង់។

របាយការណ៍បានបង្ហាញថា ភាគច្រើននៃជនរងគ្រោះពីការជួញដូរមនុស្សនៅក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ដែលឈានដល់ ៥៤ភាគរយត្រូវបានកេងប្រវ័ញ្ចលើការងារដោយបង្ខំ ខណៈដែល៣៨ភាគរយត្រូវបានកេងប្រវ័ញ្ចផ្លូវភេទ រួមទាំងពេស្យាចារ ហើយ ៨ភាគរយទៀតត្រូវបានកេងប្រវ័ញ្ចលើទម្រង់ផ្សេងៗទៀត ដែលមានជនរងគ្រោះចាប់ពីកុមាររហូតដល់មនុស្សពេញវ័យ។ ការចូលដៃពីសមាជិកនគរបាលជាតិម្នាក់ និងមន្ត្រីអន្តោប្រវេសន៍បាលី ៤នាក់ ដែលជាប់ពាក់ព័ន្ធនឹងក្រុមឧក្រិដ្ឋកម្មអន្តរជាតិ បង្កើតគំរូមិនល្អសម្រាប់កិច្ចខិតខំប្រឹងប្រែងអនុវត្តច្បាប់ក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែនដ៏ធំនេះ។ ទោះជាយ៉ាងណាក៏ដោយ ការបង្ហាញមុខជនពាក់ព័ន្ធនៅក្នុងឧក្រិដ្ឋកម្មនេះ គឺស្តែងចេញអោយឃើញនូវកិច្ចខិតខំប្រឹងប្រែងកាន់តែប្រសើរឡើងក្នុងការដោះស្រាយបញ្ហាជួញដូរមនុស្ស។

វាកាន់តែមានសារៈសំខាន់ និងបន្ទាន់ក្នុងការដោះស្រាយការជួញដូរមនុស្ស ដោយជារៀងរាល់ឆ្នាំ មានករណីពលករចំណាកស្រុកឥណ្ឌូនេស៊ីបានស្លាប់នៅបរទេស។ កិច្ចខិតខំប្រឹងប្រែងរបស់នគរបាលក្នុងការស៊ើបអង្កេតមន្ត្រីដែលពាក់ព័ន្ធនឹងករណីនេះ គឺជាទម្រង់នៃការទប់ស្កាត់ការកើតឡើងនៃករណីផ្សេងទៀតនាពេលអនាគត។ ទន្ទឹមនឹងនោះ ចំណាត់ការនេះត្រូវបានគេរំពឹងថានឹងធ្វើឲ្យមុខមាត់របស់នគរបាលកាន់តែមានភាពប្រសើរឡើង និងបង្ហាញថាប្រទេសឥណ្ឌូនេស៊ីគោរពសិទ្ធិមនុស្សយ៉ាងខ្លាំង។

ឥណ្ឌូណេស៊ី ក្នុងនាមជាប្រទេសអធិបតេយ្យមួយ មិនត្រឹមតែបានផ្តល់សច្ចាប័នលើអនុសញ្ញាសិទ្ធិមនុស្សផ្សេងៗជាផ្នែកនៃសមាជិកអង្គការសហប្រជាជាតិប៉ុណ្ណោះទេ ថែមទាំងទទួលខុសត្រូវក្នុងការធានានូវអរិយធម៌របស់មនុស្សជាតិ និងសុវត្ថិភាពរបស់ពលរដ្ឋរបស់ខ្លួនពីក្រុមជនឥទ្ធពលអន្តរជាតិ។ ប្រទេសឥណ្ឌូណេស៊ីបានដាក់ចេញច្បាប់ដើម្បីដោះស្រាយករណីជួញដូរមនុស្សតាមរយៈច្បាប់លេខ ២១ឆ្នាំ ២០០៧ ទាក់ទងនឹងការលុបបំបាត់ការជួញដូរមនុស្ស។ ជាងនេះទៅទៀត នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៤២ នៅខែឧសភា ឆ្នាំ២០២៣ ដែលបានប្រារព្ធឡើងនៅទីក្រុង Labuan Bajo ភាគខាងកើត Nusa Tenggara ប្រទេសឥណ្ឌូនេស៊ី បានចុះហត្ថលេខាលើសេចក្តីប្រកាសមួយ ដើម្បីលុបបំបាត់ការជួញដូរមនុស្សនៅកម្រិតតំបន់។

នៅក្នុងកិច្ចប្រជុំអាស៊ាន ប្រទេសឥណ្ឌូនេស៊ីក្នុងនាមជាប្រធានអាស៊ានឆ្នាំ២០២៣ បានស្នើប្រទេសសមាជិកអាស៊ាន ឱ្យរួមគ្នាលុបបំបាត់ការជួញដូរមនុស្ស ដែលបណ្តាលមកពីការប្រើប្រាស់បច្ចេកវិទ្យាខុសទិសដៅ។ ចំណុចសំខាន់ៗចំនួន ១៥ក្នុងកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា និងត្រូវបានអនុវត្តដោយប្រទេសសមាជិកអាស៊ាន ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងជួយជនរងគ្រោះផងដែរ។ បណ្តាប្រទេសអាស៊ានបានយល់ព្រមធ្វើការជាមួយគ្នាដើម្បីបង្កើនសមត្ថភាព

នៃការអនុវត្តច្បាប់ ចែករំលែកការអនុវត្តល្អ និងធ្វើការស៊ើបអង្កេតរួមគ្នាពាក់ព័ន្ធនឹងការជួញដូរមនុស្សឆ្លងដែន។

សេចក្តីប្រកាស ក៏បានយកចិត្តទុកដាក់ជាពិសេសចំពោះជនរងគ្រោះ នៃការជួញដូរមនុស្សដោយជំរុញឱ្យមានស្តង់ដារការពារនៅកម្រិតតំបន់សម្រាប់ជនរងគ្រោះ និងការស្វែងយល់ពីការបង្កើតយន្តការក្នុងតំបន់តាមរយៈយន្តការអាស៊ាន ដើម្បីជៀសវាងការជួញដូរម្តងហើយម្តងទៀត និងការបន្តការកេងប្រវ័ញ្ចលើជនរងគ្រោះ។ សេចក្តីប្រកាសក៏បានសង្កត់ធ្ងន់លើទិដ្ឋភាព នៃការរំលោភបំពានដោយប្រើបច្ចេកវិទ្យា ដោយក្រើនរំលឹកដល់សហគមន៍អាស៊ានទាក់ទងនឹងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសម្រាប់ប្រព្រឹត្តិបទល្មើស។

ការប្រារព្ធទិវាពិភពលោកប្រឆាំងការជួញដូរមនុស្សនៅថ្ងៃទី៣០ ខែកក្កដា ត្រូវបានគេរំពឹងថានឹងជាសន្ទុះមួយក្នុងការប្រមូលផ្តុំកិច្ចសហប្រតិបត្តិការនៅទូទាំងប្រទេសអាស៊ានក្នុងការលុបបំបាត់ការជួញដូរមនុស្ស។ កិច្ចសហប្រតិបត្តិការនេះត្រូវបានគេរំពឹងថានឹងត្រូវបានអនុវត្តនៅគ្រប់កម្រិតក្នុងសង្គម រួមទាំងសហគមន៍មូលដ្ឋានដែលងាយរងគ្រោះ។ ការកេងប្រវ័ញ្ចមនុស្ស ក្នុងទម្រង់នៃការជួញដូរមនុស្ស គឺជាឧក្រិដ្ឋកម្មឆ្លងដែនប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវតែបញ្ឈប់ដោយសារឧក្រិដ្ឋកម្មនេះមានរចនាសម្ព័ន្ធ ប្រព័ន្ធ និងទំនាក់ទំនងស្រដៀងគ្នាទៅនឹងឧក្រិដ្ឋកម្មគ្រឿងញៀន។ ដូច្នេះវាទាមទារការប្តេជ្ញាចិត្តរួមគ្នាដើម្បីលុបបំបាត់វា។ ការបង្កើតក្រុមការងារស្តីពីការជួញដូរមនុស្ស ត្រូវបានគេរំពឹងថានឹងធ្វើការប្រកបដោយប្រសិទ្ធភាព ដើម្បីជួយសង្គ្រោះជនរងគ្រោះ និងបង្ហាញមុខបណ្តាញក្រុមជួញដូរមនុស្ស៕ Antara News

## នៅអាស៊ានតើប្រទេសណាមានពលករចំណាកស្រុកច្រើនជាងគេ?

https://btv.com.kh/article/28613 2023/08/20 01:16:58 pm

***ភ្នំពេញ៖*** អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) កាលពីពេលថ្មីៗកន្លងទៅនេះ បានបញ្ចេញរបាយការណ៍ ស្តីពីទេសន្តរប្រវេសន៍ពិភពលោកឆ្នាំ២០២២ ដោយក្នុងនោះ គត់សម្គាល់ថា នៅតំបន់អាស៊ានមានប្រទេសចំនួន៤ ដែលបានបញ្ជូនពលករទៅបរទេសច្រើនជាងគេទី១ប្រទេសហ្វីលីពីន ទី២ប្រទេសឥណ្ឌូនេស៊ី និងទី៣ប្រទេសភូមា ឬមីយ៉ាន់មា និងទី៤វៀណាម ដោយឡែកប្រទេសផ្សេងទៀតបញ្ជូនក្នុងរង្វង់ត្រឹមជាង១លាននាក់ចុះក្រោម។ អង្គការអន្តរជាតិមួយនេះបានគូសបញ្ជាក់ថា ពលករចំណាកស្រុករបស់ហ្វីលីពីន មានចំនួនជាង៦,១លាននាក់ ខណៈដែលឥណ្ឌូនេស៊ី មានជិត៥លាននាក់ ហើយមីយ៉ាន់ម៉ាឬភូមា មានជាង៣.៧លាននាក់។ ដោយឡែកពលករចំណាកស្រុករបស់វៀតណាម មានជាង៣,៤លាននាក់ ក្នុងពេលដែលឡាវនិង មានជាង១,៣លាននាក់ប្រហាក់ប្រហែលគ្នា។ ទន្ទឹមនឹងនោះ ថៃមានពលករចំណាកស្រុកជាង ១,១លាន នាក់

ដោយឡែក ម៉ាឡេស៊ី និងសិង្ហបូរី ប៉ុណ្ណោះ ដែលមានចំនួនពលករតិចជាងគេ ក្នុងរង្វង់តិចជាង១លាននាក់។ ប្រទេសគោលដៅ ដែលពលករអាស៊ានធ្វើចំណាក់ស្រុកច្រើនជាងគេ គឺអាម៉េរិកខាងជើង អឺរ៉ុប និងប្រទេសធំៗតំបន់មជ្ឈឹមបូព៌ាដូចអារ៉ាប៊ីសាអូឌិត និងអារ៉ាប់រួម និងបណ្ដាប្រទេសរីកចម្រើនក្នុងតំបន់អាស៊ី។

អង្គការអន្តរជាតិដែលជាជំនាញលើបញ្ហាទេសន្តរប្រវេសន៍ដដែលនេះ បានបញ្ជាក់ថា ពលករចំណាក ស្រុកធ្វើការងារដូចជា ការងារបម្រើតាមផ្ទះ សំណង់ កសិកម្ម ឧស្សាហកម្ម និងបដិសណ្ឋារកិច្ចជាដើម។ មិនមានការវាយតម្លៃពីចំណូលជាក់លាក់នៃប្រទេសនីមួយៗ នៃបណ្ដាប្រទេសអាស៊ាន ដែលពលករទាំងអស់បានបញ្ជូនមកប្រទេសដើមវិញនោះទេ។ ប៉ុន្តែអង្គការនេះ បានប៉ាន់ស្មានថាជារួមលើពិភពលោកថា ទឹកប្រាក់ប្រមាណ៥០៤ពាន់លានដុល្លារគឺជាទឹកប្រាក់ដែលហូរចូលទៅប្រទេសក្រីក្រ និងចំណូលកម្រិតទាប ខណៈពលករចំណាកស្រុកទូទាំងពិភពលោក មានប្រមាណ១៦៩លាននាក់។ នេះបើតាមការបញ្ជាក់ដដែល។ ក្នុងពិភពលោក ប្រទេស ដែលមានពលករចំណាកស្រុកច្រើនជាងគេ គឺប្រទេសឥណ្ឌាដែលមានប្រជាជនជាង១៨លាននាក់ បានធ្វើដំណើរទៅបរទេសដើម្បីស្វែងរកការងារធ្វើដែលតាមពីក្រោយដោយប្រទេសម៉ិចស៊ិក ចិន និងរុស្ស៊ីជាដើម។

ដោយឡែកក្នុងក្របខណ្ឌកម្ពុជាវិញ ពលរដ្ឋជាង១,៣លាននាក់ ដែលកំពុងធ្វើការនៅប្រទេសថៃ កូរ៉េខាងត្បូង ជប៉ុន និងបណ្ដាប្រទេសរីកចម្រើនផ្សេងទៀត ហើយក្នុងមួយឆ្នាំៗ ប្រាក់បញ្ញើប្រមាណជាង១ពាន់លានជារៀងរាល់ឆ្នាំ បានហូរចូលក្នុងប្រទេសដើម្បីបំប៉នសេដ្ឋកិច្ចជាតិ។

អង្គការទេសន៍ប្រវេសអន្តរជាតិ បានសង្កត់ធ្ងន់ថា ពលរដ្ឋទាំងអស់មានសិទ្ធិគ្រប់គ្រាន់ក្នុងការជ្រើសរើសកន្លែងធ្វើការដែលជាសិទ្ធិស្វ័យសម្រេចដែលខ្លួនចង់បាន ហើយការស្វែងរកការងារធ្វើដែលភាគច្រើនបំផុតទៅកាន់ប្រទេសរីកចម្រើននេះ គឺជាឱកាសស្វែងរកប្រាក់ចំណូលខ្ពស់ ជំនាញវិជ្ជាជីវៈនៅកន្លែងធ្វើការថ្មី ហើយវាជាការចូលរួមចំណែកគាំទ្រសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក និងអភិវឌ្ឍសង្គម។

សូមបញ្ជាក់ថារឿងពលករនៅកម្ពុជានេះ បានក្លាយជារឿងនយោបាយនៅកម្ពុជាដែលមជ្ឈដ្ឋានប្រឆាំង ឬក្រុមរិះគន់មួយចំនួនបានធ្វើជាលេសដើម្បីវាយប្រហារនិងបំពុលសង្គម។ យ៉ាងណាក៏ដោយ តាមរយៈតួលេខខាងលើនេះ យើងមើលឃើញថា បញ្ហាពលករចំណាកស្រុកនេះ ជារឿងសកលមិនមែនជារឿងដាច់ដោយឡែករបស់កម្ពុជានោះទេ ព្រោះថាពលករចំណាកស្រុកកម្ពុជាមានតិចជាបណ្ដាប្រទេសជិតខាងខ្លាំងណាស់ ហើយប្រៀបធៀបជាមួយអន្តរជាតិនៅតិចខ្លាំងមែនទែន។

មួយវិញទៀត ការធ្វើចំណាកស្រុកនេះ គឺជានិន្នាការសកលដើម្បីឱ្យពលរដ្ឋមានចំណូលកាន់តែខ្ពស់ មានជំនាញ និងចូលរួមអភិវឌ្ឍសង្គមជាតិ។ ទន្ទឹមនឹងនេះ អ្វីដែលត្រូវពិចារណា គឺយន្តការការពារពលកររបស់រដ្ឋនីមួយៗដើម្បីធានាថា ពលរដ្ឋបានធ្វើការដោយស្របច្បាប់ គ្មានការរំលោភបំពាន និងទទួលបានអត្ថប្រយោជន៍ទៅតាមប្រទេសអ្នកទទួល។ សម្រាប់អ្នកតាមដានសង្គមកម្ពុជា ប្រធានបទនេះគួរលែងក្លាយជាប្រធានបទនៃការរិះគន់ដោយគ្មានការពិចារណាហើយបំពុលសង្គមតទៅទៀត៕ ដោយៈ សុវណ្ណ ធរណិន្ទសាគរ

## គួរប្រុងប្រយ័ត្នបំផុត!ទុកចិត្តមិនបានទេ ក្មេងៗសោះបែកគំនិតធ្វើរឿងបែបនេះ ទីបំផុតត្រូវសមត្ថកិច្ចនគរបាលស្រុកភ្នំព្រឹកឃាត់ខ្លួន

https://postnews.com.kh/local/658199?fbclid=IwAR3OiOVBKVG7m31BMDfrwX603Cx8RFIMJLkOmZlDZ8oO2RKf3cIrVo3oTfg ថ្ងៃពុធ, ទី16 ខែខែសីហា, 2023 07:34 ព្រឹក 0 Comments

បាត់ដំបង:កាលពីថ្ងៃអាទិត្យ ១២រោចខែទុតិយាសាឍឆ្នាំថោះបញ្ចស័កព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០២៣ វេលាម៉ោង ១៧និង៥០នាទី អនុវត្តតាមយោបល់ដឹកនាំបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង និងលោកស្រីឧត្តមសេនីយ៍ត្រី រស់ ជីវី ស្នងការរងផែនការងារ ប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជននិងការងារយេនឌ័រនៃស្នងការដ្ឋាន និងដោយបានការសម្រប សម្រួលលើនីតិវិធីពីឯកឧត្តម កែវ សុជាតិ ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តបាត់ដំបងផងនោះ លោក វរសេនីយ៍ទោ ហេង បារាំង អធិការនៃនគរបាលស្រុកភ្នំព្រឹក បានដឹកនាំកម្លាំងធ្វើការស្រាវជ្រាវនិងឃាត់ខ្លួន ក្រុមយុវជនមួយក្រុមមានគ្នាចំនួន ០៨នាក់ ពាក់ព័ន្ធក្នុងករណីផលិតរូបភាពអាសអាភាស(លួចថតរូបជនរងគ្រោះ)និងចែកចាយរូបភាពនេះជាសាធារណៈក្នុងបណ្ដាញសង្គម។

ជនសង្ស័យទាំង០៨នាក់នោះរួមមានៈ

១-ឈ្មោះ អឿន ភារម្យ ភេទប្រុសអាយុឆ្នាំ រស់នៅ ស្រុកភ្នំព្រឹក ខេត្ត បាត់ដំបង មុខរបរ (១៦/១១/២០០៦)

២-ឈ្មោះ ង៉ូវ ហុង ភេទប្រុស អាយុ ឆ្នាំរស់នៅស្រុកភ្នំព្រឹក ខេត្ត បាត់ដំបង (០៣/០៦/២០០៧)

៣-ឈ្មោះ តែម សុខរិន ភេទប្រុស អាយុ ឆ្នាំរស់នៅ ស្រុកភ្នំព្រឹក ខេត្ត បាត់ដំបង (១២/០៤/២០០៧)

៤-ឈ្មោះ សាយ សៀកម៉េង ភេទប្រុសអាយុ-ឆ្នាំរស់នៅ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង(០៣/០២/២០០៨)

៥-ឈ្មោះ គាត ណារ៉ុង ភេទប្រុសអាយុ- ឆ្នាំរស់នៅ ស្រុកភ្នំព្រឹក ខេត្ត បាត់ដំបង(០៥/០៩/២០០៨)

៦-ឈ្មោះ ជឿន មករា ភេទប្រុស អាយុ -ឆ្នាំ រស់នៅភូមិផ្លូវ៦ ឃុំតាគ្រាំ ស្រុកកម្រៀង ខេត្ត បាត់ដំបង

មុខរបរ សិស្ស(១៣/០១/២០០៩)

៧-ឈ្មោះ ផាន វុធថា ភេទប្រុស អាយុ -ឆ្នាំ រស់នៅស្រុកកម្រៀង ខេត្ត បាត់ដំបង (០៩/ ០៥/ ២០០៩)

៨-ឈ្មោះ ពឿន សុវណ្ណដា ភេទប្រុស អាយុ -ឆ្នាំ រស់នៅ ស្រុកភ្នំព្រឹក ខេត្ត បាត់ដំបង ។

លោកវរសេនីយ៍ទោ ហេង បារាំង អធិការនគរបាលស្រុកភ្នំព្រឹកបានឱ្យដឹងថា នៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០២៣វេលាម៉ោង១៨និង៣០ នាទី នៅចំណុចក្រុម ទី១១ ស្ថិតភូមិភ្នំតូច ឃុំពេជ្រចិន្ដា ស្រុកភ្នំព្រឹក ខេត្ត បាត់ដំបង មានការភ្ញាក់ផ្អើលមួយបន្ទាប់ពីនារីជាជនរ ងគ្រោះដែលបានជួលបន្ទប់ស្នាក់នៅរួមគ្នាចំនួន ០៥ នាក់ ដើម្បីរៀនសូត្រក្នុងមូលដ្ឋានខាង លើបានប្រទះឃើញរូបភាព(អាក្រាតកាយ)របស់ពួកខ្លួនត្រូវបានចែកចាយក្នុង បណ្ដាញសង្គមដែលរូបភាពទាំងនេះ គឺត្រូវបានគេលួចថតជាឃ្លីបវីដេអូ ក្នុងពេលដែលជន រងគ្រោះកំពុងងូតទឹក ក្នុង បន្ទប់ទឹក នៃបន្ទប់ជួលស្នាក់នៅរបស់ខ្លួន។

តាមរយៈរូបភាពបែបនេះ ជនរងគ្រោះបានផ្ដល់ព័ត៌ មានដល់អាណាព្យាបាលរបស់ខ្លួន និង បានដាក់ពាក្យបណ្ដឹង មកសមត្ថកិច្ចនគរបាលស្រុកភ្នំព្រឹកដើម្បីជា សមត្ថកិច្ចក្នុងរឿងនេះ ។ ផ្ដើមពីការស្រាវជ្រាវជាបន្ទាន់ សមត្ថកិច្ច នគរបាលបានឈានដល់ការឃាត់ខ្លួនក្រុមក្មេងៗខាងលើ ក្នុងរឿងជាក់ស្ដែងដែលពួកគេជាអ្នកជួលបន្ទប់ស្នាក់នៅជាប់គ្នាជាមួយ បន្ទប់របស់ជនរងគ្រោះ។ ហើយការសាកសួរក៏ត្រូវចាប់ផ្ដើមឡើង ដែលក្រុមក្មេងទាំងនេះ បានឆ្លើយសារភាពថា ពួកខ្លួនបានយកទូរស័ព្ទដែលលួចថតជាឃ្លីបវីដេអូខណៈដែលនារីរងគ្រោះចូលទៅងូតទឹកក្នុងបន្ទប់ទឹកជាប់គ្នា ដែលមានការធ្លុះធ្លាយ(មើលឃើញ) ហើយពេលថតបានក៏យករូបភាពនេះទៅមេើលផងនិងចែកចាយដល់អ្នកផ្សេងមើល ជាការកម្សាន្តហើយពេលសមត្ថកិច្ចនគរបាលធ្វើការពិនិត្យក្នុងទូរស័ព្ទរបស់ពួកគេរកឃើញឃ្លីបវីដេអូពីរូបភាពអាក្រាតកាយជនរងគ្រោះចំនួន ១៩វីដេអូឃ្លីបឯណោះ ។

នៅពេលនេះសមត្ថកិច្ចនគរបាលរៀបចំសំណុំរឿងបញ្ជូនជនសង្ស័យនិងវត្ថុតាងពាក់ព័ន្ធមកកាន់ផែនជំនាញ ដើ ម្បីអនុវត្តបន្តតាមផ្លូវច្បាប់ហើយ។ រឿងមួយនេះគឺជាមេរៀនសម្រាប់មហាជនទូទៅដែលគប្បីពិនិត្យមើលចំ ពោះ ទីតាំងស្នាក់នៅឬទីកន្លែងមួយចំនួនដូចជាបន្ទប់ទឹកជាដើមដែលប្រេីប្រាស់ប្រចាំថ្ងៃ ចៀសវាងនូវករណីឆ្វេសប្រហែសណាមួយដែល នាំ ឱ្យជនកំហូចលួចធ្វើសកម្មភាពបែបនេះបាន ៕

# ថ្ងៃទី២២ ខែ សីហា ឆ្នាំ២០២៣

## នគរបាលស្រុកជាំក្សាន្ត
## ឃាត់ខ្លួនជនសង្ស័យម្នាក់ជាប់ពាក់ព័ន្ធករណីជួញដូរមនុស្សទៅប្រទេសចិន

https://cen.com.kh/archives/687732.html Posted ByPen Srey NeatAugust 21, 2023

*ខេត្តព្រះវិហារ ៖ ស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ បានឲ្យដឹងថា នាថ្ងៃទី២០ ខែសីហា ឆ្នាំ ២០២៣ កម្លាំងជំនាញការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាន នគរបាលខេត្តព្រះវិហារ សហការជាអធិការដ្ឋាននគរបាលស្រុកជាំក្សាន្ត បានធ្វើការឃាត់ខ្លួនជន សង្ស័យចំនួន ០១នាក់ ឈ្មោះ ផន ទូច ភេទស្រី អាយុ ៦១ឆ្នាំ ជនជាតិខ្មែរ មុខរបរ កសិករ រស់នៅ ភូមិសែនរុងរឿង៤ ឃុំមរកត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដែលជាប់ពាក់ព័ន្ធករណីជួញដូរមនុស្ស (នាំចេញក្រៅភូមិសាស្ត្រដោយមានគោលដៅ) ប្រទេសចិន កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ នៅចំណុចផ្ទះជនរងគ្រោះ ស្ថិតក្នុងភូមិសែនរុងរឿង៤ ឃុំមរកត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។*

*ជនសង្ស័យខាងលើ សមត្ថកិច្ចជំនាញបានកសាងសំណុំរឿងបញ្ជូនទៅអយ្យការអមសាលា ដំបូងខេត្ត ចាត់ការតាមច្បាប់។ រក្សាសិទ្ធដោយ ៖ សុទ្ធលី*

## ក្រសួងការបរទេសតៃវ៉ាន់ និងរដ្ឋអាជ្ញា Kaohsiung ត្រូវបានគេរិះគន់ជុំវិញករណីឆបោក ការងារនៅកម្ពុជា និងនៅកន្លែងផ្សេងទៀត

https://www.khmertimeskh.com/501346410// Khmer Times August 21, 2023

*អាជ្ញាធរ* Control Yuan *កាលពីថ្ងៃសុក្រ បានរិះគន់ក្រសួងការបរទេស និងការិយាល័យរដ្ឋ អាជ្ញាស្រុក* Kaohsiung *ជុំវិញករណីជាច្រើន ដែលពាក់ព័ន្ធនឹងជនជាតិតៃវ៉ាន់ ត្រូវបានគេបោក បញ្ឆោតឱ្យទៅបណ្តាប្រទេសអាស៊ីអាគ្នេយ៍ ដោយពួកគេត្រូវបានគេបង្ខំឱ្យធ្វើការឱ្យក្រុមឆបោក។ នៅក្នុងសេចក្តីថ្លែងការណ៍មួយ អ្នកឃ្លាំមើលរដ្ឋាភិបាលបាននិយាយថា សមាជិកអាជ្ញាធរ* Control Yuan *លោក* Yeh Ta-hua *និង លោក* Chi Hui-jung *នឹងធ្វើសន្និសីទសារព័ត៌មានមួយនៅថ្ងៃទី២១ ខែ សីហា ដើម្បីរៀបរាប់លម្អិតអំពីមូលហេតុក្នុងការរិះគន់។ អ្នកទាំងពីរកំពុងស៊ើបអង្កេតករណីដែល មានជនជាតិតៃវ៉ាន់មួយចំនួនធំត្រូវបានគេបោកបញ្ឆោតដោយផ្តល់ការងារក្លែងក្លាយនៅប្រទេសកម្ពុ ជា ឬមីយ៉ាន់ម៉ា ដោយគិតថាពួកគេនឹងទទួលបានប្រាក់ខែច្រើន ក្នុងតំណែងលេខា ឬជាបុគ្គលិកសេ វាកម្មអតិថិជន។*

*តាមប្រភពព័ត៌មានបានឲ្យដឹងថា នៅពេលដែលមានជនរងគ្រោះត្រូវបានបង្ខំឱ្យផ្តល់ឯកសារ អត្តសញ្ញាណរបស់ពួកគេ ពួកគេមិនត្រូវបានអនុញ្ញាតឱ្យចាកចេញពីបរិវេណឡើយ ។ ជនរងគ្រោះ*

ត្រូវបានបង្ខំអោយបោកប្រាស់ជនជាតិចិនផ្សេងទៀតតាមទូរស័ព្ទ ឬផ្ញើសារ ហើយអ្នកដែលដែលមិនធ្វើតាម ត្រូវបានគេធ្វើទារុណកម្ម នេះបើយោងតាមរបាយការណ៍ប្រព័ន្ធផ្សព្វផ្សាយ។

លោក Yeh Ta-hua និង លោក Chi Hui-jung បាននិយាយថាពួកគេនឹងស៊ើបអង្កេតថាតើអាជ្ញាធរតៃវ៉ាន់បានចាត់វិធានការបុរេសកម្ម ក្នុងការបង្ក្រាបឧក្រិដ្ឋកម្មដែលបានរៀបចំដោយរបៀបណា ថាតើពួកគេបានធ្វើការផាកពិន័យដល់ភាគីដែលមានកំហុសបានត្រឹមត្រូវដែរឬទេ និងបានផ្តល់ជនរងគ្រោះនូវជំនួយសំខាន់ៗ និងថាតើពួកគេបានបង្កើនមន្ត្រីស៊ើបអង្កេតឧក្រិដ្ឋកម្មដើម្បីការពារករណីស្រដៀងគ្នា កុំឱ្យកើតមានជាថ្មីម្តងទៀតដែរឬអត់៕ Focus Taiwan

# ថ្ងៃទី២៤ ខែ សីហា ឆ្នាំ២០២៣

## លោកស្រី ជូ ប៊ុនអេង ប្រាប់មន្ត្រីពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ធ្វើសកម្មភាពជាក់ស្តែង កុំឲ្យមានតែរចនាសម្ព័ន្ធលើក្រដាស

https://freshnewsasia.com/index.php/en/localnews/306578-2023-08-23-05-48-29.html 2023-08-23 12:48pm

**(ភ្នំពេញ)៖** លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានប្រាប់ដល់មន្ត្រីពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ធ្វើសកម្មភាពជាក់ស្តែងតាមរចនាសម្ព័ន្ធ ដោយកុំឲ្យមានតែរចនាសម្ព័ន្ធលើក្រដាស។ ការជំរុញរបស់មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ បានធ្វើឡើងនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ ក្នុងឱកាសអញ្ជើញបើកវគ្គបណ្តុះបណ្តាល ស្តីពី «ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប» នៅរាជធានីភ្នំពេញ សម្រាប់ក្រុមទី១ (ខេត្តកំពង់ធំ)។

បើតាមការថ្លែងរបស់លោកស្រី ជូ ប៊ុនអេង មន្ត្រីថ្នាក់មូលដ្ឋាន ដែលស្ថិតក្រោមគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានរចនាសម្ព័ន្ធច្បាស់លាស់ណាស់ ប៉ុន្តែបែរជាបណ្តែតបណ្តោយឲ្យមានឧក្រិដ្ឋជន ធ្វើសកម្មភាពបានទៅវិញ។ ប្រការនេះហើយ ដែលលោកស្រីមិនចង់ឃើញឈ្មោះមន្ត្រី មានតែនៅក្នុងរចនាសម្ព័ន្ធលើក្រដាស ហើយគ្មានសកម្មភាពជាក់ស្តែង។

លោកស្រីបានផ្តាំថា តំណែងមិនមានឫងរឹងសម្រាប់ការពារនោះទេ ហេតុនេះហើយលោកស្រីបានជំរុញឲ្យមន្ត្រី ខិតខំប្រឹងប្រែងធ្វើការងារបន្តទៀត ដើម្បីរួមគ្នាទប់ស្កាត់នឹងអំពើជួញដូរមនុស្ស ដែលពិតពលោកកំពុងតែធ្វើសកម្មភាពយ៉ាងខ្លាំង។

សូមជម្រាបថា រាជរដ្ឋាភិបាលកម្ពុជា បានធ្វើសកម្មភាពឥតឈប់ឈរ ដើម្បីការពារប្រជាជនខ្លួន រួមទាំងជនបរទេស រស់នៅលើទឹកដីកម្ពុជា ពីអំពើជួញដូរមនុស្ស។

## បែកធ្លាយវីដេអូ
## ចៅកែចិនហៅស្រីស្អាត ថតននលគក ក្នុងបន្ទប់សណ្ឋាគារមួយនៅក្រុងព្រះសីហនុ

https://kohsantepheapdaily.com.kh/article/1790976.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ២២ ខែ សីហា ឆ្នាំ ២០២៣ ម៉ោង ២១:៤២

ខេត្តព្រះសីហនុ ៖ បែកធ្លាយវីដេអូឃ្លីប នៅលើបណ្តាញសង្គមហ្វេសប៊ុក កាលពីយប់ថ្ងៃទី ២១ ខែសីហា ឆ្នាំ២០២៣ ដោយនារីស្រស់ស្អាតម្នាក់ អះអាងថា ត្រូវបានចៅកែចិន ហៅរូបនាងឲ្យមកថតរូបននលគក ក្នុងបន្ទប់សណ្ឋាគារអន្តរជាតិ ហ្វ៊ីងហ្វូវ នៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។ បើតាមគណនីហ្វេសប៊ុកឈ្មោះ Pa Pu បានរៀបរាប់ថា ៖ «នៅជាន់ទី២ បន្ទប់៨២១៧ ចៅកែចិន ហៅមកថតស្រា-ត រូបនាងស្មានហៅមកធ្វើការ កុហកនាង ហើយថា ជូនមកផ្ទះ មកដល់ក្រោម មិនជូនទៀត ថ្ងៃតាក់ស៊ី ក៏មិនអោយ ជួញដូរផ្លូវភេទ និងប្រើប្រាស់ គ្រឿងញៀនទៀត បញ្ជាក់តែជាន់ទី ២ បន្ទប់៨២១៧ តែប៉ុណ្ណោះ។ ជួយចែករំលែក ចាប់វាអោយអស់ទៅ រូបនាងថា នេះទឹកដីខ្មែរ ប៉ុន្តែវាថា ខ្មែរៗទៅ វាខ្ជាចអី ចង់សើច វាមកស្រុកខ្មែរ មើលងាយប្រទេសយើង។ សូមសមត្ថកិច្ចជួយចាត់វិធានការលើសណ្ឋាគារ និងលេខបន្ទប់ ដែលខ្ញុំនិយាយខាងលើមួយនេះផង» ។

## គណៈកម្មាធិការ
## ប្រឆាំងការជួញដូរមនុស្សជំរុញមន្ត្រីខិតខំបំពេញការងារឲ្យមានប្រសិទ្ធភាពខ្ពស់

https://www.khmertimeskh.com/501348401// តន វិបុល / Khmer Times August 24, 2023

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានជំរុញឲ្យមន្ត្រីពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សត្រូវខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីប្រសិទ្ធភាពនៃការជួយសង្គ្រោះជនរងគ្រោះពីអំពើជួយដូរមនុស្ស និងឈានដល់ការបង្ក្រាបជនល្មើសទាន់ពេលវេលា។ ការជំរុញនេះ ធ្វើឡើងក្នុងវគ្គបណ្តុះបណ្តាលស្តីពី «ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប» ដល់មន្ត្រីជំនាញមកពីខេត្តកំពង់ធំ និងព្រៃវែង ដែលរៀបចំធ្វើឡើងនៅរាជធានីភ្នំពេញពីម្សិលមិញ។

លោកស្រីបានបញ្ជាក់ថា ការរៀបចំកម្មវិធីបណ្តុះបណ្តាលនេះ ផ្តោតសំខាន់លើការកំណត់អត្តសញ្ញាណបឋមរបស់ជនរងគ្រោះពីអំពើជួញដូរមនុស្ស ប៉ុន្តែដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះបានលុះត្រាតែពួកគេសហការជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ច ដើម្បីបន្តស៊ើបអង្កេតស្វែងរកអត្តសញ្ញាណជនល្មើស។ លោកស្រីបន្តថា ក្នុងដំណាក់កាលនេះ គណៈកម្មាធិការជាតិកំពុងពិនិត្យ និងកែលម្អលើបទដ្ឋាន និងយុទ្ធសាស្ត្រ ដែលបានអនុវត្តតាំងពីឆ្នាំ២០១៥មកម្ល៉េះ។ ក្រោយពីការកែលម្អរួចហើយ គណៈកម្មាធិការជាតិនឹងចុះបណ្តុះបណ្តាលមន្ត្រីរបស់ខ្លួននៅទូទាំងប្រទេស។ លោកស្រីបានបន្ថែមថា កម្មវិធីនេះ គឺជាការបណ្តុះបណ្តាលដល់មន្ត្រីជួរមុខ ដែលអនុវត្តការងារនៅតាមមូលដ្ឋាន ព្រោះពួកគេមានឱកាសជួបផ្ទាល់ជាមួយប្រជាពលរដ្ឋដែលងាយស្រួលដល់ការកំណត់អត្តសញ្ញាណជនរងគ្រោះពិតប្រាកដពីអំពើជួញដូរមនុស្ស។

លោកស្រីមានប្រសាសន៍ថា៖ «ប្រសិនបើយើងកំណត់អត្តសញ្ញាណមិនបានត្រឹមត្រូវទេ គឺស្មើនឹងយើងមិនបានជួយដល់ជនរងគ្រោះពិតប្រាកដទេ។ បន្ថែមលើសពីនេះ គឺនៅពេលខ្លះមានជនក្លែងបន្លំជាជនរងគ្រោះដោយសារការជួញដូរមនុស្ស ហើយពេលខ្លះទៀតពួកគេជាជនរងគ្រោះដែរ ប៉ុន្តែមិនមែនជាជនរងគ្រោះដោយសារអំពើជួញដូរមនុស្សឡើយ»។ លោកបានបញ្ជាក់បន្ថែមថា៖ «ដូច្នេះប្រសិនបើយើងជាមន្ត្រី ជាសមត្ថកិច្ចផ្នែកនេះមិនសហការគ្នាទេ គឺយើងមិនអាចតាមចាប់ជនល្មើសដែលមានបណ្តាញច្រើនឡើយ ព្រោះពួកគេមិនបញ្ឈប់ ឬមួយលះបង់ការប្រព្រឹត្តអំពើឧក្រិដ្ឋកម្មជួញដូរមនុស្សនោះទេ»។

លោកស្រីសង្កត់ធ្ងន់ថា ក្រោមហេតុផលនេះហើយដែលចាំបាច់ត្រូវកំណត់អត្តសញ្ញាណ និងទិន្នន័យឱ្យបានច្បាស់លាស់ដើម្បីជួយសង្គ្រោះជនរងគ្រោះដោយសារអំពើជួញដូរមនុស្សពិតប្រាកដ ហើយក៏មានបំណងតាមដានរូបភាពជួញដូរមនុស្សមានការប្រែប្រួលដូចម្តេច។ ចំណែកមន្ត្រីជួរមុខ គឺចំណុចសំខាន់បំផុត ក្នុងការធ្វើសកម្មភាពលើកិច្ចការនេះ។ ដូច្នេះមន្ត្រីទាំងនោះចាំបាច់ត្រូវទទួលបានការពង្រឹងសមត្ថភាពនេះ។ លោកស្រី បានលើកឡើងថា ជនរងគ្រោះពីការជួញដូរមនុស្សភាគច្រើន ជាអ្នកដែលត្រូវបានគេនាំចេញទៅក្រៅកន្លែងផ្សេងៗ។ នៅពេលពួកគេត្រឡប់មកវិញ មន្ត្រីជួញមុខនឹងចុះជួបផ្ទាល់ជាមួយពួកគេ ដែលអាចជាជនរងគ្រោះពីអំពើជួញដូរមនុស្ស។ ប្រសិនបើពួកគេជាជនរងគ្រោះពិតប្រាកដ មន្ត្រីគណៈកម្មាធិការជាតិនឹងជួយតាមសេចក្តីត្រូវការរបស់ពួកគេ។

សម្រាប់ឆមាសទី១ ឆ្នាំ២០២៣នេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានរកឃើញអំពើជួញដូរមនុស្សប្រមាណ៨០ករណី ដែលក្នុងនោះមានទាំងការជួញដូរផ្លូវភេទ និងការជួញដូរកម្លាំងពលកម្ម។ ចំណែកករណីជួយសង្គ្រោះជនរងគ្រោះពីអំពើជួញដូរមនុស្ស លោក

ស្រី ជូ ប៊ុនអេង មិនអាចទាន់បញ្ជាក់បាននៅឡើយទេ ព្រោះលោកស្រីមិនទាន់មានទិន្នន័យនៅក្នុងដៃ។

# ថ្ងៃទី២៥ ខែ សីហា ឆ្នាំ២០២៣

## ឃាត់ខ្លួនមនុស្ស ២ នាក់ ពាក់ព័ន្ធការជួញដូរគ្រលៀននៅ ទីក្រុងហាណូយ

https://www.kampucheathmey.com/global-news/564972 ថ្ងៃព្រហស្បតិ៍ ២៤ សីហា ២០២៣ ដោយ Boa Sokunveary

កាលពីថ្ងៃអង្គារ ទី២២ ខែសីហា ប៉ូលិសប្រកាសថា ចាប់បានឈ្មួញជួញដូរគ្រលៀនមនុស្ស ២ នាក់ ពេលនេះកំពុងឃុំឃាំង រង់ចាំការស៊ើបអង្កេតបន្ត ។ អ្នកទាំងពីរមានឈ្មោះថា N.V.C. អាយុ ៤៣ ឆ្នាំ រស់នៅខេត្ត Phu Tho ភាគខាងជើង និង N.T.P. អាយុ ៣៥ ឆ្នាំជាអ្នករស់នៅទីក្រុង Hai Phong ភាគខាងជើងប្រទេសវៀតណាមដូចគ្នា ។ លទ្ធផលស៊ើបអង្កេតបឋមបានបង្ហាញថា អ្នកទាំងពីរស្គាល់គ្នានៅមន្ទីរពេទ្យ Viet Duc ក្នុងទីក្រុងហាណូយកាលពីឆ្នាំ ២០២១ ហើយបានរក្សាទំនាក់ទំនងគ្នារហូតមកដល់ឥឡូវ ។

នៅដើមឆ្នាំនេះ ពួកគេបានរួមដៃគ្នាជួញដូរគ្រលៀនមនុស្ស ដើម្បីរកលុយ ព្រោះឃើញថាមានមនុស្សជាច្រើននៅលើ Facebook ត្រូវការទិញ និងលក់គ្រលៀន ។ ក្រោយមកមានបុគ្គលម្នាក់ឈ្មោះ H. អាយុ ៣៣ ឆ្នាំ រស់នៅ Phu Tho ចង់លក់គ្រលៀនរបស់គាត់ ទើបពួកគេទាក់ទងទៅចរចាតម្លៃ ។ លោក N.T.P. បានណែនាំលោក H. ឱ្យទៅពិនិត្យសុខភាពនៅមន្ទីរពេទ្យ Viet Duc ហើយឲ្យតម្លៃគ្រលៀននោះ ១៧ ៦៦៦ ដុល្លារ ខណៈអ្នកទិញយល់ព្រមឲ្យតម្លៃដល់ទៅ ៤២ ០៦៣ ដុល្លារ ឯណោះ ។

N.V.C. និង N.T.P. បានរ៉ាប់រងលើការពិនិត្យសុខភាព និងការរស់នៅរបស់ H. រហូតដល់ H. វះកាត់យកគ្រលៀនចេញនៅថ្ងៃទី៩ ខែមករា ឆ្នាំ២០២៣ ។ បន្ទាប់ពីកាត់ការចំណាយរួចរាល់ N.V.C. បានផ្ទេរប្រាក់ ១៧ ៦៦៦ ដុល្លារទៅឲ្យ H. និង ១១ ៥៣៧ ដុល្លារ ទៅឲ្យ N.T.P. ដែលនៅសល់ប៉ុន្មានជារបស់ខ្លួន ។ ពេលនេះនគរបាលស្រុក Hoan Kiem កំពុងបំពេញនីតិវិធី ដើម្បីចាត់ការតាមនិតិវិធីច្បាប់ហើយ ព្រោះជាបទល្មើសដែលអាចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត យោងតាមក្រមព្រហ្មទណ្ឌវៀតណាម ។ **ប្រែសម្រួល៖ វារី** ប្រភព៖ tuoitrenews

# ថ្ងៃទី២៨ ខែ សីហា ឆ្នាំ២០២៣

## អាជ្ញាធរថ្នាក់ក្រោមជាតិត្រូវបាន
## បណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស

https://www.postkhmer.com/national/2023-08-24-1839-253890.html *ជា សុខនី* | Publication date 24 August 2023 | 18:39 ICT

***ភ្នំពេញ:*** *ក្រសួងមហាផ្ទៃ និងអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) បានសហការគ្នារៀបចំបើកវគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទៅដល់អាជ្ញាធរថ្នាក់ក្រោមជាតិក្នុងខេត្តព្រៃវែង និងកំពង់ធំ ដើម្បីឱ្យមន្ត្រីទាំងនោះផ្តល់សេវាគាំពារសមស្របបានទាន់ពេលវេលា។*

*វគ្គបណ្តុះបណ្តាលនេះ ត្រូវបានធ្វើឡើងនៅរាជធានីភ្នំពេញ នាថ្ងៃទី២៣ ខែសីហា ក្រោមអធិបតីលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃនិងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងលោកស្រី គ្រីស្ទីន ផាកូ ប្រធានបេសកកម្មអង្គការIOM ប្រចាំកម្ពុជា រួមជាមួយនិងមន្ត្រីក្រសួងសង្គមកិច្ចផងដែរ។ នេះបើយោងតាមទំព័រហ្វេសប៊ុករបស់លោកស្រី ជូ ប៊ុនអេង។ ប្រភពដដែលបានឱ្យដឹងទៀតថា សិក្ខាកាមដែលអញ្ជើញចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ មានលោក លោកស្រី ជាមន្ត្រីថ្នាក់ក្រោមជាតិអាជ្ញាធរដែនដី អភិបាល អភិបាលរងស្រុក ស្នងការរង អធិការ អធិការរង និងមន្ត្រីនគរបាលដែលអញ្ជើញមកពីខេត្តព្រៃវែង និងខេត្តកំពង់ធំ។*

*លោកស្រី ជូ ប៊ុនអេងរដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានថ្លែងថា ការបើកវគ្គបណ្តុះបណ្តាលនេះឡើង ក្នុងគោលបំណង ដើម្បីពង្រឹងសមត្ថភាពមន្ត្រីអ្នកអនុវត្តន៍ការងារ ថ្នាក់ក្រោមជាតិ ឱ្យទទួលបានចំណេះដឹង ក្នុងការសង្កេត សាកសួរ ប្រមូលព័ត៌មាន ស្វែងរកភាពរងគ្រោះរបស់បុគ្គលដែលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស ឱ្យអាចសន្និដ្ឋានឈានទៅធ្វើការសន្មតជាបណ្តោះអាសន្នថា «ជាជនរងគ្រោះ» ដើម្បីផ្តល់កិច្ចការពារ ការគាំពារ និងផ្តល់សេវាសមស្របជួយជនរងគ្រោះឱ្យបានទាន់ពេលវេលា ប្រកបដោយមនុស្សធម៌ មិនរើសអើង ដោយមិនទាន់គិតអំពីការសង្កេត ស្រាវជ្រាវផ្សេងទៀតតាមនីតិវិធីតុលាការដែលចាំបាច់។*

*លោកស្រីបញ្ជាក់ថា៖ «មន្ត្រីថ្នាក់មូលដ្ឋាន ដែលស្ថិតក្រោមគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានរចនាសម្ព័ន្ធច្បាស់លាស់ណាស់ ប៉ុន្តែបែរជាបណ្តែតបណ្តោយឱ្យមានឧក្រិដ្ឋជន ធ្វើសកម្មភាពបានទៅវិញ។ ប្រការនេះហើយ ដែលយើងមិនចង់ឃើញឈ្មោះមន្ត្រីមានតែនៅក្នុងរចនាសម្ព័ន្ធលើក្រដាស ហើយគ្មានសកម្មភាពជាក់ស្តែង»។*

ជុំវិញរឿងនេះ លោក អំ សំអាត នាយកទទួលបន្ទុកកិច្ចការទូទៅ នៃអង្គការការពារសិទ្ធិមនុស្សលីកាដូ បានថ្លែងថា ការរៀបចំរបស់ក្រសួងក្នុងការពង្រឹងសមត្ថភាព និងបង្កើនចំណេះដឹងទៅដល់អាជ្ញាធរថ្នាក់ក្រោមជាតិទាក់ទងនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សគឺជារឿងចាំបាច់។ លោកថា៖« ពីព្រោះមិនថានៅកម្ពុជា ឬបណ្ដាប្រទេសផ្សេងនោះទេ អំពើជួញដូរមនុស្សនៅតែជាក្ដីបារម្ភ ខណៈដែលរដ្ឋាភិបាលសហរដ្ឋអាមេរិក នៅតែដាក់ចំណាត់ថ្នាក់កម្ពុជាចូលទៅក្នុងបញ្ជីខ្មៅនៃអំពើជួញដូរមនុស្ស»។ លោកបន្តថា ដូច្នេះហើយកម្ពុជា ត្រូវតែមានយន្តការ និងការរៀបចំឱ្យបានត្រឹមត្រូវនៅក្នុងការជួយលើកកម្ពស់ទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាពិសេសគឺការស្ដារនីតិសម្បទាជនរងគ្រោះទាំងនោះឡើងវិញ។

លោក អំ សំអាត លើកឡើងថា៖ «ស្ថានភាពបច្ចុប្បន្ននេះ ខ្ញុំយល់ថាការផ្ដល់សេវាគាំពារពីអាជ្ញាធរមូលដ្ឋានដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស គឺវានៅមិនទាន់គ្រប់គ្រាន់នោះទេ និងមិនទាន់មានការឆ្លើយតបទាន់ពេលវេលាសម្រាប់គាត់ ពីព្រោះបញ្ហានៃការគាំពារទៅលើជនរងគ្រោះនៅមានការរើសអើង និងមិនសមស្របតាមស្ថានភាពសង្គម។ជាពិសេសគឺមិនសូវមានមណ្ឌល ឬក៏កន្លែងសុវត្ថិភាពសម្រាប់ពួកគាត់ស្នាក់នៅបណ្ដោះអាសន្ននៅក្នុងដំណើររឿងក្ដី ពីព្រោះបញ្ហាខ្វះទាក់ទងនឹងសុវត្ថិភាព និងសន្តិសុខផ្ទាល់ខ្លួនរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងក្រុមគ្រួសារ វាក៏ជារឿងសំខាន់ដែរ»។

ពាក់ព័ន្ធបញ្ហានៃការជួញដូរមនុស្សនេះ ក្រៅពីការផ្ដល់វគ្គបណ្ដុះបណ្ដាលទៅដល់អាជ្ញាធរថ្នាក់ក្រោមជាតិ ឱ្យមានចំណេះដឹង និងសមត្ថភាពក្នុងការកំណត់អត្តសញ្ញាណនៃជនរងគ្រោះដោយអំពើជួញដូរមនុស្សហើយ លោកអំ សំអាត សង្ឃឹមថា អាជ្ញាធរថ្នាក់ក្រោមជាតិ នឹងផ្ដល់កិច្ចគាំពារឱ្យល្អប្រសើរ និងពេញលេញសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្សផងដែរ៕

## កម្ពុជា ចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន ជាមួយដៃគូសន្ទនាបូក ៣ ស្ដីពីសហប្រតិបត្តិការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន

https://www.postkhmer.com/national/2023-08-24-1734-253881.html សំបាន ច័ន្ទដារ៉ា | Publication date 24 August 2023 | 17:34 ICT

***ភ្នំពេញ:*** រដ្ឋលេខាធិការក្រសួងមហាផ្ទៃលោក សុខ ផល និងគណៈប្រតិភូកម្ពុជា បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់រដ្ឋមន្ត្រីអាស៊ាន ជាមួយដៃគូសន្ទនាបូក ៣ នៅឥណ្ឌូនេស៊ី ស្ដីអំពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន សំដៅពង្រឹងការរៀបចំ និងចាត់ចែងអនុវត្តការងារឱ្យកាន់តែមានប្រសិទ្ធភាពក្នុងរង្វង់ប្រទេសជាដៃគូ។ ជំនួបប្រជុំពិគ្រោះថ្នាក់រដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនលើកទី១៧ នេះ ធ្វើឡើងនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ នៅទីក្រុង

ឡាប៊ូនបាចូ ឥណ្ឌូនេស៊ី ដែលមានការចូលរួមពីតំណាងប្រទេសជាសមាជិកអាស៊ាននានា និងប្រទេសដៃគូសន្ទនារួមមាន ចិន កូរ៉េខាងត្បូង និងជប៉ុន។ នេះបើយោងតាមការប្រកាសពីក្រសួងមហាផ្ទៃ។

នៅក្នុងអង្គប្រជុំ អាស៊ាននិងដៃគូ បានផ្លាស់ប្តូរទស្សនៈយោបល់គ្នាទៅវិញទៅមក លើកិច្ចសហប្រតិបត្តិការរួមគ្នាប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន និងផ្តល់យោបល់បន្តពង្រឹងសហប្រតិបត្តិការបន្ថែមរវាងអាស៊ាននិងប្រទេសជាដៃគូសំដៅ រៀបចំ ចាត់ចែងឱ្យមានប្រសិទ្ធភាពនូវផែនការដែលខ្លួនដាក់ចេញនិងឯកភាពកន្លងមក។ បន្ទាប់ពីនេះ លោក សុខ ផល ក៏បានចូលរួមក្នុងពិធីផ្ទេរតំណែងជាប្រធានកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន លើកទី១៨ (18th AMMTC) ដែលនឹងត្រូវប្តូរវេនពីឥណ្ឌូនេស៊ីទៅកាន់ឡាវ ផងដែរ ខណៈឡាវនឹងធ្វើជាម្ចាស់ផ្ទះនៅខែសីហា ឆ្នាំ ២០២៤។

ក្រៅពីនោះ លោក សុខ ផល បានជួបពិភាក្សាការងារជាមួយរដ្ឋមន្ត្រីក្រសួងសន្តិសុខសាធារណៈចិនលោក ស៊ី ថាចុង ផង ដោយភាគីទាំង២ កោតសរសើរនិងវាយតម្លៃខ្ពស់ទំនាក់ទំនងនិងកិច្ចសហការល្អរវាងគ្នានិងគ្នាកន្លងទៅប៉ុន្មានឆ្នាំមកនេះ។ ភាគីទាំង២ ក៏បានពិភាក្សានិងប្តេជ្ញាលើកកម្ពស់កិច្ចសហប្រតិបត្តិការប្រឆាំងបទល្មើសឆ្លងដែន តាមរយៈយន្តការតំបន់ និងក្របខ័ណ្ឌមេគង្គ-ឡានឆាង ផងដែរ។

លោក គិន ភា ប្រធានវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ថ្លែងថា កិច្ចប្រជុំពិគ្រោះយោបល់នេះ ពិតជាមានសារៈសំខាន់ណាស់ដែលជាយន្តការពហុភាគីដើម្បីទប់ស្កាត់បញ្ហាសន្តិសុខជាប្រពៃណីលើបទល្មើសឆ្លងដែនខណៈប្រទេសដៃគូសន្ទនាតួយ៉ាង ចិន កូរ៉េខាងត្បូង ជប៉ុន ជាដើមសុទ្ធសឹងតែជាប្រទេសដែលមានសក្តានុពលសម្រាប់ការគាំទ្រក្នុងកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអាស៊ាន។

លោក គិន ភា ថ្លែងថា៖«កន្លងមកកិច្ចសហការក្នុងក្របខ័ណ្ឌអាស៊ានលើការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែននេះមានលក្ខណៈល្អ ព្រោះជាបញ្ហារួមដែលត្រូវដោះស្រាយ ព្រោះបទល្មើសនេះ ត្រូវការយន្តការពហុភាគី»។ លោក ថ្លែងថា ក្នុងបញ្ហាសន្តិសុខតំបន់នេះ ឧក្រិដ្ឋកម្មឆ្លងដែនជាបទល្មើសធំដែលទាមទារបណ្តាប្រទេសនានារួមគ្នាដោះស្រាយ ដែលគ្មានប្រទេសណាមួយជាឯកតោភាគីអាចសម្រេចបានដោយជោគជ័យឡើយ ពោលគឺពហុភាគីនិយមដែលជាយន្តការគន្លឹះ៕

# អាជ្ញាធរថៃ
# នឹងដោះលែងពលរដ្ឋខ្មែរធ្វើការខុសច្បាប់ ចំនួន ៥ នាក់ នៅថ្ងៃអង្គារ សប្ដាហ៍ក្រោយ

https://www.kampucheathmey.com/local-news/565951 *ថ្ងៃសុក្រ ២៥ សីហា ២០២៣ដោយ* Inn Pisey

*អាជ្ញាធរថៃ នឹងដោះលែងពលរដ្ឋខ្មែរចំនួន ៥ នាក់ ដែលធ្វើការខុសច្បាប់នៅប្រទេសថៃ ឲ្យវិលមកកម្ពុជាវិញ នាថ្ងៃអង្គារ សប្ដាហ៍ក្រោយ បន្ទាប់ពីមានការជួយសម្របសម្រួលពីអនុព័ន្ធការងារកម្ពុជា និងស្ថានទូតកម្ពុជា។*

*សូមបញ្ជាក់ថា អាជ្ញាធរថៃ កាលពីថ្ងៃទី ១៩ ខែសីហានេះ បានចាប់ខ្លួនពលរដ្ឋខ្មែរចំនួន ៥ នាក់ ដែលកំពុងប្រកបរបររកស៊ីខុសច្បាប់នៅប្រទេសថៃ។ ភ្លាមៗ ស្ថានទូតខ្មែរ ប្រចាំប្រទេសថៃ បានឲ្យអនុព័ន្ធការងារចេញទៅដោះស្រាយ និងសម្របសម្រួល និងស្វែងយល់ពីបញ្ហា ដើម្បីស្វែងរកការដោះស្រាយ។ អនុព័ន្ធការងារប្រចាំស្ថានទូត ប្រាប់អ្នកសារព័ត៌មានថា ក្រោមការសម្របសម្រួលដ៏ជិតស្និទ្ធរវាងប្រទេសជិតខាងទាំងពីរ អាជ្ញាធរថៃ បានអនុញ្ញាតឲ្យពលរដ្ឋខ្មែរទាំង ៥ រូប អាចវិលមកកាន់កម្ពុជា នៅថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០២៣ សប្ដាហ៍ក្រោយនេះ។*

*ទន្ទឹមនឹងនេះ លោកបានអំពាវនាវឲ្យពលរដ្ឋខ្មែរដែលចង់ធ្វើការនៅប្រទេសថៃ សូមធ្វើជាពលករស្របច្បាប់ទៅតាមទីភ្នាក់ងារក្រុមហ៊ុនឯកជនដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានទទួលស្គាល់ជាផ្លូវការ ព្រោះការធ្វើការដោយមិនស្របច្បាប់ មានភាពប្រថុយប្រថាន និងគ្រោះថ្នាក់ និងបាត់បង់អត្ថប្រយោជន៍ ប៉ុន្តែការបម្រើការងារស្របច្បាប់វិញ មិនធ្វើឲ្យពលរដ្ឋខ្មែរមានហានិភ័យការងារ និងទទួលបានអត្ថប្រយោជន៍របស់ប្រទេសជាដៃគូ។ លោកបន្តថា ស្ថានទូតខ្មែរ និងអនុព័ន្ធការងារកម្ពុជានៅប្រទេសថៃ មិនបានព្រងើយកន្តើយចំពោះសុខទុក្ខរបស់ពលរដ្ឋដែលប្រឈមនឹងបញ្ហាទាំងនេះឡើយ។*

*បន្ថែមពីនេះ អនុព័ន្ធការងារកម្ពុជាប្រចាំប្រទេសថៃ បានអំពាវនាវដល់ប្រជាពលរដ្ឋដែលមានបំណងទៅធ្វើការនៅបរទេស សូមចេញទៅដោយស្របច្បាប់ និងសុវត្ថិភាព ព្រមទាំងទទួលអត្ថប្រយោជន៍ផ្សេងៗ ស្របទៅតាមច្បាប់នៅប្រទេសទទួល ដូចនេះពលរដ្ឋខ្មែរអាចចុះឈ្មោះទៅធ្វើការតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជនទទួលការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស៕*

# កិច្ចប្រជុំត្រួតពិនិត្យការងារប្រចាំខែសីហា ឆ្នាំ២០២៣ របស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប

https://www.information.gov.kh/articles/111774 ចេញផ្សាយ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០២៣

នៅសាលាខេត្តសៀមរាប នារសៀលថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣នេះ លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត (ហៅកាត់ថា គ.ខ.ប.ជ) បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យការងារប្រចាំខែសីហា ឆ្នាំ២០២៣ ដឹកនាំកិច្ចប្រជុំដោយលោកស្រី យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត និងមានអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ មន្ទីរ អង្គភាពពាក់ព័ន្ធ រដ្ឋបាលក្រុង ស្រុក មន្ត្រីនគរបាលយុត្តិធម៌ តំណាងព្រះរាជអាជ្ញាអមសាលាដំបូងខេត្ត ព្រមទាំងតំណាងអង្គការ ដៃគូពាក់ព័ន្ធ សរុប ៦២នាក់ ស្រី៣៥នាក់។

កិច្ចប្រជុំបាន ពិនិត្យទៅលើសេចក្ដីព្រាងរបាយការណ៍ប្រចាំខែសីហា ឆ្នាំ២០២៣ ពិនិត្យ និងពិភាក្សាលើបញ្ហាប្រឈមមួយចំនួន ដែលក្រុមការងារបានអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមគ្រប់រូបភាព ដោយមានការចូលរួមសហការពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ នៅតាមមូលដ្ឋានភូមិ ឃុំ ដូចជា ធ្វើការផ្សព្វផ្សាយច្បាប់ស្ដីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ការជួញដូរមនុស្សឆ្លងដែន កិច្ចការពារជនរងគ្រោះជាពិសេសកុមារ និងការជួញដូរមនុស្សឆ្លងដែន ខុសច្បាប់ជាដើម។ល។

កិច្ចប្រជុំក៏បានលើកយកបញ្ហាមួយចំនួនទៀត យកមកពិភាក្សា ដើម្បីស្វែងរកដំណោះស្រាយរួមគ្នា សម្រាប់ការពារជនរងគ្រោះ និងងាយរងគ្រោះ ដោយអំពើ រំលោភបំពានផ្សេងៗ និងបញ្ហាខ្វះៗពាក់ព័ន្ធទៅនឹងការចំណាកស្រុក ការសុំកូន ករណីរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ អំពើសញ្ចារកម្ម ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តប្រវេសន៍ និងអំពើជួញដូរមនុស្ស ព្រមទាំងបទល្មើសពាក់ព័ន្ធដទៃទៀតជាដើម។

មានប្រសាសន៍នៅក្នុងកិច្ចប្រជុំនោះដែរ លោកស្រី យូ សុភា បានចាត់ទុក អំពើជួញដូរមនុស្សគឺជាវិបត្តិសកលមួយដែល បណ្ដាប្រទេសជាច្រើនបានជួបប្រទះ ដោយក្នុងនោះដែរប្រទេសកម្ពុជាក៏បានទទួលរងនូវវិបត្តិនេះ ដែលធ្វើឲ្យរាជរដ្ឋាភិបាល ក៏ដូចជាប្រជាពលរដ្ឋទាំងអស់មានការព្រួយបារម្ភជាខ្លាំង ។លោកស្រី យូ សុភា ក៏បានមានប្រសាសន៍ជម្រុញឲ្យគ្រប់អ្នកពាក់ព័ន្ធទាំងអស់ បន្តកិច្ចសហការគ្នាឲ្យកាន់ស្អិតរមួតលើការអនុវត្តនីតិវិធីនានា ការបង្ក្រាបបទល្មើស ការជួយសង្គ្រោះជនរងគ្រោះឲ្យបានទាន់ពេលវេលា ពង្រឹងសមត្ថភាព និងពង្រីកការផ្សព្វផ្សាយដល់សិស្សានុសិស្ស នៅតាមគ្រឹះស្ថានសិក្សារបស់រដ្ឋ ឲ្យបានទូលំទូលាយ ដើម្បីបង្ក្រាប និងផ្ដន្ទាទោសដល់ជនល្មើសឲ្យខាងតែបាន ជាពិសេសសហការពង្រីកការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដើម្បីបញ្ជ្រាបការយល់ដឹងអំពី

ការឆបោក ការបៀតបៀន និងការរំលោភបំពានគ្រប់រូបភាពតាមប្រព័ន្ធអនឡាញ និងធ្វើការបណ្ដុះបណ្ដាលទៅដល់លោកគ្រូ អ្នកគ្រូក្រុមប្រឹក្សាកុមារ ឱ្យក្លាយជាជនបង្គោល ដើម្បីធ្វើការផ្សព្វផ្សាយបន្តទៅដល់សិក្សានុសិស្សឱ្យបានទូលំទូលាយ។ អត្ថបទ និងរូបភាព: លោកយូ វង្ស កែសម្រួលដោយ លីវ សុខុន

## ប្រធានាធិបតីអ៊ីតាលី អំពាវនាវឱ្យសហភាពអឺរ៉ុបបង្កើនកូតាជនចំណាកស្រុកស្របច្បាប់បន្ថែមទៀត ដើម្បីលុបបំបាត់ការជួញដូរមនុស្ស

https://freshnewsasia.com/index.php/en/internationalnews/307449-2023-08-25-13-38-58.html

2023-08-25 08:38pm

**(រ៉ូម)៖** ប្រធានាធិបតីអ៊ីតាលី លោក Sergio Mattarella បាននិយាយនៅថ្ងៃសុក្រ (២៥ សីហា) នេះថា សហភាពអឺរ៉ុបត្រូវតែអនុញ្ញាតឱ្យមានការធ្វើចំណាកស្រុកស្របច្បាប់បន្ថែមទៀត ដើម្បីលុបបំបាត់ការជួញដូរមនុស្ស ចំពេលមានការកើនឡើងនៃការមកដល់តាមសមុទ្រទៅកាន់ប្រទេសរបស់លោក។ នេះបើយោងតាមការចេញផ្សាយដោយ ទីភ្នាក់ងារសារព័ត៌មាន AFP នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៣។

ចំនួនមនុស្សឆ្លងព្រំដែនពីអាហ្វ្រិកខាងជើង ទៅកាន់ប្រទេសអ៊ីតាលីបានកើនឡើងទ្វេដងពីមួយឆ្នាំទៅមួយឆ្នាំ ដោយនៅឆ្នាំនេះកើនដល់ប្រហែល ១០៦,០០០នាក់ បើទោះបីជាមានការខិតខំប្រឹងប្រែងដោយរដ្ឋាភិបាលស្ដាំនិយម របស់នាយករដ្ឋមន្ត្រី លោក Giorgia Meloni ដើម្បីបង្ក្រាបលើជនអន្តោប្រវេសន៍ខុសច្បាប់ និងដាក់កម្រិតលើនាវាជួយសង្គ្រោះសប្បុរសធម៌ក៏ដោយ។

ប្រធានាធិបតី Mattarella បាននិយាយនៅក្នុងសន្និសីទមួយនៅទីក្រុង Rimini ដែលរៀបចំដោយក្រុមកាតូលិកថា «បាតុភូតនៃការធ្វើចំណាកស្រុក ត្រូវតែត្រូវបានដោះស្រាយព្រោះវាជាចលនាសកល ដែលមិនអាចត្រូវបានលុបចោល ដោយជញ្ជាំង ឬរបាំងឡើយ»។ លោកបានបន្ថែមថា «កូតាទៀងទាត់ និរន្តរភាព និងខ្ពស់គ្រប់គ្រាន់ គឺជាមធ្យោបាយតែមួយគត់ ដើម្បីលុបបំបាត់ការជួញដូរមនុស្សយ៉ាងឃោរឃៅ»។

រដ្ឋាភិបាលរបស់ លោក Meloni បានធ្វើតាមការណែនាំរបស់ លោក Mattarella មួយផ្នែកដោយកាលពីខែកក្កដា បាននិយាយថាខ្លួននឹងបង្កើនកូតា សម្រាប់ពលករចំណាកស្រុកដែលមិនមែនជាសហភាពអឺរ៉ុបដល់ ៤៥២,០០០នាក់ សម្រាប់រយៈពេល ២០២៣-២០២៤។ ប៉ុន្តែចំនួននេះ គឺទាបជាងការស្នើដោយដោយក្រុមហ៊ុន និងសហជីព ដែលមានរហូតដល់ ៨៣៣,០០០នាក់។

ប្រធានាធិបតីអ៊ីតាលី ដែលជាប្រមុខរដ្ឋ និងជាឥស្សរជនមិនប្រកាន់បក្សពួក បាននិយាយថា សកម្មភាពត្រូវតែធ្វើឡើងនៅកម្រិតសគមអឺរ៉ុបទាំងមូល។ អន្តោប្រវេសន៍គឺជាបញ្ហានយោបាយក្តៅក្នុងប្លុកជាយូរមកហើយ ដែលរារាំងដល់ការសម្រេចចិត្តរួមដោយប្រទេសសមាជិកទាំង២៧៕

# ថ្ងៃទី២៩ ខែ សីហា ឆ្នាំ២០២៣

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃណែនាំគោលការណ៍ប្រាំពីរចំណុច ទៅកាន់កងកម្លាំងនគរបាលជាតិ

HTTPS://WWW.RASMEINEWS.COM/ARCHIVES/832608 AUG 28, 2023

ដោយៈមុនីរ័ត្ន/ភ្នំពេញ ៖ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ណែនាំគោលការណ៍ដឹកនាំសំខាន់ៗចំនួនប្រាំពីចំណុចដល់កងកម្លាំងនគរបាលជាតិ ដើម្បីលើកកម្ពស់ស្មារតីទទួលខុសត្រូវក្នុងការអនុវត្តតួនាទីភារកិច្ច រួមចំណែកសម្រេចឱ្យបានជោគជ័យនូវកម្មវិធីនយោបាយ និងយុទ្ធសាស្រ្តបញ្ចកោណដំណាក់កាលទី១ នៃរាជរដ្ឋាភិបាល នីតិកាលទី៧។ ការណែនាំនេះបានធ្វើឡើងក្នុងឱកាសដែលឯកឧត្តមអភិសន្តិបណ្ឌិត អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រកាសតែងតាំងមុខតំណែង និងបំពាក់ឋានន្តរស័ក្តិអគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ នៅសាលប្រជុំខេត្តព្រៃវែង នៃទីស្តីការក្រសួងមហាផ្ទៃ។

គោលការណ៍ដឹកនាំ ទាំងប្រាំពីរចំណុច ដែលឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ណែនាំដល់កងកម្លាំងនគរបាលជាតិ នាឱកាសនោះរួមមាន ៖

ទី១. ត្រូវបន្តខិតខំរួមគ្នាថែរក្សាសុខសន្តិភាព ស្ថិរភាពនយោបាយ ការពារឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដី មិនឱ្យមានការលូកដៃជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងកម្ពុជា ព្រមទាំងទប់ស្កាត់ និងប្រឆាំងដាច់ខាតរាល់សកម្មភាពប៉ុនប៉ង ផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ឬការញុះញង់ណាមួយ ដើម្បីបង្កអស្ថិរភាពនយោបាយ ឬភាពវឹកវរចលាចលក្នុងសង្គម។

ទី២. បង្កើនការថែរក្សា ពង្រឹងសន្តិសុខជាតិ ដោយត្រូវបង្កើនកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរ និងកម្លាំងអនុវត្តច្បាប់ នៃប្រទេសដែលមានព្រំដែនជាប់កម្ពុជា និងប្រទេសនានាក្នុងតំបន់ និងពិភពលោក ដើម្បីផ្លាស់ប្តូរព័ត៌មាន សហការទប់ស្កាត់អំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន អង្គការចាត់តាំង នៃក្រុមឧក្រិដ្ឋកម្មឆ្លងដែន អំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទលើគ្រប់ទម្រង់ បទល្មើសសម្អាតប្រាក់ បទល្មើសហិរញ្ញប្បទានភេរវកម្ម ហិរញ្ញប្បទានដល់ការសាយភាយអាវុធមហាប្រល័យ បទល្មើសគ្រឿងញៀនខុសច្បាប់ និងបទល្មើសបច្ចេកវិទ្យា។ បន្ថែមលើនេះ ត្រូវបន្តសហការ

ជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចក្នុងការដោះស្រាយបញ្ហាព្រំដែនគោក និងទឹកជាមួយប្រទេសជិតខាង ដែលនៅសេសសល់ ដោយផ្អែកលើមូលដ្ឋានច្បាប់អន្តរជាតិ ឈរលើការអនុវត្តយុទ្ធសាស្ត្រ អភិវឌ្ឍតំបន់ព្រំដែន ជាព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ។

ទី៣. ត្រូវពង្រឹងការងារនគរបាល និងសហគមន៍ សំដៅជំរុញអនុវត្តគោលនយោបាយ "ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព" ដើម្បីកៀរគរ ប្រមែប្រមូលការគាំទ្រចូលរួមពីគ្រប់ផ្នែក គ្រប់ថ្នាក់ ជាពិសេសលើកកម្ពស់ការចូលរួមពីប្រជាពលរដ្ឋក្នុងការបង្ការបង្ក្រាបបទល្មើសនានានៅតាមសហគមន៍ ព្រមទាំងការរក្សាសណ្តាប់ធ្នាប់ បរិស្ថាននៅក្នុងមូលដ្ឋានឱ្យបានល្អប្រសើរ តាមរយៈការចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាព លក្ខណៈសម្បត្តិទាំង ៧យ៉ាង នៃគោលនយោបាយ "ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព"។ ក្នុងនោះត្រូវពង្រឹងនគរបាលប៉ុស្តិ៍រដ្ឋបាល ពង្រឹងកម្លាំងប្រជាការពារតាមភូមិ ឃុំ សង្កាត់ ដោយត្រូវតម្រង់ភារកិច្ច របៀបរបបធ្វើសកម្មភាព និងការរៀបចំចាត់តាំងកម្លាំងប្រជាការពារ ឱ្យបានត្រឹមត្រូវតាមសេចក្តីណែនាំលេខ ០៣៧ សណន ស្តីពីការពង្រឹងចលនាប្រជាការពាររបស់ក្រសួងមហាផ្ទៃ។

ទី៤. គ្រឿងញៀនខុសច្បាប់ គឺជាបញ្ហាប្រឈមដែលមានលក្ខណៈគ្រោះថ្នាក់ និងស្មុគស្មាញជាទីបំផុត ហើយនិន្នាការផលិត ចរាចរ ជួញដូរ និងចែកចាយគ្រឿងញៀនខុសច្បាប់ក្នុងតំបន់ និងពិភពលោក មិនមានសញ្ញាថមថយនោះឡើយ។ ក្នុងន័យនេះកងកម្លាំងនគរបាលជាតិ ត្រូវលើកកម្ពស់កិច្ចសហប្រតិបត្តិការអោយកាន់តែខ្លាំងក្លាថែមទៀត ជាមួយក្រសួង ស្ថាប័ន អាជ្ញាធរ ពាក់ព័ន្ធអនុវត្តយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ដោយត្រូវលើកកម្ពស់ វិធានការផ្សព្វផ្សាយ អប់រំ វិធានការស្រាវជ្រាវបង្ក្រាប បង្កើនកិច្ចសហការជាមួយបណ្តាប្រទេស និងអង្គការអន្តរជាតិពាក់ព័ន្ធទាំងក្នុងតំបន់ និងពិភពលោក សិក្សាពីបទពិសោធ ក្នុងការបង្ក្រាប និងការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។

ទី៥. បន្តបង្កើនវិធានការអប់រំ វិធានការរដ្ឋបាល និងវិធានការច្បាប់ឱ្យបានម៉ឺងម៉ាត់ ដើម្បីពង្រឹងសុវត្ថិភាពចរាចរផ្លូវគោក និងសណ្តាប់ធ្នាប់តាមដងផ្លូវក្នុងទីក្រុង ទីប្រជុំជន ដើម្បីដោះស្រាយភាពកកស្ទះ និងកាត់បន្ថយគ្រោះថ្នាក់ចរាចរ។

ទី៦. ត្រូវបន្តពង្រឹងវិធានការបង្ការទប់ស្កាត់ ផ្តល់អន្តរាគមន៍សង្គ្រោះ និងដោះស្រាយបញ្ហាអគ្គីភ័យ ព្រមទាំងគ្រោះថ្នាក់នានាក្នុងសង្គម ដើម្បីរក្សាសុវត្ថិភាពជូនប្រជាពលរដ្ឋ។

ទី៧ ដែលជាចំណុចចុងក្រោយត្រូវបន្តជំរុញការកែទម្រង់ កម្លាំងនគរបាលជាតិ ដោយយកចិត្តទុកដាក់បណ្តុះ បណ្តាលជួរនគរបាលជាតិ ឱ្យមានសមត្ថភាពជំនាញ វិជ្ជាជីវៈច្បាស់លាស់ គោរពឱ្យបានខ្ជាប់ខ្ជួន វិន័យកងកម្លាំង ពង្រឹងការជ្រើសរើសបញ្ចូលក្របខ័ណ្ឌនគរបាលជាតិ ឱ្យបាន

ត្រឹមត្រូវ និងមានតម្លាភាព។ ការប្រគល់មុខតំណែង ការដំឡើងឋានន្តរស័ក្តិ និងលើកសរសើរ ជូនរង្វាន់ត្រូវផ្អែកលើ លក្ខណៈសម្បត្តិ ស្នាដៃ និងបទពិសោធការងារ ព្រមទាំងត្រូវអនុវត្ត វិន័យកងកម្លាំងឱ្យបានម៉ឺងម៉ាត់ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ។ សរន

## សមត្ថកិច្ចថៃចាប់ខ្លួនស្ត្រីពលករខ្មែរបីនាក់ ដាក់ឃុំករណីលួចលក់ត្រីខៀតគ្មានការអនុញ្ញាត

https://www.rfa.org/khmer/news/social-economy/thai-police-arrested-three-cambodian-women-workers-08242023165954.html ដោយ ឡេង ម៉ាលី 2023.08.24

សមត្ថកិច្ចថៃចាប់ស្ត្រីពលករខ្មែរបីនាក់ ឃុំខ្លួនក្នុងពន្ធនាគារ ដោយចោទពីបទលួចលក់ត្រីប្រឡាក់គ្មានការអនុញ្ញាត។ ស្ត្រីពលករ ដែលសមត្ថកិច្ចថៃចាប់ខ្លួននោះនិយាយថា ត្រីប្រឡាក់ ដែលពួកគេលក់នោះ គឺជាត្រីដែលប្ដីរបស់ពួកគាត់ទៅរកបាននៅជិតៗ កន្លែងពួកគេស្នាក់នៅ និងជាត្រីសល់ពីការធ្វើម្ហូបប៉ុណ្ណោះ។ សមត្ថកិច្ចថៃបានទាមទារឱ្យស្ត្រីពលករខ្មែរទាំងបីនាក់ ដែលរងការចោទថា លួចលក់ត្រីប្រឡាក់គ្មានការអនុញ្ញាតនោះ ត្រូវបង់ប្រាក់ម្នាក់ៗ ចំនួន ១ម៉ឺនបាត ឬជាង ៣០០ដុល្លារ ទើបគេព្រមដោះលែងឱ្យមានសេរីភាពវិញ។ ប៉ុន្តែ បើទោះជាក្រុមស្ត្រីពលករខ្មែរបង់ប្រាក់តាមការទាមទារក្ដី ក៏សមត្ថកិច្ចថៃមិនដោះលែងពួកគេវិញដែរ។

លោកស្រី វនសៀ ជាដា អាយុ ៣៩ឆ្នាំ ជាពលករម្នាក់ ក្នុងចំណោមពលករទាំងបីនាក់ ដែលសមត្ថកិច្ចថៃចាប់ខ្លួន ប្រាប់វិទ្យុអាស៊ីសេរី នៅថ្ងៃទី២៤ ខែសីហាថា លោកស្រីមកប្រទេសថៃ ធ្វើការនៅរោងចក្រមួយកន្លែងក្នុងខេត្តភិតបុរី (Phit Borey) ហើយពេលប្ដីលោកស្រីទំនេរពីការងារទៅរកត្រីនៅជិតកន្លែងស្នាក់នៅធ្វើម្ហូប។ លោកស្រីបន្តទៀតថា ត្រីដែលនៅសល់ពីការធ្វើម្ហូប លោកស្រីប្រឡាក់លក់ឱ្យអ្នកជិតខាង ហើយនៅទីបំផុតសមត្ថកិច្ចបានចាប់ខ្លួនលោកស្រី និងស្ត្រីពលករពីរនាក់ផ្សេងទៀត ក្នុងករណីលក់ត្រីប្រឡាក់នេះ។ លោកស្រី វនសៀ ជាដា៖ «ខ្ញុំត្រីតែពីរហ្នឹងត្រីតុពីរដល់គេ (សមត្ថកិច្ចថៃ) ចាប់បានគេថា ខ្ញុំហ្នឹងធ្វើខុសច្បាប់ប្រទេសថៃ យើងមកធ្វើការដឹងតែធ្វើការគេ អត់ឱ្យលក់ដូរទាំងអស់ពេលអ៊ីចឹង គេទារខ្ញុំ ១ម៉ឺនបាត»។

សមត្ថកិច្ចថៃ ក្នុងខេត្តភិតបុរី (Phit Borey) បានចាប់ខ្លួនស្ត្រីពលករខ្មែរបីនាក់ នៅម្តុំកន្លែងពួកគេធ្វើការ និងស្នាក់នៅ ស្ថិតក្នុងខេត្តនេះ កាលពីថ្ងៃទី១៩ ខែសីហា ដោយចោទពីបទលួចលក់ត្រីប្រឡាក់គ្មានការអនុញ្ញាត។ នៅពេលចាប់ខ្លួនភ្លាមៗ នោះ សមត្ថកិច្ចថៃ ទាមទារក្រុមស្ត្រីពលករទាំងបីនាក់ថា ម្នាក់ៗ ត្រូវបង់ប្រាក់ចំនួន ១ម៉ឺនបាត ឬជាង ៣០០ដុល្លារ ជាថ្នូរនឹងការដោះលែង។ ប៉ុន្តែនៅពេលក្រុមលោកស្រីបង់ប្រាក់រួចហើយ សមត្ថកិច្ចថៃមិនដោះលែងតាមការសន្យាទេ ហើយថែម

ទាំងបញ្ជូនសំណុំរឿងនេះទៅតុលាការទៀត។ នៅពេលជួបរឿងបែបនេះ ក្រុមស្ត្រីពលករបាន បង្ហោះវីដេអូ ដែលពួកគាត់ជាប់ឃុំនៅក្នុងពន្ធនាគារនោះ តាមហ្វេសប៊ុក។

លោកស្រី វ៉ន សៀ ជាដា ឱ្យដឹងទៀតថា ក្រោយការបង្ហោះវីដេអូរួចហើយ មានមន្ត្រីស្ថានទូត កម្ពុជាប្រចាំប្រទេសថៃ បានទូរស័ព្ទទៅលោកស្រី ប៉ុន្តែមិនមែនមកជួយសម្របសម្រួលធ្វើអន្តរាគមន៍ ទេ គឺមន្ត្រីទាំងនោះបានស្ដីបន្ទោសក្រុមលោកស្រី និងបញ្ជាក់ជំហរថា ពួកគេមិនអាចជួយបានទេ ព្រោះក្រុមលោកស្រីខុស លួចលក់ត្រីបែបនេះ គឺខុសច្បាប់។ លោកស្រីឱ្យដឹងថា សមត្ថកិច្ចនឹង បញ្ជូនក្រុមលោកស្រីទាំងបីនាក់ ទៅប្រទេសកម្ពុជាវិញ នៅដើមសប្ដាហ៍ក្រោយនេះ។

លោកស្រី វ៉ន សៀ ជាដា៖ «គេមិនអាចជួយអីបងឯងបានទេ ហើយបងឯងគេឱ្យមកធ្វើការបង ឯងមកធ្វើការខុសអ៊ីចឹងឱ្យគេជួយម៉េច? បងឯងមិនយល់ពីគេ ឱ្យគេជួយយើងម៉េច? ដឹងអត់គេឱ្យ មកធ្វើការដឹងអត់ថា មកធ្វើការអ៊ីចឹងខុសច្បាប់ ខ្ញុំថា ខ្ញុំអត់ដឹងទេ។ សំណាងហើយគេឱ្យបងឯងគេ ដាក់បងឯងប៉ុណ្ណឹង តាមច្បាប់ប្រទេសថៃ គេដាក់គុកបងឯងមួយឆ្នាំ។ ដល់ពេលនិយាយអ៊ីចឹង ខ្ញុំ ខ្ជិលនិយាយហ្នឹងទៅ»។

ទាក់ទងការលើកឡើងនេះ វិទ្យុអាស៊ីសេរីមិនអាចសុំការឆ្លើយតបពីប្រធានអនុព័ន្ធការងារអម ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ លោក ឈឹម វិបុល អ្នកនាំពាក្យក្រសួងការបរទេស លោក អាន សុខ ខឿន បានទេ នៅថ្ងៃទី២៤ ខែសីហា។

កាលពីពេលកន្លងទៅ អ្នកការពារសិទ្ធិពលករ និងភ្នាក់ងារបញ្ជូនពលករទៅធ្វើការនៅ ប្រទេសថៃ រិះគន់ថា មន្ត្រីស្ថានទូតកម្ពុជាប្រចាំប្រទេសថៃថា មិនសូវយកចិត្តទុកដាក់ជួយគាំពារសិទ្ធិ ពលករខ្មែរទេ តែមន្ត្រីទាំងនោះពូកែខាងធ្វើការយកមុខយកមាត់ នឹងរឿងពង្រឹងបក្សប្រជាជនកម្ពុជា នៅប្រទេសនេះទៅវិញ។

មន្ត្រីផ្នែកការពារសិទ្ធិពលករចំណាកស្រុក នៃអង្គការសង់ត្រាល់ (CENTRAL) ប្រចាំនៅ ប្រទេសថៃ លោក លឹង សុផុន យល់ថា បើទោះជាច្បាប់ការងារប្រទេសថៃ មិនអនុញ្ញាតឱ្យពលករ បរទេសមានសិទ្ធិលក់ដូរក្ដី ប៉ុន្តែលោកថា មន្ត្រីស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ គួររកវិធីដោះស្រាយ ជាជាងមកស្ដីបន្ទោសឱ្យពលករ ដែលកំពុងរងគ្រោះ។ អ្នកការពារសិទ្ធិពលកររូបនេះឱ្យដឹងទៀតថា ក្រុមស្ត្រីពលករទាំងបីនាក់នោះ ពួកគេមានលិខិតឆ្លងដែន និងឯកសារការងារត្រឹមត្រូវ។ ដូច្នេះ ប្រសិនបើមន្ត្រីស្ថានទូតជួយធ្វើអន្តរាគមន៍ទាន់ពេល បញ្ហានេះនឹងមិនរីកធំ ឬក៏មិនឱ្យសមត្ថកិច្ចថៃ បញ្ជូនសំណុំរឿងនេះទៅតុលាការនោះទេ។

លោក លឹង សុផុន៖ «គួរណាស់គាត់ (មន្ត្រីស្ថានទូតខ្មែរប្រចាំប្រទេសថៃ) មានវិធានការណា មួយ ដើម្បីដោះស្រាយជូនប្រជាពលរដ្ឋខ្មែរយើងកំពុងមានបញ្ហាប្រឈម ជាពិសេស ដូចបងៗ ដែល

កំពុងតែប៉ូលិសចាប់ដាក់ឃុំគួរណាស់គួរមានវិធានការណាមួយឱ្យពួកគាត់ធាប់រួចផុតពីគុក ឬរួចផុតពីទោសអីអ៊ីចឹងណា»។

ស្រដៀងគ្នានឹងការលើកឡើងរបស់មន្ត្រីសង្គមស៊ីវិលនេះដែរ លោកស្រី វនសៀ ជាជា ដែលកំពុងជាប់ឃុំ ដោយសារលួចលក់ត្រីប្រឡាក់គ្មានការអនុញ្ញាតនេះ មានប្រសាសន៍ថា លោកស្រីចង់ឃើញមន្ត្រីស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ សម្របសម្រួលជាមួយសមត្ថកិច្ចថៃ ដោយអនុញ្ញាតឱ្យលោកស្រីអាចបន្តធ្វើការងារនៅប្រទេសថៃតទៅទៀត ព្រោះលោកស្រីបារម្ភថា នៅពេលសមត្ថកិច្ចថៃបញ្ជូនពួកលោកស្រីទៅដល់ប្រទេសកម្ពុជារួចហើយ គេមិនអនុញ្ញាតឱ្យក្រុមលោកស្រីចូលមកធ្វើការនៅប្រទេសថៃវិញបានទេ។

អង្គការសង់ត្រាល់ (CENTRAL) រកឃើញថា ពលករខ្មែរភាគច្រើន ដែលសមត្ថកិច្ចថៃចាប់ខ្លួនបានរងការធ្វើទុក្ខទោស ទារុណកម្ម ដោយការចាប់ដាក់ខ្នោះ និងជាប់ឃុំក្នុងបន្ទប់តូចចង្អៀត។ អង្គការនេះរកឃើញទៀតថា រយៈពេលបីខែចុងក្រោយនេះ សមត្ថកិច្ចថៃចាប់ពលករខ្មែរជាង ១.០០០ នាក់ (មួយពាន់)។ ពលករខ្លះជាប់ឃុំនៅប្រទេសថៃ ហើយមួយចំនួនធំ សមត្ថកិច្ចថៃបញ្ជូនទៅកម្ពុជាវិញ៕

## ពលករខ្មែរមួយចំនួនធ្វើការនៅថៃដែលប្រើប្រាស់ថ្នាំញៀន ធ្វើឱ្យគ្មានប្រាក់ផ្ញើឱ្យគ្រួសារ

https://www.rfa.org/khmer/news/social-economy/some-cambodian-workers-in-thailand-addicted-drug-08252023052111.html ដោយ ម៉ៅ សុជានី 2023.08.25

ពលករខ្មែរធ្វើការរោងចក្រនៅប្រទេសថៃរាប់រយនាក់ប្រើប្រាស់ថ្នាំញៀន ធ្វើឱ្យពុំមានប្រាក់ផ្ញើឱ្យឪពុកម្ដាយនៅកម្ពុជា។ មន្ត្រីអង្គការសង្គមស៊ីវិល លើកឡើងថា បញ្ហានេះនឹងជះឥទ្ធិពលអាក្រក់ដល់សង្គមជាតិ ដែលមន្ត្រីស្ថានទូតខ្មែរប្រចាំនៅប្រទេសគួរតែអន្តរាគមន៍ទៅអាជ្ញាធរថៃ ជួយដល់ពលករទាំងនោះជាបន្ទាន់។

ពលករខ្មែរធ្វើការនៅខេត្តជាប់ទីក្រុងបាងកក (Bangkok) មួយចំនួនលើកឡើងថា ពួកគេមិនចង់ធ្វើការនៅតំបន់ដែលក្រុមពលករទាំងនោះប្រើប្រាស់ថ្នាំញៀននោះទេ ក៏ប៉ុន្តែដោយសារគ្មានជម្រើស ដូច្នេះមានតែអត់ទ្រាំធ្វើការនៅទីនោះបន្តទៀត ដើម្បីរកប្រាក់ដោះស្រាយជីវភាពគ្រួសារ។

ពលករធ្វើការរោងចក្រផលិតអាហារ ស៊ីភី រ៉ែម (CP Ram Company) នៅស្រុកឡាតលុមកែវ (Lat Lum Keo) ខេត្តផាត់ធុមថានី (Pathum Thani) ជាប់ទីក្រុងបាងកកថ្ងៃងសុំមិនឱ្យបញ្ចេញឈ្មោះថា ពលករខ្មែរប្រមាណ ១ពាន់នាក់ក្នុងចំណោមពលករខ្មែរជាង ១ពាន់ ៩០០នាក់(១.៩០០)ដែលធ្វើការរោងចក្រ នៅតំបន់លោករស់នៅបានប្រើប្រាស់គ្រឿងញៀន។ ពលកររូបនេះ បន្តថា ថ្នាំញៀនត្រូវបានគេដាក់លក់ដូចផ្សារត្រី ដែលពួកគេទិញពីប៉ូលិសមូលដ្ឋានរបស់ថៃ នៅតំបន់នោះក្នុងតម្លៃ

៣០គ្រាប់ ពី១៥០ ទៅ ២០០បាត ឬស្មើនឹងប្រមាណពី ៤ទៅ៦ដុល្លារអាមេរិក រួចនាំគ្នាប្រើប្រាស់នៅតាមបន្ទប់រៀងៗខ្លួន។

ពលកររូបនេះបន្ថែមថា ដំបូងឡើយគ្រួសារគាត់ធ្លាប់ស្នាក់នៅក្នុងបន្ទប់ជាមួយអ្នកប្រើប្រាស់ថ្នាំញៀនដែរ តែក្រោយមកក៏បានប្តូរបន្ទប់វិញ ដោយសារព្រួយបារម្ភពីសុវត្ថិភាពខ្លាចអ្នកញៀនថ្នាំវង្វេងស្មារតី ហើយប្រើអំពើហិង្សាមកលើខ្លួន។ ពលកររូបនេះបញ្ជាក់ថា ក្រុមអ្នកញៀនថ្នាំទាំងនោះភាគច្រើនមានឧបករណ៍ប្រើប្រាស់ថ្នាំញៀន និងមានកាំបិតដាវដាក់ជាប់ខ្លួន ហើយជារឿយៗពួកគេតែងស្រែកឡូឡាបង្កការរំខានដល់អ្នកដែលមិនបានប្រើប្រាស់ថ្នាំញៀននៅពេលយប់។ «ខ្ញុំខ្លាចពេលណាគេប្រើប្រាស់ដល់កម្រិតទៅ វាអាចនឹងប្រតិកម្មក្នុងខ្លួនគាត់អីចឹង គាត់ធ្វើសកម្មភាពមកលើយើងអីចឹង។ ដូចគេប្រើអ៊ីចឹងធ្វើអត់ឱ្យយើងងងុយដេក មិនឱ្យយើងអស់កម្លាំង ហើយបាយទឹកអីអត់ហូបអត់អី ហើយគេនាំគ្នាដើរចុះដើរឡើងចេញចូលៗអ៊ីចឹងទៅ»។

ស្រដៀងគ្នានេះដែរ ពលការិនីធ្វើការនៅតំបន់ពលករខ្មែរប្រើប្រាស់ថ្នាំញៀន ម្នាក់ទៀត គឺលោកស្រី ជួង សុភាព រៀបរាប់ប្រាប់វិទ្យុអាស៊ីសេរីថា ប្អូនប្រុសរបស់លោកស្រីអាយុ២៥ឆ្នាំ បានប្រើប្រាស់ថ្នាំញៀន តាមគ្នីគ្នារយៈពេលប្រមាណ៤ឆ្នាំហើយ។ ពលករមានដើមកំណើតនៅខេត្តពោធិ៍សាត់រូបនេះ បន្តថា ប្អូនលោកស្រីភាគច្រើនទិញថ្នាំញៀន ពីប៉ូលិសមូលដ្ឋាននៅតំបន់នោះ រួចយកមកប្រើប្រាស់នៅក្នុងបន្ទប់ នៅពេលដែលប្អូនត្រឡប់មកពីធ្វើការវិញ។ លោកស្រីថា ប្អូនលោកស្រីញៀនថ្នាំរហូតលែងស្គាល់ឪពុកម្តាយ ហើយតែងប្រើហិង្សាមកលើលោកស្រី និងមិនស្តាប់បង្គាប់ការណែនាំរបស់សាច់ញាតិឡើយ។

លោកស្រី ជួង សុភាព ៖ «ដល់ពេលជក់ថ្នាំអ៊ីចឹងទៅមានបាញ់គ្នាកាប់គ្នាអ៊ីចឹងទៅអនាធិបតេយ្យដូចតំបន់ម៉ាហ្វីយ៉ាអ៊ីចឹង។ ប្តីត្បិតតែរោងចក្រនឹងធំល្អមែន តែអ្នកធ្វើការគឺអត់សូវខ្លាចច្បាប់ទេ ដូចថាធ្វើអីមកគ្មានខ្លាចច្បាប់ទេ ចង់កាប់ចង់ជក់ចង់ផឹកអ៊ីចឹង ធ្វើបានតាមអំពើចិត្ត។ និយាយទៅគួរឱ្យខ្លាចដូចថាដាក់ទៅឆ្វេងក៏មានតែអ្នកញៀនថ្នាំ ដាក់ទៅស្តាំមានតែអ្នកញៀនថ្នាំ»។ លោកស្រីបន្តថា អ្នកញៀនថ្នាំភាគច្រើនជាក្រុមយុវជនអាយុចន្លោះពី ១៨ ទៅជិត ៣០ឆ្នាំ ដោយអ្នកខ្លះទិញថ្នាំញៀនសម្រាប់ប្រើប្រាស់ខ្លួនឯងផង និងលក់បន្តឱ្យពលករធ្វើការជាមួយគ្នាផង។ លោកស្រីអះអាងថា កន្លងទៅលោកស្រីធ្លាប់ប្តឹងទៅប៉ូលិសមូលដ្ឋានរបស់ថៃឱ្យចាត់វិធានការលើរឿងនេះដែរ ក៏ប៉ុន្តែពុំទទួលបានលទ្ធផលឡើយ ហើយថៃមទាំងប៉ូលិសប្រាប់លោកស្រីថា កុំចេះដឹងរឿងគេពេក។ លោកស្រីព្រួយបារម្ភខ្លាចប្អូនលោកស្រីមានគ្រោះថ្នាក់ដល់អាយុជីវិត ពីព្រោះសព្វថ្ងៃនេះរាងកាយស្គមស្លេកស្លាំង និងមិនសូវហូបអាហារឡើយ។ លោកស្រីក៏បារម្ភពីអនាគតគ្រួសារដែរ ព្រោះចាប់តាំងពីប្អូនលោកស្រីញៀនថ្នាំមក ពុំដែលផ្ញើប្រាក់ទៅឱ្យឪពុកម្តាយនៅកម្ពុជានោះទេ។

លោកស្រី ជួង សុភាព៖ «លក់ផងជក់ផងស្មើរតែទាំងអស់ហ្នឹង ខ្ញុំឃើញដូចថា សង្វៃគណាស់ខ្មែរយើងមិនគួរណាធ្លាក់ដល់ចំណុចហ្នឹងទេ។ ដូចថាគាត់លក់ថ្នាំផងញៀនផង ញៀនរហូតថ្នាក់លែងខ្វល់ខ្វាយពីឪពុកម្ដាយប្រទេសជាតិ សូម្បីតែខ្លួនគាត់ក៏បណ្ដោយខ្លួនធ្វើឱ្យស្គមរីងរៃ ហើយធ្វើការមកបានតែលុយហ្នឹងយកមកជក់ថ្នាំ»។ ក្រុមពលករទាំងនោះអំពាវនាវឱ្យមន្ត្រីស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ អន្តរាគមន៍ទៅអាជ្ញាធរថៃឱ្យចាត់វិធានការលើអ្នកលក់ថ្នាំញៀននៅតំបន់នោះ ដើម្បីសម្រួលដល់ពួកគេធ្វើការងារដោយសុវត្ថិភាព។

វិទ្យុអាស៊ីសេរីមិនអាចទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ ដើម្បីសុំអត្ថាធិប្បាយជុំវិញពីពលករខ្មែរប្រើប្រាស់ថ្នាំញៀននេះបានទេ នៅថ្ងៃទី២៤ សីហា។ ចំណែករដ្ឋមន្ត្រីក្រសួងការងារ លោក ហេង សួរ ក៏មិនអាចទាក់ទងបានដែរ។

ជុំវិញរឿងនេះ មន្ត្រីកម្មវិធីផ្នែកទេសន្តរប្រវេសក៍នៃអង្គការសង់ត្រាល់(CENTRAL) លោក ឌី ថេហូយ៉ា មានប្រសាសន៍ថា បញ្ហានេះពុំមែនជាកំហុសរបស់ពលករនោះទេ ពោលគឺដោយសារតែបរិស្ថាននៅតំបន់ពួកគាត់ធ្វើការមានថ្នាំញៀន។ លោកបន្តថា បញ្ហានេះជាគ្រោះថ្នាក់ធំមួយដល់សង្គមជាតិ ដោយសារតែយុវជនពេញកម្លាំងទាំងនោះរវល់តែញៀនថ្នាំដោយពុំបានធ្វើការងាររកប្រាក់ផ្គត់ផ្គង់ជីវភាពគ្រួសារ និងជាបន្ទុកដល់គ្រួសារទៅវិញ។ លោកបញ្ជាក់ថា ដើម្បីដោះស្រាយបញ្ហានេះមន្ត្រីស្ថានទូតខ្មែរនៅទីក្រុងបាងកក គួរតែអន្តរាគមន៍ទៅរដ្ឋាភិបាលឱ្យចាត់វិធានការជួយដល់ពលករទាំងនោះជាបន្ទាន់។

លោក ឌី ថេហូយ៉ា៖ «ខ្ញុំគិតថាវាប៉ះពាល់ធំធេងរយៈពេលយូរ ក្លាយទៅជាបន្ទុកសង្គម។ បន្ទុកទី១បន្ទុកគ្រួសាររបស់គាត់ដែលប្រឈមថា តើត្រូវដោះស្រាយរបៀបម៉េច ។ បន្ទុកទីវារងផលប៉ះពាល់ឥទ្ធិពលតកូនតចៅដែលគាត់មិនមានលុយ ដើម្បីផ្គត់ផ្គង់ក្រុមគ្រួសារហើយ គាត់មានសារជាតុញៀនទៀត ហើយគាត់ធ្វើឱ្យស្ថិរភាពនៅក្នុងសហគមន៍នៅក្នុងមូលដ្ឋានហ្នឹងវាអត់មានស្ថិរភាព។ ធម្មតាសារជាតុញៀន កាលណាវាញៀនគឺវាអត់ដឹងខុសត្រូវអីទេ វាអាចប្រើប្រាស់អំពើហិង្សាកាប់សម្លាប់អីជាដើមអ៊ីចឹងទៅ»។ របាយការណ៍របស់អង្គការសង់ត្រាល់ឱ្យដឹងថា បច្ចុប្បន្នមានពលករខ្មែរធ្វើការស្របច្បាប់ និងមិនស្របច្បាប់ ប្រមាណ ២លាននាក់ធ្វើការនៅប្រទេសថៃ។

កន្លងទៅក្រៅពីការប្រើប្រាស់ថ្នាំញៀន ពលករខ្មែរ ក៏ប្រឈមនឹងបញ្ហាច្រើនយ៉ាង ដូចជាថៅកែកេងប្រវ័ញ្ចកម្លាំងពលកម្ម បង្ខំឱ្យធ្វើការហួសកម្លាំង ប្រើហិង្សាលើរាងកាយ ប្រមាថមើលងាយ និងបើកប្រាក់ខែឱ្យមិនទៀងទាត់ជាដើម។ ជារឿយៗពលករទាំងនោះមិនដែលទទួលបានយុត្តិធម៌នោះទេ នៅពេលដែលពួកគាត់ទៅប្ដឹងអំពីការរំលោភសិទ្ធិការងារពីសំណាក់ថៅកែថៃ។ ចំណែកឯ

ស្ថានទូតខ្មែរវិញកម្រចុះទៅអន្តរាគមន៍ឱ្យពលករ និងចុះត្រួតពិនិត្យពីស្ថានភាពរស់នៅរបស់ពួកគាត់នោះទេ។

មន្ត្រីសង្គមស៊ីវិលឱ្យដឹងថា កត្តាដែលជំរុញឱ្យពលករខ្មែរទៅធ្វើការនៅប្រទេសថៃ ដោយសារជីវភាពខ្វះខាត ធ្វើស្រែចម្ការបានផលតែគ្មានទីផ្សារ គ្មានការងារក្នុងស្រុក និងជំពាក់ប្រាក់ធនាគារជាដើម។ ក្រុមពលករឱ្យដឹងថា ពលករខ្មែរដែលញៀនថ្នាំទាំងនោះពុំដែលបានផ្ញើប្រាក់ទៅឱ្យសាច់ញាតិនៅកម្ពុជានោះទេ។ ជាមួយគ្នានេះពួកគេក៏មិនចង់ធ្វើការនៅតំបន់នោះដែរ ក៏ប៉ុន្តែដោយសារគ្មានជម្រើស ព្រោះជីវភាពក្រីក្រ និងអត់ការងារធ្វើនៅក្នុងស្រុក ដូច្នេះមានតែខំស្មោះនៅប្រទេសថៃបន្តទៀត ដើម្បីរកប្រាក់ដោះស្រាយជីវភាពគ្រួសារ។

## ក្រសួងការបរទេសតៃប៉ិត្រូវបានរិះគន់ជុំវិញករណីជួញដូរមនុស្សមកកម្ពុជា

https://www.khmertimeskh.com/501349554//?p=1349554 KhmerAugust 26, 2023

ក្រុមប្រឹក្សាឃ្លាំមើល (The Control Yuan) បានរិះគន់ក្រសួងការបរទេស (MOFA) និងការិយាល័យព្រះរាជអាជ្ញាស្រុក Kaohsiung ជុំវិញការដោះស្រាយករណីពាក់ព័ន្ធនឹងជនជាតិតៃវ៉ាន់ដែលត្រូវបានគេចាប់បង្ខាំងនៅកម្ពុជា បន្ទាប់ពីត្រូវបានចាប់ខ្លួននៅក្នុងការបោកប្រាស់ការងារ និងជួញដូរមនុស្ស។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានរបាយការណ៍អំពីជនជាតិតៃវ៉ាន់ដែលត្រូវបានគេធ្វើទារុណកម្ម ចាប់បង្ខាំង គំរាមកំហែងវះយកសរីរាង្គ និងត្រូវបានបង្ខិតបង្ខំឱ្យចូលរួមក្នុងសកម្មភាពបោកប្រាស់ បន្ទាប់ពីទទួលយកការងារក្រៅម៉ោងនៅក្នុងប្រទេសកម្ពុជា និងប្រទេសដទៃទៀត។

សមាជិកនៃក្រុមប្រឹក្សាឃ្លាំមើល (The Control Yuan) លោកស្រី Yeh Ta-hua និងលោកស្រី Chi Hui-jung បានដាក់របាយការណ៍ស៊ើបអង្កេតលើបញ្ហានេះ ដែលត្រូវបានអនុម័តដោយគណៈកម្មាធិការនៃក្រុមប្រឹក្សាឃ្លាំមើលលើកិច្ចការក្នុងស្រុក និងជនជាតិភាគតិចកាលពីថ្ងៃអង្គារសប្តាហ៍មុន។ សមាជិកនៃក្រុមប្រឹក្សាឃ្លាំមើល (The Control Yuan) លោកស្រី Yeh Ta-huaបង្ហាញរបាយការណ៍ក្នុងអំឡុងពេលសន្និសីទសារព័ត៌មាននៅឯ Control Yuan ក្នុងទីក្រុងតៃប៉ិ។

លោកស្រីYeh បានប្រាប់សន្និសីទសារព័ត៌មាននៅទីក្រុងតៃប៉ិថា ការិយាល័យរបស់ព្រះរាជអាជ្ញាបានបំពានគោលការណ៍ ដែលថា ការស៊ើបអង្កេតរបស់ព្រះរាជអាជ្ញាមិនត្រូវបង្ហាញជាសាធារណៈនោះទេ ខណៈដែលខ្លួនបានចេញវីដេអូទាក់ទងនឹងករណីឆបោកការងារកាលពីខែសីហាឆ្នាំមុន។ លោកស្រីបាននិយាយថា វីដេអូនេះត្រូវបានចេញផ្សាយ ខណៈដែលជនរងគ្រោះកំពុងជាប់ពន្ធនាគារក្នុងប្រទេសកម្ពុជា ហើយជាលទ្ធផល ពួកគេត្រូវបានធ្វើទារុណកម្មកាន់តែធ្ងន់ធ្ងរ។ លោកស្រី Yeh បានបន្តថា ក្នុងនាមជាក្រសួង ខ្លួនបានបរាជ័យក្នុងការគ្រប់គ្រងពីស្ថានការណ៍ជួញដូរ

មនុស្សនៅកម្ពុជា។ លោកស្រីបាននិយាយថា មជ្ឈមណ្ឌលហៅទូរសព្ទបន្ទាន់របស់ក្រសួងបានទទួលការហៅទូរស័ព្ទចំនួន ៦៤៣លើកដើម្បីសុំជំនួយទាក់ទងនឹងការបោកប្រាស់ការងារនៅក្រៅប្រទេសចាប់ពីឆ្នាំ២០២១ ដល់ខែមិថុនាឆ្នាំនេះ។ បន្ថែមពីលើនេះ មានពលរដ្ឋចំនួន ៦៨២នាក់ក្នុងប្រទេសកម្ពុជា ១៩៤នាក់ក្នុងប្រទេសថៃ និង១២៤នាក់ក្នុងប្រទេសមីយ៉ាន់ម៉ា បានស្វែងរកជំនួយពីការិយាល័យតៃវ៉ាន់នៅក្រៅប្រទេស។

លោកស្រី Yeh បាននិយាយថា អ្នកបង្ហោះវីដេអូ (YouTuber) ឈ្មោះ Hao-pang Bump បានបង្ហោះវីដេអូដែលចោទប្រកាន់ក្រសួងថា មិនព្រមជួយជនរងគ្រោះពីការបោកប្រាស់ការងារកាលពីខែមីនាឆ្នាំមុន ដោយបានបន្ថែមថា ក្រសួងគ្រាន់តែសុំឱ្យភ្នាក់ងារនគរបាលជាតិ និងភ្នាក់ងារផ្សេងទៀតឱ្យជួយដោះស្រាយបញ្ហានេះកាលពីខែឧសភាឆ្នាំមុន ដែលបានបង្ហាញពីកង្វះវិធានការណ៍ និងការឆ្លើយតប។" លោកស្រីបាននិយាយថា លើសពីនោះ មូលនិធិសង្គ្រោះបន្ទាន់សម្រាប់ប្រជាជនតៃវ៉ាន់ ដែលធ្វើដំណើរទៅក្រៅប្រទេស កម្រត្រូវបានប្រើប្រាស់ដោយសារតែដំណើរការដាក់ពាក្យសុំដ៏លំបាក ដែលនាំឱ្យមានភាពយឺតយ៉ាវក្នុងការជួយសង្គ្រោះជនជាតិតៃវ៉ាន់នៅក្រៅប្រទេស។

ក្រុមប្រឹក្សាឃ្លាំមើលបាននិយាយថា គួរតែមានការកែលម្អនិងបានស្នើឱ្យគណៈរដ្ឋមន្ត្រីឱ្យតាមដានជាមួយភ្នាក់ងារពាក់ព័ន្ធ។ របាយការណ៍បាននិយាយថា មូលនិធិសម្រាប់ការសង្គ្រោះបន្ទាន់នៅក្រៅប្រទេស គួរតែត្រូវបានប្រើប្រាស់ ដោយមានភាពបត់បែន ដើម្បីបង្ការភាពយឺតយ៉ាវ។ របាយការណ៍បាននិយាយថា ចំនួនមន្ត្រី និងនគរបាលផ្នែកកិច្ចការឧក្រិដ្ឋកម្មអន្តរជាតិ ដែលត្រូវបានដាក់នៅក្រៅប្រទេស គួរតែត្រូវបង្កើន ដោយបន្ថែមថា រដ្ឋាភិបាលគួរតែផ្តល់ជំនួយច្រើនជាងមុនដល់ជនរងគ្រោះ នៅពេលពួកគេត្រឡប់ទៅតៃវ៉ាន់វិញ។ បន្ថែមពីលើការជំរុញកិច្ចសហប្រតិបត្តិការផ្នែកតុលាការជាមួយប្រទេសផ្សេងទៀត វាមានសារៈសំខាន់ណាស់សម្រាប់វិស័យសាធារណៈក្នុងការធ្វើការជាមួយវិស័យឯកជន ដូចជាអង្គការសង្គ្រោះអន្តរជាតិ ក្រុមហ៊ុនអាកាសចរណ៍ និងធនាគារការងារជាដើម។ របាយការណ៍បាននិយាយថា ភ្នាក់ងារគួរតែសិក្សាករណីកន្លងមក ដើម្បីរៀបចំផែនការបង្ការ ចាត់តាំងអង្គភាពជាក់លាក់ ដើម្បីដោះស្រាយឧបទ្ទវហេតុបែបនេះ និងផ្តោតលើការចេញការព្រមានដល់ក្រុមដែលមានហានិភ័យខ្ពស់ ដូចជាយុវជន តាមរយៈមធ្យោបាយនានា ដែលពួកគេភាគច្រើនប្រើដើម្បីស្វែងរកការងារ។

ក្រសួងបាននិយាយថា ខ្លួនបាននិងកំពុងសហការជាមួយការិយាល័យតៃវ៉ាន់នៅក្រៅប្រទេស និងភ្នាក់ងារនគរបាលក្នុងស្រុក ដើម្បីដោះស្រាយបញ្ហានេះ ចាប់តាំងពីទទួលបានការហៅទូរស័ព្ទសុំជំនួយពីប្រជាពលរដ្ឋដែលធ្វើការនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ២០២១។ ក្រសួងបាននិយាយថា ខ្លួនបានចេញសេចក្តីជូនដំណឹង និងការព្រមានអំពីការធ្វើដំណើរម្តងហើយម្តងទៀត ចាប់តាំងពីពេល

នោះមក ដោយជំរុញអ្នកស្វែងរកការងារឱ្យប្រុងប្រយ័ត្នចំពោះការបោកប្រាស់ការងារបរទេស។ ក្រសួងបាននិយាយថា ខ្លួនកំពុងដោះស្រាយបញ្ហាហៅទូរស័ព្ទសុំជំនួយកាន់តែច្រើន បន្ទាប់ពីវីដេអូរបស់ Hao-pang Bump បានទាក់ទាញការចាប់អារម្មណ៍ពីប្រជាជន ហើយក្រសួងបានកោះប្រជុំ និងសហការជាមួយភ្នាក់ងារនគរបាល និងអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត។

ក្រសួងការបរទេសបាននិយាយថា មូលនិធិដែលប្រើប្រាស់សម្រាប់បេសកកម្មជួយសង្គ្រោះភាគច្រើនបានមកពីថវិការបស់ក្រសួងមហាផ្ទៃជាក់លាក់ ហើយមនុស្សជាច្រើនត្រូវបានជួយសង្គ្រោះ។ ក្រសួងបានបន្ថែមថា ការដែលក្រុមប្រឹក្សាឃ្លាំមើលបានលើកឡើងពីដំណើរការដាក់ពាក្យដែលពិបាក និងយឺតយ៉ាវ អាចជាការយល់ច្រឡំ។ ក្រសួងបាននិយាយថា ជោគជ័យនៃប្រតិបត្តិការជួយសង្គ្រោះគឺអាស្រ័យទៅលើថាតើព័ត៌មានគ្រប់គ្រាន់ត្រូវបានផ្តល់ និងឆន្ទៈរបស់ជនរងគ្រោះ និងសមាជិកគ្រួសាររបស់ពួកគេ ក៏ដូចជាបទប្បញ្ញត្តិក្នុងស្រុក និងលក្ខខណ្ឌនយោបាយ ដោយបន្ថែមថា ក្រសួង និងការិយាល័យរបស់ខ្លួននៅក្រៅប្រទេសមិន ដែលធ្វេសប្រហែសក្នុងករណីសង្គ្រោះគ្រាអាសន្ននោះទេ។

## កម្ពុជា-វៀតណាម
## ដាក់ទិសដៅបង្កើនកិច្ចសហប្រតិបត្តិការទប់ស្កាត់បទល្មើសគ្រប់ប្រភេទតាមព្រំដែន

https://www.postkhmer.com/national/2023-08-27-1637-253966.html *សុខ វក្សា* I Publication date 27 August 2023 I 16:37 ICT

***ភ្នំពេញ:*** *ស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី និងគណៈប្រតិភូបញ្ជាការកងទ័ពការពារព្រំដែន ខេត្តប៊ិញភឿកនៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានឯកភាពគ្នាក្នុងការបន្តជំរុញនូវកិច្ចសហប្រតិបត្តិការទប់ស្កាត់បទល្មើសគ្រប់ប្រភេទតាមព្រំដែនដើម្បីរក្សាសណ្តាប់ធ្នាប់នៃព្រំដែនទាំង២។ ការដាក់ទិសដៅនេះត្រូវបានសម្រេចឡើងនៅក្នុងកិច្ចប្រជុំបូកសរុបលទ្ធផល កិច្ចសហប្រតិបត្តិការរក្សាសន្តិសុខ សណ្តាប់ធ្នាប់តាមព្រំដែន ដែលដឹកនាំដោយលោក អ៊ិន ប៊ុន្នីរិទ្ធី ស្នងការរងទទួលផែនការងារសន្តិសុខនិងលោក ប៊ួយ មីញស័យ មេបញ្ជាការកងទ័ពការពារព្រំដែនខេត្តប៊ិញភឿក និងសមាជិកប្រតិភូជាច្រើនរូបទៀត កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៣។*

*តាមរយៈស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី លោក ប៊ួយ មីញស័យ បានស្នើឱ្យកងកម្លាំងភាគីទាំង២ ពង្រឹងកិច្ចសហការទប់ស្កាត់បទល្មើសគ្រប់ទម្រង់នៃការជួញដូរមនុស្ស បទល្មើសគ្រឿងញៀន បួន់ប្រដាប់អាវុធ ការជួញដូរអាវុធជាតិផ្ទុះ និងបទល្មើសគ្រប់ប្រភេទនៅតាមតំបន់ព្រំដែន។ លោក ប៊ួយ មីញស័យ បានថ្លែងថា៖ «សូមឱ្យកងកម្លាំងភាគីទាំង២ រួមសហការគ្នា ពង្រឹងការត្រួតពិនិត្យយ៉ាងហ្មត់ចត់លើប្រជាពលរដ្ឋឆ្លងដែន ទៅលេងល្បែងស៊ីសងនៅកាស៊ីណូនៅច្រកទ្វារទ្វេភាគី*

ឡាប៉ាខេ កម្ពុជា ច្រកទ្វារហ័ងយៀវ វៀតណាម ដែលធ្វើឱ្យប៉ះពាល់ដល់សន្តិសុខព្រំដែន»។ បន្ថែមពីនេះភាគីវៀតណាម ក៏បានស្នើឱ្យកងកម្លាំងភាគីទាំង២ ម្ចាស់ការសហការដោះស្រាយរាល់បញ្ហាដែលកើតមានឡើង នៅតាមតំបន់ព្រំដែន ដោយសន្តិវិធីតាមដែនសមត្ថកិច្ចរៀងៗខ្លួន។

ជាការឆ្លើយតប លោក អ៊ិន ប៊ុន្នីរិទ្ធី បានឯកភាពនឹងបន្តកិច្ចសហការឱ្យបានល្អជាមួយភាគីវៀតណាម ដោយលោកនឹងនាំយកសំណូមពរ ទាំងនេះរាយការណ៍ជូនស្នងការនគរបាលខេត្តមណ្ឌលគិរីដើម្បីគោរពសុំយោបល់ដឹកនាំបន្ត។ នៅក្នុងជំនួបនៃកិច្ចប្រជុំនេះដែរ ភាគីទាំង២ បានវាយតម្លៃខ្ពស់ចំពោះលទ្ធផលកិច្ចសហប្រតិបត្តិការរក្សាសន្តិសុខ សណ្តាប់ធ្នាប់តាមតំបន់ព្រំដែនប្រចាំឆ្នាំ២០២២ និងឯកភាពដាក់ចេញនូវទិសដៅសហប្រតិបត្តិការបន្តនៅឆ្នាំ២០២៣ នេះផងដែរ។

នាយកទទួលបន្ទុកកិច្ចការទូទៅ នៃអង្គការការពារសិទ្ធិមនុស្សលីកាដូ លោក អំ សំអាត បានថ្លែងប្រាប់នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៣ថា ការដាក់ចេញនូវទិសដៅគឺជារឿងសំខាន់ ប៉ុន្តែត្រូវអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព ខណៈបញ្ហាគ្រឿងញៀន គឺជាបញ្ហាធំដែលត្រូវតែមានកិច្ចសហប្រតិបត្តិការល្អរវាងបណ្តាប្រទេស ដែលជាប់ព្រំដែនកម្ពុជា ក្នុងនោះមាន វៀតណាម ថៃ និងឡាវ ជាដើម ដើម្បីទប់ស្កាត់នូវលំហូរចូលនៃគ្រឿងញៀន។ លោកបានបញ្ជាក់ថា៖«កន្លងមកឃើញលំហូរចូលតាមច្រកព្រំដែនមានច្រើន ដូចជាលំហូរចូលគ្រឿងញៀន បទល្មើសគ្រប់ប្រភេទ ក៏ដូចជាការជួញដូរមនុស្ស។ អ៊ីចឹង! បើសិនជាមានការរឹតបន្តឹង និងទប់ស្កាត់បាននោះវាជារឿងល្អមួយ ប៉ុន្តែត្រូវធ្វើយ៉ាងណាលុបបំបាត់អំពើពុករលួយ ហើយត្រូវតែហ៊ានចាត់វិធានការចំពោះមន្ត្រីណាដែលឃុបឃិតដែលបង្កឱ្យមានបទល្មើសទាំងនោះកើនឡើង»។

# ថ្ងៃទី៣០ ខែ សីហា ឆ្នាំ២០២៣

## ជនឆបោកតាមប្រព័ន្ធទូរគមនាគមន៍ និងអ៊ីនធឺណែតជាង ៣០០នាក់ ត្រូវបានបញ្ជូនទៅប្រទេសចិនវិញពីប្រទេសកម្ពុជា មីយ៉ាន់ម៉ា ហ្វីលីពីន និងឡាវ

https://www.khmertimeskh.com/501350919// Khmer Times August 29, 2023

ក្រសួងសន្តិសុខសាធារណៈរបស់ចិន បាននិយាយថា ចាប់តាំងពីដើមឆ្នាំនេះមក នគរបាលចិនបានចាប់ផ្តើមប្រតិបត្តិការរួមគ្នាជាមួយកងកម្លាំងនគរបាលមកពីប្រទេសហ្វីលីពីន កម្ពុជា មីយ៉ាន់ម៉ា និងឡាវ ហើយបានចាប់ខ្លួនជនសង្ស័យជាង ៣០០នាក់ហើយ ដោយបន្ថែមថាក រណីទាំងនេះនៅតែស្ថិតក្រោមការស៊ើបអង្កេតនៅឡើយ។

ស្ថានទូតចិនប្រចាំប្រទេសមីយ៉ាន់ម៉ាបាននិយាយកាលពីថ្ងៃសៅរ៍ថា កាលពីសប្តាហ៍មុន ជនឆបោក តាមប្រព័ន្ធទូរគមនាគមន៍ និងអ៊ីនធឺណែតសរុបចំនួន២៤នាក់ ត្រូវបានបញ្ជូនពីប្រទេសមី

យ៉ាន់ម៉ាទៅកាន់ប្រទេសចិនវិញក្នុងរយៈពេល៤ថ្ងៃ ។ ស្ថានទូតបានបន្តថា នៅអាកាសយានដ្ឋានអន្តរជាតិយ៉ាំងហ្គោន របស់ប្រទេសមីយ៉ាន់ម៉ា នគរបាលមីយ៉ាន់ម៉ា បានប្រគល់ជនសង្ស័យចំនួន៦នាក់ឱ្យនគរបាលចិននៅថ្ងៃទី២៣ ខែសីហា ជនសង្ស័យចំនួន ៩ នាក់នៅថ្ងៃទី ២៤ ខែសីហា ជនសង្ស័យចំនួន៨ នាក់នៅថ្ងៃទី២៥ ខែសីហា និងជនសង្ស័យចំនួន៥ នាក់នៅថ្ងៃទី ២៦ខែសីហា។

ជនសង្ស័យដែលត្រូវបានឃុំខ្លួនក្នុងប្រទេសមីយ៉ាន់ម៉ាត្រូវបានចោទប្រកាន់ថាបានធ្វើប្រតិបត្តិការឆបោកប្រជាជនចិនតាមប្រព័ន្ធទូរគមនាគមន៍។

ក្រសួងសន្តិសុខសាធារណៈរបស់ប្រទេសចិន បាននិយាយថា មានក្រុមឆបោកតាមប្រព័ន្ធទូរគមនាគមន៍កាន់តែច្រើន បានផ្លាស់ប្តូរទីតាំងរបស់ពួកគេចេញពីប្រទេសចិន ដើម្បីជៀសវាងការបង្ក្រាបរបស់នគរបាលក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ China Daily

## ក្រសួងសង្គមកិច្ច បន្តបើកកិច្ចប្រជុំពីនីតិវិធីប្រតិបត្តិបទដ្ឋានក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយអំពើជួញដូរមនុស្ស

https://freshnewsasia.com/index.php/en/localnews/307904-2023-08-29-06-36-10.html 2023-08-29 01:36pm

**(ភ្នំពេញ)៖** ក្រុមការងារបច្ចេកទេសដឹកនាំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបើកកិច្ចប្រជុំបច្ចេកទេស ស្តីពីការធ្វើបច្ចុប្បន្នភាព លើកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ពីនីតិវិធីប្រតិបត្តិបទដ្ឋានក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស។

ពិធីនេះបានធ្វើឡើងក្រោមវត្តមានលោក ញឹក វណ្ណារ៉ា រដ្ឋលេខាធិការ តំណាងលោក ជា សុមេធី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, លោក សៅ សុកៈ អនុរដ្ឋលេខាធិការ នៃក្រសួង ស.អ.យ, លោកស្រីឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ, លោក ឯក សំអុល ប្រធានគម្រោងកម្មវិធី របស់អង្គការ IOM, លោក ឡៅ វ៉េង អគ្គនាយករងសេវាសង្គមកិច្ច, លោក ជ័យ រដ្ឋ អគ្គនាយករងកុងសុល នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, លោក យូ សុភ័ក្រ ប្រធាននាយកដ្ឋានគាំពារជនរងគ្រោះ តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រធានមន្ទីរ ស.អ.យ ខេត្តជាប់ព្រំដែនវៀតណាម និងតំណាងអង្គការដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ។

ក្នុងនាមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា លោក ញឹក វណ្ណារ៉ា សូមថ្លែងអំណរគុណចំពោះអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (អាយ អូ អឹម) ដែលតែងតែសហការយ៉ាងជិតស្និទ ជាមួយក្រសួងសង្គមកិច្ច លើវិស័យសង្គមកិច្ចកន្លងមកដែលមាននាយកដ្ឋាន គាំពារជនរងគ្រោះជាសេនាធិការ ពិសេសថ្ងៃនេះបានសហការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការធ្វើបច្ចុប្បន្នភាព លើកិច្ចព្រមព្រៀងសហ ប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលវៀតណាម ពីនីតិវិធីប្រតិបត្តិបទដ្ឋានក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយអំពើជួញដូរមនុស្សនេះ។

ជាមួយគ្នានេះដែរ លោក ញឹក វណ្ណារ៉ា បានបន្តថា នីតិវិធីប្រតិបត្តិបទដ្ឋានក្នុងការ កំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយអំពើជួញដូរមនុស្សបានកើតឡើងតាំងពីឆ្នាំ២០០៩ រហូតមកដល់ពេលនេះ មានរយៈពេលជាង១៣ឆ្នាំកន្លងផុតទៅហើយ ដែលជាហេតុតម្រូវឱ្យភាគី នៃប្រទេសទាំងពីរត្រូវតែធ្វើបច្ចុប្បន្នភាពឡើងវិញនូវ SOP មួយនេះ។ មួយទៀត អំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មលើមនុស្សបានកើតឡើង និងកំពុងរីកសាយភាយគ្រប់ទីកន្លែងគ្រប់រូបភាពភាគច្រើនជាឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំងហើយឧក្រិដ្ឋកម្មនេះបានធ្វើឱ្យប៉ះពាល់ទាំងថ្នាក់ជាតិ តំបន់ និងលើពិភពលោក។

មន្ត្រីជាន់ខ្ពស់ក្រសួងសង្គមកិច្ច បានលើកឡើងថា បញ្ហានេះប្រទេសកម្ពុជាបាននឹងកំពុងបង្កើតរៀបចំចងក្រងផ្សព្វផ្សាយ អនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ កិច្ចព្រមព្រៀងទ្វេភាពហុភាគី និងយន្តការនានាសំដៅប្រយុទ្ធប្រឆាំង និងចូលរួមកាត់បន្ថយឱ្យបានជាអតិបរិមានូវអំពើជួញដូរមនុស្សទាំងក្នុងក្របខ័ណ្ឌជាតិ តំបន់ និងលើពិភពលោក ពិសេសជាងនោះទៅទៀត ការសម្របសម្រួល ក្នុងកំណត់អត្តសញ្ញាណបឋម ការផ្តល់សេវា ការរៀបចំធ្វើមាតុភូមិនិវត្តន៍ ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស គឺជាចំណុចដ៏សំខាន់ដែលប្រទេសជាម្ចាស់ហត្ថលេខីទាំងអស់នៃសន្ធិសញ្ញាស្តីពីការលុបបំបាត់ ប់អំពើជួញដូរមនុស្សត្រូវតែអនុវត្តឱ្យបានពេញលេញ និងផ្តល់សេវាដល់ ជនរងគ្រោះដោយអំពើជួញដូរមនុស្សដោយមិនប្រកាន់និន្នាការជាតិពន្ធនោះឡើយ។

ក្នុងបរិបទនេះ លោកសង្ឃឹមយ៉ាងមុតមាំថា ការចូលរួមក្រុមការងារបច្ចេកទេស (អ្នកអនុវត្តជាក់ស្តែង) របស់លោក លោកស្រី និងធ្វើឱ្យសិក្ខាមួយនេះមានអត្ថន័យក្នុងចូលរួមមតិយោបល់ ជាតុចូលផ្សេងៗ ដើម្បីជាប្រយោជន៍ដល់ជនរង់គ្រោះដោយអំពើជួញដូរមនុស្សនិងរំលោភបំពានផ្លូវភេទពិសេសស្ត្រី និងកុមាររងគ្រោះដោយអំពើជួញដូរមនុស្ស និងកេងប្រវ័ញ្ចផ្លូវភេទនៅកម្ពុជា ឬនៅប្រទេសគោលដៅណាមួយ។

ក្នុងនាមក្រសួងសង្គមកិច្ច លោក ញឹក វណ្ណារ៉ា សូមសូមគោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់នាយកដ្ឋានគាំពារជនរងគ្រោះ ដែលបានខិតខំប្រឹងប្រែងសហការយ៉ាងសកម្មជាមួយអង្គការដៃគូលើការកសាងឯកសារមួយនេះ និងសូមថ្លែងអំណរគុណចំពោះអង្គការដៃគូអភិវឌ្ឍន៍ទាំងអស់ ជានិច្ចជាកាលតែងតែសហការជាមួយក្រសួងសង្គមកិច្ច លើវិស័យការងារសង្គមកិច្ច ជាពិសេសអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (អាយ អឹម) បានជួយគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសក្នុងដំណើរការកសាងឯកសារនេះឡើង។

ទន្ទឹមនឹងនេះដែរ លោកក៏សូមអំពាវនាវដល់អង្គការដៃគូអភិវឌ្ឍន៍ទាំងអស់មេត្តាជួយគាំទ្រ និងមានកិច្ចសហការបន្តជាមួយក្រសួងសង្គមកិច្ច ឱ្យបានច្រើនជាងនេះដើម្បីរួមគ្នាការពារ និងទប់ស្កាត់ជនរងគ្រោះអំពើជួញដូរមនុស្សនាពេលអនាគត់។ ជាមួយគ្នានេះ លោកសង្ឃឹមយ៉ាងមុតមាំថាឯកសារនេះនឹងក្លាយជាពិសេសមធ្យោបាយសម្រាប់ការអនុវត្តការងារជាក់ស្តែងប្រកបដោយប្រសិទ្ធិភាពខ្ពស់ និងជាជំនួយស្មារតីដល់អ្នកផ្តល់សេវាថែទាំជនរងគ្រោះ ការកំណត់អត្តសញ្ញាណបឋម ការផ្តល់សេវា និងការសម្របសម្រួលក្នុងការធ្វើមាតុភូមិនិវត្តជនរងគ្រោះនៃជនជាតិទាំងពីរ គឺកម្ពុជា និងវៀតណាម៕

# ថ្ងៃទី៣១ ខែ សីហា ឆ្នាំ២០២៣

## មេដឹកនាំអាស៊ានប្តេជ្ញាជាថ្មី ក្នុងការដោះស្រាយឧក្រិដ្ឋកម្មឆ្លងដែន និងពង្រឹងសន្តិសុខតាមព្រំដែន

https://www.postkhmer.com/national/2023-08-29-1815-254041.html វី សុថាន់ | Publication date 29 August 2023 | 18:15 ICT

***ភ្នំពេញ:*** មេដឹកនាំអាស៊ាន បានអះអាងជាថ្មី ពីការប្តេជ្ញាចិត្តក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូសន្ទនា និងភាគីខាងក្រៅ ដើម្បីដោះស្រាយឧក្រិដ្ឋកម្មឆ្លងដែន និងពង្រឹងសន្តិសុខតាមព្រំដែនខណៈពួកគេបានទទួលស្គាល់ការគំរាមកំហែង នៃការរត់ពន្ធអាវុធនៅក្នុងតំបន់អាស៊ាន និងបញ្ហាប្រឈមក្នុងការទប់ស្កាត់ការជួញដូរអាវុធខុសច្បាប់។ ការប្តេជ្ញាចិត្តនេះ ធ្វើឡើងនៅក្នុងកិច្ចប្រជុំពេញអង្គថ្នាក់រដ្ឋមន្ត្រីអាស៊ាន ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន (AMMTC) លើកទី១៧នៅទីក្រុងឡាប៊ូនបាចូ (Labuan Bajo) ប្រទេសឥណ្ឌូនេស៊ី កាលពីថ្ងៃទី២១ ខែសីហា ដែលដឹកនាំដោយប្រទេសឥណ្ឌូនេស៊ីជាប្រធានអាស៊ាននៅឆ្នាំនេះ។ លោក សុខ ផល រដ្ឋលេខាធិការក្រសួងមហាផ្ទៃកម្ពុជា បានដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំនេះ។

សេចក្តីថ្លែងការណ៍រួមនៃកិច្ចប្រជុំនេះដែលទើបចេញផ្សាយនៅថ្ងៃទី២៩ ខែសីហា បានបញ្ជាក់ថា៖ «យើងបានផ្លាស់ប្តូរទស្សនៈ និងបញ្ជាក់ឡើងវិញពីការប្តេជ្ញាចិត្តរបស់យើងក្នុងការអនុ

វត្តផែនការសកម្មភាពអាស៊ានក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនឆ្នាំ២០១៦-២០២៥»។ កិច្ចប្រជុំបានកត់សម្គាល់ពីវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកិច្ចប្រជុំឧត្តមមន្ត្រី ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន (SOMTC) ឆ្នាំ២០២២-២០២៤ដើម្បីអនុវត្តផែនការសកម្មភាពរបស់អាស៊ានហើយទន្ទឹងរង់ចាំការអនុវត្តយ៉ាងរឹងមាំនិងពេញលេញនៃវិស័យទាំង១០របស់ខ្លួន។

សេចក្តីថ្លែងការណ៍រួមបញ្ជាក់ថា៖ «យើងបានទទួលស្គាល់ការគំរាមកំហែងនៃការរត់ពន្ធអាវុធដែលរីករាលដាលនៅក្នុងតំបន់អាស៊ាន និងបញ្ហាប្រឈមក្នុងការបង្ការ និងទប់ស្កាត់ការជួញដូរ និងការរត់ពន្ធអាវុធ និងគ្រាប់រំសេវឆ្លងដែនខុសច្បាប់។ ក្នុងន័យនេះ យើងបានអនុម័តសេចក្តីប្រកាសអាស៊ានស្តីពីការប្រយុទ្ធប្រឆាំងនឹងការរត់ពន្ធអាវុធ ដែលជាការប្តេជ្ញាចិត្តក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការដោះស្រាយបញ្ហាប្រឈមដែលកំពុងកើនឡើងទាំងនេះ។

យើងសូមកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសកម្ពុជា ក្នុងឋានៈជាប្រធានដឹកនាំកិច្ចប្រជុំ SOMTC លើវិស័យអាទិភាពនៃការរត់ពន្ធអាវុធក្នុងការដឹកនាំរៀបចំសេចក្តីប្រកាសនេះ»។ ប្រភពដដែលបានបន្ថែមថា៖«យើងសូមបញ្ជាក់ឡើងវិញពីការប្តេជ្ញាចិត្តរបស់យើងក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូសន្ទនាអាស៊ាន និងភាគីខាងក្រៅពាក់ព័ន្ធផ្សេងទៀតដើម្បីដោះស្រាយឧក្រិដ្ឋកម្មឆ្លងដែន និងពង្រឹងសន្តិសុខព្រំដែន»។

អង្គប្រជុំនោះបានស្វាគមន៍ការអនុម័តផែនការការងារ SOMTC ចំនួន ៦ ស្តីពីកិច្ចសហប្រតិបត្តិការដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន រួមមាន ប្រទេសបូក៣នៃដៃគូអាស៊ានពីឆ្នាំ២០២៤-២០២៧, ប្រទេសចិនពីឆ្នាំ២០២៤-២០២៧ ,ឥណ្ឌាពីឆ្នាំ២០២៣-២០២៧, ប្រទេសជប៉ុនពីឆ្នាំ២០២៣-២០២៧ ,នូវែលសេឡង់ពីឆ្នាំ២០២៣-២០២៥ និងសហរដ្ឋអាមេរិកពីឆ្នាំ២០២៣-២០២៦។

កិច្ចប្រជុំក៏បានអនុម័តសេចក្តីប្រកាសក្រុងឡាប៊ូនបាចូ ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ក្នុងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនផងដែរ ដែលជាការប្តេជ្ញាចិត្តក្នុងការពន្លឿននិងលើកកម្ពស់ប្រសិទ្ធភាព នៃការអនុវត្តច្បាប់ក្នុងការដោះស្រាយករណីឧក្រិដ្ឋកម្មឆ្លងដែននៅក្នុងតំបន់អាស៊ាន។ ជាមួយគ្នានេះ កិច្ចប្រជុំបានកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសឥណ្ឌូនេស៊ី ក្នុងឋានៈជាប្រធានកិច្ចប្រជុំ AMMTC ក្នុងការដឹកនាំរៀបចំសេចក្តីប្រកាសនេះ និងបានសង្កត់ធ្ងន់លើគោលការណ៍នៃធម្មនុញ្ញអាស៊ាន ជាពិសេសការគោរព លើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងទទួលស្គាល់សិទ្ធិជនរងគ្រោះនិងសាក្សី។

សេចក្តីថ្លែងការណ៍រួមបន្ថែមថា៖« ក្នុងន័យនេះយើងបានអនុម័តសេចក្តីប្រកាសអាស៊ានស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការការពារ និងជួយសាក្សី និងជនរងគ្រោះនៃឧក្រិដ្ឋកម្មឆ្លងដែនដែលជាការប្តេជ្ញាចិត្តចំពោះការការពារ និងការផ្តល់ជំនួយដល់សាក្សី និងជនរងគ្រោះ»។ មួយវិញ

ទៀត កិច្ចប្រជុំក៏បានកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសឥណ្ឌូនេស៊ីក្នុងឋានៈជាប្រធានដឹកនាំកិច្ចប្រជុំ SOMTC លើវិស័យអាទិភាពនៃអំពើភេរវកម្ម ក្នុងការដឹកនាំរៀបចំសៀវភៅណែនាំអាស៊ានស្តីពីការអប់រំកែប្រែ ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មអ្នកទោសក្នុងពន្ធនាគារពាក់ព័ន្ធនឹងអំពើភេរវកម្ម និងអំពើជ្រុលនិយមដោយហិង្សា។

កិច្ចប្រជុំរង់ចាំប្រើប្រាស់សៀវភៅណែនាំនេះក្នុងការផ្តល់ដល់អ្នកធ្វើសេចក្តីសម្រេចចិត្តនូវការណែនាំដ៏មានសារៈប្រយោជន៍សម្រាប់ការបង្កើតនិងអនុវត្តកម្មវិធីស្តារនីតិសម្បទា និងសមាហរណកម្មប្រកបដោយប្រសិទ្ធភាពដោយផ្អែកលើចំណេះដឹង ដែលបានផ្តល់ពីអ្នកជំនាញពាក់ព័ន្ធក្នុងវិស័យនេះ។ ក្នុងឱកាសនៃកិច្ចប្រជុំនេះលោក សុខ ផល និងលោក ListyoSigit Prabowo អគ្គស្នងការនគរបាលជាតិឥណ្ឌូនេស៊ីក៏បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ រវាងក្រសួងមហាផ្ទៃកម្ពុជា និងនគរបាលជាតិឥណ្ឌូនេស៊ីស្តីពីកិច្ចសហប្រតិបត្តិការក្នុងការបង្ការនិងប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែននិងការលើកកម្ពស់ការកសាងសមត្ថភាព៕

## UN ព្រមានថា មនុស្សរាប់សែននាក់ ត្រូវបានក្រុមឧក្រិដ្ឋជនបោកប្រាស់ តាមប្រព័ន្ធអនឡាញ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍

https://dap-news.com/international/2023/08/30/354943/ BySS107Posted on August 30, 2023 1:33 pm

ហ្សឺណែវ៖ អង្គការសហប្រជាជាតិ (UN) កាលពីថ្ងៃអង្គារ បានព្រមានថា មនុស្សរាប់សែននាក់កំពុងត្រូវបានបង្ខិតបង្ខំនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ក្នុងនោះក្រុមឧក្រិដ្ឋជនឱ្យធ្វើសកម្មភាពបោកប្រាស់តាមអ៊ីនធើណេត ដែលជារឿយៗស្ថិតនៅក្រោមការគំរាមកំហែងនៃការធ្វើទារុណកម្ម ។ UN បានឲ្យដឹងនៅក្នុងរបាយការណ៍មួយថា មនុស្សជាច្រើននាក់ត្រូវបានគេជួញដូរឱ្យធ្វើការក្នុងឧក្រិដ្ឋកម្មអនឡាញ ហើយប្រឈមមុខនឹងការរំលោភដ៏ធ្ងន់ធ្ងរ ដូចជា ការធ្វើទារុណកម្ម ឬអំពើហិង្សាផ្លូវភេទជាដើម ។

លោក Volker Turk ប្រធានសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ បានលើកឡើងថា "អ្នកដែលត្រូវបានបង្ខិតបង្ខំឱ្យធ្វើការក្នុងប្រតិបត្តិការបោកប្រាស់ទាំងនេះ ស៊ូទ្រាំនឹងការប្រព្រឹត្តដោយអមនុស្សធម៌ ខណៈដែលត្រូវបានបង្ខំឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម" ។ លោកបានបញ្ជាក់ថា "ពួកគេជាជនរងគ្រោះ ។ ពួកគេមិនមែនជាឧក្រិដ្ឋជននោះទេ" ។

របាយការណ៍បានកត់សម្គាល់ថា ទំហំ នៃការវាយប្រហារនៅក្នុងអាស៊ីអាគ្នេយ៍ គឺពិបាកក្នុងការវាស់ស្ទង់ដោយសារតែលក្ខណៈនៃការលាក់កំបាំង និងចន្លោះប្រហោងក្នុងការឆ្លើយតបរបស់អាជ្ញាធរ ។ យ៉ាងណាមិញ របាយការណ៍បានឲ្យដឹងថា ប្រភពដែលអាចជឿទុកចិត្តបានបានបង្ហាញ

ថា យ៉ាងហោចណាស់មនុស្ស ១២០.០០០នាក់នៅទូទាំងប្រទេសមីយ៉ាន់ម៉ា អាចនឹងត្រូវបានឃុំខ្លួននៅក្នុងស្ថានភាពដែលពួកគេត្រូវបានគេបង្ខំឱ្យអនុវត្តការបោកប្រាស់តាមអ៊ីនធើរណេត ។

បើតាមការប៉ាន់ស្មាននៅក្នុងប្រទេសកម្ពុជា មានចំនួនប្រហែល១០ម៉ឺននាក់ ៕ ប្រែសម្រួលដោយ៖ ម៉ៅ បុប្ផាមករា

## សមត្ថកិច្ចឥណ្ឌូណេស៊ី ចាប់ខ្លួនជនជាតិចិន៨៨នាក់ដែលបបួលថតស្រា.តដើម្បីជំរិ.តទារលុយ

https://kohsantepheapdaily.com.kh/article/1795179.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ៣០ ខែ សីហា ឆ្នាំ ២០២៣ ម៉ោង ២២:២៣

សមត្ថកិច្ចឥណ្ឌូណេស៊ី ប្រកាសកាលពីថ្ងៃពុធអំពីការចាប់ខ្លួនជនជាតិចិន ៨៨នាក់ ពីបទសង្ស័យថាពួកគេជាក្រុមឆបោកដោយប្រើ «ល្បិចប្រុសស្អាត ស្រីស្អាត» ដើម្បីដាក់អន្ទាក់ជនជាតិចិនដូចគ្នានៅប្រទេសចិនឱ្យធ្លាក់ចូលក្នុងល្បិចស្នេហាក្លែងក្លាយដែលពួកគេបង្កើតឡើង។ នៅក្នុងល្បិចនេះ, ក្រុមឆបោកធ្វើជាបង្កើតស្នេហា និងបបួលគ្នាថតអាក្រាត។ បន្ទាប់មក ក្រុមខិលខូចគំរាមជនរងគ្រោះថាត្រូវតែផ្ញើលុយឱ្យខ្លួន។ បើមិនដូច្នេះទេ ខ្លួននឹងបង្ហាញរូបនេះទៅក្រុមគ្រួសាររបស់ជនរងគ្រោះ។

ការឈានទៅបំបែកសម្បុកក្រុមឆបោកនេះ ក៏ទទួលបានតម្រុយខ្លះៗ ពីអាជ្ញាធរនៅប្រទេសចិនដែលផ្តល់ជាគិនភាគ និងអត្តសញ្ញាណរបស់ក្រុមនេះ។ សមត្ថកិច្ចឥណ្ឌូណេស៊ីចាប់ខ្លួនបុរស ៨៣នាក់ និងនារី៥នាក់នៅសួនឧស្សាហកម្មនៃទីក្រុងបាថាម (Batam) កាលពីថ្ងៃអង្គារ។ សមត្ថកិច្ចឱ្យដឹងថាមុននឹងឈានដល់ការវែកមុខពួកគេ, ក្រុមឆបោកបានជំរិតជនរងគ្រោះរាប់រយនាក់នៅប្រទេសចិន។ ភាគច្រើននៃជនរងគ្រោះទាំងនោះជាមន្ត្រីរដ្ឋាភិបាល ឬអ្នកបម្រើការនៅតាមមន្ទីរ-ក្រសួងនានា។

សមត្ថកិច្ចថ្លែងថាខ្លួនកំពុងស៊ើបអង្កេតសំណុំរឿងនេះ ដើម្បីចង់ដឹងថាតើនៅក្នុងចំណោមជនរងគ្រោះទាំងនោះមានជនជាតិឥណ្ឌូណេស៊ីដែរ ឬទេ។ ប្រសិនបើគ្មានទេ, សមត្ថកិច្ចនឹងបណ្តេញក្រុមឆបោកទាំង៨៨នាក់ចេញពីប្រទេសឥណ្ឌូណេស៊ីជាបន្ទាន់។ សមត្ថកិច្ចឱ្យដឹងថាក្រុមឆបោកព្យាយាមទាក់ទងស្នេហាផ្អែមល្ហែមជាមួយជនរងគ្រោះតាមរយៈការសន្ទនាគ្នាតាមវីឌីអូ ឬហៅម៉្យាងទៀតថាវីឌីអូខល (video call)។

ក្រុមឆបោកជានារីព្យាយាមប្រើប្រាស់វិធីអូសទាញជនរងគ្រោះដំបូងសិន។ បន្ទាប់មក, ពួកគេអូសទាញជនរងគ្រោះឱ្យថតបង្ហាញកេរខ្មាស ដោយមានគ្នាគេចាំថតយករូបវីឌីអូរបស់ជនរងគ្រោះ។ បន្ទាប់ពីបានវីឌីអូហើយ, ពួកគេចាប់ផ្តើមប្រើសម្តីខ្លាំងដាក់ជនរងគ្រោះដើម្បីជំរិតទារប្រាក់។ ពួកគេ

គំរាមថានឹងយកវីឌីអូអាក្រាតនោះទៅបង្ហោះនៅលើបណ្តាញសង្គម បើជនរងគ្រោះមិនព្រមផ្ញើលុយឱ្យពួកគេ។ សមត្ថកិច្ចមិនទាន់ស្រាវជ្រាវដឹងថាតើក្រុមឆបោកនេះបើកប្រតិបត្តិការរយៈពេលប៉ុន្មានខែ ប៉ុន្មានឆ្នាំហើយ។

ម៉្យាងទៀត គេក៏មិនទាន់ដឹងថា តើក្រុមឆបោកនេះរកបានប្រាក់ប៉ុន្មាន ពីអំពើទុច្ចរិតរបស់ពួកគេ។ បន្ទាប់ពីរដ្ឋាភិបាលចិនបើកយុទ្ធនាការបង្ក្រាបយ៉ាងចាស់ដៃទៅលើក្រុមឆបោក និងបណ្តាញរបស់ពួកគេនៅប្រទេសចិន, ពួកនេះក៏បាត់បង់ទីតាំងឈរ និងពិបាកគ្រប់គ្រងបណ្តាញរបស់ពួកគេ។ ដូច្នេះ ពួកគេក៏បង្វិចិត្តផ្លាស់ប្តូរទីតាំងប្រតិបត្តិការ អំពើខិលខូចរបស់ខ្លួនទៅប្រទេសផ្សេងៗ ឧទាហរណ៍ ប្រទេសឥណ្ឌូណេស៊ី និងប្រទេសដទៃទៀតនៅតំបន់អាស៊ីអាគ្នេយ៍។ កាលពីឆ្នាំ២០១៩, សមត្ថកិច្ចឥណ្ឌូណេស៊ីចាប់ខ្លួនជនជាតិចិន៨៥នាក់ និងជនជាតិឥណ្ឌូណេស៊ី៦នាក់ពាក់ព័ន្ធនឹងអំពើឆបោកតាមអនឡាញ។ កាលនោះ, សមត្ថកិច្ចរកឃើញថាពួកគេជំរិតទារប្រាក់ពីជនរងគ្រោះបានរាប់លានដុល្លារឯណោះ៕ ប្រភព៖ Channel News Asia

## **អាជ្ញាធរខេត្តកណ្តាលផ្សព្វផ្សាយច្បាប់ជួញដូរមនុស្ស និងហិង្សាក្នុងគ្រួសារដល់ប្រជាពលរដ្ឋ**

https://www.postkhmer.com/national/2023-08-30-1022-254053.html ជា សុខនី। Publication date 30 August 2023 । 10:22 ICT

**ភ្នំពេញៈ** គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តកណ្តាល កាលពីថ្ងៃទី ២៨ ខែសីហា បានបើកវេទិកាផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ជូនដល់ប្រជាពលរដ្ឋនៅ ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ដើម្បីបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើហិង្សាក្នុងគ្រួសារតាមគ្រប់រូបភាពទាំងអស់។ យោងតាមការផ្សព្វផ្សាយរបស់រដ្ឋបាលខេត្តកណ្តាល ចេញផ្សាយនៅថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០២៣។

លោកស្រី ឈឹម វណ្ណនី ស្នងការរងនគរបាលខេត្តកណ្តាល និងជាអនុប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានបញ្ជាក់ថា គោលបំណងនៃការបើកវេទិកានេះឡើង ដើម្បីឱ្យប្រជាពលរដ្ឋបានយល់កាន់តែច្បាស់អំពីអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។ លោកស្រីថ្លែងថា អភិបាលខេត្តកណ្តាល បានជំរុញឱ្យអាជ្ញាធរពាក់ព័ន្ធយកចិត្តទុកដាក់អនុវត្តការងាររួមគ្នា បង្ការទប់ស្កាត់ និងចាត់វិធានការតាមច្បាប់ ឱ្យបានទាន់ពេលវេលាចំពោះជនល្មើស និងមេខ្យល់ដែលបានប្រើប្រជាតិចុតតាមគ្រប់រូបភាព»។

លោក នី សុខា ប្រធានសមាគមការពារសិទ្ធិមនុស្ស អាដហុក ថ្លែងនៅថ្ងៃទី ២៩ ខែសីហា ថា ជារួមរូបភាពនៃការរៀបចំផ្សព្វផ្សាយច្បាប់ ទាក់ទងនឹងអំពើជួញដូរមនុស្សនេះ គឺវាជារឿងល្អ និងឱ្យកាន់តែទូលំទូលាយបន្តទៅទៀត ជាពិសេសប្រជាពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋានតំបន់ព្រំដែនមាន

ការខ្វះខាតព័ត៌មានពួកគាត់នឹងងាយចាញ់បោកមេខ្យល់ និងងាយត្រូវបានជនល្មើសយកទៅជួញដូរផងដែរ។ លោកថ្លែងថា ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីច្បាប់ការជួញដូរ និងបង្ក្រាបអំពើជួញដូរមនុស្ស គឺនៅមានកម្រិតទាបណាស់ ជាពិសេសប្រជាពលរដ្ឋនៅតាមជនបទដាច់ស្រយាល ឬនៅជិតព្រំដែន ស្ទើរតែមិនមានការយល់ដឹងអំពីច្បាប់ទាំងនេះសោះ៕

## ស្ថានឯកអគ្គរាជទូតកម្ពុជា ជូនដល់ប្រជាពលរដ្ឋខ្មែរកំពុងរស់នៅ ធ្វើការ និងសិក្សា ក្នុងប្រទេសជប៉ុនឱ្យចូលរួមគោរពច្បាប់

http://nokorwatnews.com/archives/1037358 30/08/2023

ភ្នំពេញ ៖ សេចក្តីជូនដំណឹង របស់ស្ថានឯកអគ្គរាជទូតកម្ពុជា ជូនដល់ប្រជាពលរដ្ឋខ្មែរកំពុងរស់នៅ ធ្វើការ និងសិក្សា ក្នុងប្រទេសជប៉ុនឱ្យចូលរួមគោរពច្បាប់ និងយន្តការផ្តល់សេវាគាំពារ និងទ្រទ្រង់ដល់កម្មសិក្សាការី និងពលករជំនាញ ដោយស្ថានទូតកម្ពុជា និងក្រសួង-ស្ថាប័នពាក់ព័ន្ធ។ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសជប៉ុន សូមជម្រាបជូនដល់បងប្អូនប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅ ធ្វើការ និងសិក្សាក្នុងប្រទេសជប៉ុន មេត្តាជ្រាបថា កន្លងទៅថ្មីៗនេះស្ថានទូតបាន ទទួលព័ត៌មានតាមរយៈអង្គភាពប៉ូលីសជប៉ុនីនិងនៅលើបណ្តាញទំនាក់ទំនងសង្គមហ្វេសប៊ុក អំពីករណីប្រព្រឹត្តខុសច្បាប់របស់បងប្អូនខ្មែរមួយចំនួន មានដូចជា ចោរកម្ម អសុពលភាពនៃទិដ្ឋាការស្នាក់នៅ បើកបររថយន្តដោយគ្មានបណ្ណបើកបរ និងមានជាតិស្រវឹងនៅពេលបើកបរ ការរត់គេចចេញពីកន្លែងធ្វើការ ដែលខ្លួនបានចុះកុងត្រាជាមួយដោយសារការជឿតាមមេខ្យល់។ល។

ចំពោះករណីដូចខាងលើនេះ ស្ថានទូតសូមលើកទឹកចិត្តដល់បងប្អូន ធ្វើការពិចារណាឱ្យបានហ្មត់ចត់មុននឹងចូលរួម ឬប្រព្រឹត្តិនូវអំពើខុសច្បាប់ ដែលនាំមកនូវការចាប់ខ្លួន ឃុំខ្លួន បាត់បង់ឱកាសការងារ ដែលធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍ផ្ទាល់ខ្លួន និងកិត្តិយសប្រទេសជាតិ។ សូមបញ្ជាក់ជូនថា ក្នុងការបំពេញតួនាទី និងភារកិច្ចពេញលេញរបស់ខ្លួន ស្ថានទូតតែងផ្តល់សេវាគាំពារ និងទ្រទ្រង់ដល់ ផលប្រយោជន៍ការងាររបស់បងប្អូនប្រជាពលរដ្ឋខ្មែរ កម្មសិក្សាការី និងពលករជំនាញទាំងអស់នៅ ប្រទេសជប៉ុន ដោយមិនមានការរើសអើង ឬបែងចែកជាក្រុមបក្សពួកឡើយ ប៉ុន្តែស្ថានទូតមិនគាំទ្រ ជាដាច់ខាតចំពោះរាល់សកម្មភាពទាំងឡាយណាដែលផ្ទុយនឹងច្បាប់។

ពាក់ព័ន្ធនឹងការប្រព្រឹត្តនូវសកម្មភាពខុសច្បាប់របស់អតីតកម្មសិក្សាការីខ្មែរកន្លងមក ក៏មានពាក្យចចាមអារ៉ាមថា បណ្តាលមកពីពុំមានការដោះស្រាយបញ្ហាការងារពីសំណាក់ស្ថានទូត ក្នុងខណៈ ដែលស្ថានទូតតែងចាត់ទុកបញ្ហាការងារ និងការរស់នៅរបស់កម្មសិក្សាការី និងពលករជំនាញខ្មែរជា អាទិភាពចម្បង ដោយបានខិតខំសហការជាមួយភាគីពាក់ព័ន្ធ ដើម្បីដោះស្រាយឱ្យមាន

ប្រសិទ្ធភាព និង ទទួលបានជោគជ័យ។ លើសពីនេះ ការស្នើសុំឱ្យមានវិធានការផ្លូវច្បាប់ ចំពោះមេខ្យល់បោកបញ្ឆោត កម្មសិក្សាការី ទៅធ្វើការខុសច្បាប់ និងចំពោះនិយោជកជប៉ុន ដែលបានទទួលកម្មសិក្សាការីខុសច្បាប់ ទៅធ្វើការនៅតាមរោងចក្រ សហគ្រាសរបស់ខ្លួន គឺជាចំណុចសំខាន់ដែលស្ថានទូតតែងពិភាក្សាជាមួយ ក្រសួង ស្ថាប័នជប៉ុន កន្លងមក។

នៅក្នុងដំណើរការដោះស្រាយបញ្ហាការងារ និងការរស់នៅរបស់ប្រជាពលរដ្ឋខ្មែរនៅប្រទេសជប៉ុន ស្ថានទូតស្នើសុំបងប្អូនសិក្សាស្វែងយល់ឱ្យបានទូលំទូលាយពី "សៀវភៅសម្រាប់កម្មសិក្សាការីហ្វឹកហ្វឺនជំនាញ" រៀបចំដោយអង្គការហ្វឹកហ្វឺនជំនាញសម្រាប់ជនបរទេស (OTIT) ដែលបានសង្ខេបលំអិតពីសិទ្ធិ កាតព្វកិច្ច បែបបទការងារ នីតិវិធីដោះស្រាយការងារ អាស័យដ្ឋាន និងព័ត៌មានទំនាក់ទំនង ក្នុងករណីដែលមានបញ្ហាការងារ ឬការរស់នៅជាយថាហេតុ។ ចំពោះកម្មសិក្សាការី និងពលករ ជំនាញខ្មែរ ដែលមានបញ្ហាការងារ អ្នកទាំងនោះ អាចធ្វើការប្រឹក្សាយោបល់ និងស្នើសុំអន្តរាគមន៍ពី សំណាក់ ៖ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសជប៉ុន :

o Facebook Page : Royal Embassy of Cambodia in Japan (និងភាសាជប៉ុន) អាស័យដ្ឋាន : 8-6-9 Akasaka, Minato-ku, Tokyo 107-0052 Tel,: 03-5412-8521 រៀងរាល់ថ្ងៃធ្វើការ ចាប់ពីម៉ោង ៩:០០ ដល់ម៉ោង ១៦:០០។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ការិយាល័យរកការងារឱ្យធ្វើនៅបរទេសទី ៣ : Tel.: +855-89-957-789 • Facebook: www.facebook.com/overseasplacement.Japanoffice

អង្គការ OTIT Tel: 0120-250-366 រៀងរាល់ថ្ងៃព្រហស្បតិ៍ ចាប់ពីម៉ោង ១១:០០ ដល់ម៉ោង ១៩:០០ Website: www.support.otit.go.jp/soudan/kh/

ស្ថានទូតស្នើសុំកម្មសិក្សាការី និងពលករជំនាញខ្មែរ ដែលកំពុងធ្វើការក្នុងប្រទេសជប៉ុនទាំងអស់ មេត្តាចូលរួមគោរពច្បាប់ឱ្យបានហ្មត់ចត់ ខិតខំធ្វើការ និងអភិវឌ្ឍសមត្ថភាពជំនាញ ជាពិសេសកុំជឿ តាមការអូសទាញរបស់មេខ្យល់ទៅធ្វើការខុសច្បាប់ ដែលនាំឱ្យបាត់បង់ប្រយោជន៍ការងាររបស់ខ្លួន។ ការខិតខំបំពេញការងារ និងចូលរួមអនុវត្តច្បាប់របស់បងប្អូន គឺជាការចូលរួមថែរក្សាកិត្តិយសប្រទេសជាតិ និងជាកត្តាជម្រុញលើកទឹកចិត្តដល់និយោជកជប៉ុនឱ្យធ្វើការជ្រើសរើសកម្លាំងពលកម្មខ្មែរមកធ្វើការនៅ តាមរោងចក្រ-សហគ្រាសរបស់ខ្លួនឱ្យកាន់តែច្រើន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមបងប្អូនប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅ ធ្វើការ និង សិក្សាក្នុងប្រទេសជប៉ុន មានភាពកក់ក្តៅ និងជឿទុកចិត្តមកលើយន្តការផ្តល់សេវាគាំពារ និងទ្រទ្រង់ ដែលផ្តល់ដោយស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសជប៉ុន៕